មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0179**

**សម្ភាសន៍ជាមួយឈ្មោះ ប៉ាន ឈួន ភេទប្រុស អាយុ៦៤ឆ្នាំ**

**មុខងារនៅសម័យខ្មែរក្រហមៈ «អនុប្រធានកងចល័តតំបន់៥»**

**សព្វថ្ងៃរស់នៅភូមិដូនជ្រែង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ**

**ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១១**

**សម្ភាសន៍ដោយៈ ឡុង ដានី**

**០២:២៨:៥៣**

**៨៨ទំព័រ**

ដានី : ចឹងដឹបូងចង់ស្គាល់ឈ្មោះលោកពូ ឈ្មោះពេញឈ្មោះអីដែរ?

ឈួន : ប៉ាន ឈួន ។

ដានី : ប៉ាន ឈួន?

ឈួន : បាទ!

ដានី : ពូអាយុប៉ុន្មានហើយសព្វថ្ងៃ?

ឈួន : ខ្ញុំ ៦៤ឆ្នាំ ។

ដានី : កំណើតកើតជានៅជានៅណាដែរ?

ឈួន : នៅព្រះនេត្រព្រះ ។

ដានី : នៅភូមិអី?

ឈួន : ភូមិប៉ោយសំរោង ។

ដានី : ឃុំអីដែរ?

ឈួន : បាទ! ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តអូ!នែក ពីដើមខេត្តបាត់ដំបង ។

ដានី : ព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង?

ឈួន : បាទ!

ហ៊ុយ : នៅបន្ទាយមានជ័យយើងទើបនឹងកើតឆ្នាំ៨៧ ។

ដានី : សព្វថ្ងៃរស់នៅភូមិអីដែរ?

ឈួន : នៅភូមិដូនជ្រែង ឃុំព្រះនេត្រព្រះដែរ ។

ដានី : ភូមិដូនជ្រែង ឃុំព្រះនេត្រព្រះដែរ?

ឈួង ៖ បាទ!

ដានី ៖ ប្រពន្ធលោកពូ គាត់ឈ្មោះអីដែរ?

ឈួង ៖ ឈ្មោះ ទុយ សុផល ។

ដានី ៖ ទុយ សុផល គាត់អាយុប៉ុន្មានដែរ?

ឈួង ៖ អាយុ៥១ ។

ដានី ៖ អាយុ៥១ ។ លោកពូមានកូនចៅប៉ុន្មាននាក់ដែរ?

ឈួង ៖ អត់មានទេ មានតែកូនចិញ្ចឹម ។

ដានី ៖ កូនចិញ្ចឹមប៉ុន្មាននាក់?

ឈួង ៖ កូនចិញ្ចឹម២នាក់ ហើយកូនខែក!ខាងប្រពន្ធម្នាក់ វាដូចតែកូនខ្លួនឯង ទាំងអស់៣ ។

ហ៊ុយ ៖ កូនប្រពន្ធ កូនបង្កើតហើយ ។

ឈួង ៖ នោះហើយ កូនប្រពន្ធ ប៉ុន្តែប្តីគេមុន ។

ដានី ៖ កូនចិញ្ចឹម២នាក់ ចុះប្រុស?

ឈួង ៖ ប្រុស១ ស្រី១ ។

ដានី ៖ បើកូនខាងប្រពន្ធលោកពូស្រី ឬប្រុស?

ឈួង ៖ ប្រុស ។

ដានី ៖ លោកពូប្រកបមុខរបរធ្វើស្អីដែរ?

ឈួង ៖ ធ្វើស្រែ ។

ដានី ៖ ធ្វើស្រែ?

ឈួង ៖ បាទ!

ដានី ៖ មានធ្វើអីទៀត?

ហ៊ុយ ៖ គណៈកម្មការវត្ត ។

ដានី ៖ គណៈកម្មការវត្ត?

ឈួង ៖ បាទ!

ដានី ៖ ឪពុកពូ គាត់ឈ្មោះអីដែរ?

ឈួង ៖ ឈ្មោះ ប៉ាន ហឹន ។

ដានី ៖ ប៉ាន ហឹន?

ឈួង ៖ ប៉ាន ហៀន នោះហើយ ហ៎ា ។

ដានី ៖ ស្រះវឿ និង ន (ហឿន)?

ឈួង ៖ ហ្នឹងហើយ ។

ដានី ៖ ហឿន សព្វថ្ងៃគាត់នៅរស់ទេ?

ឈួង ៖ ខូចហើយ ។

ដានី ៖ ខូចតាំងពីអង្កាល់?

ឈួង ៖ ខូចឆ្នាំ៧៩ ។

ដានី ៖ ចុះម្ដាយ?

ឈួង ៖ ម្ដាយឈ្មោះ ខៀវ ពួយ ។

ដានី ៖ ខៀវ?

ឈួង ៖ ពួយ ។

ដានី ៖ ខៀវ ពួយ?

ឈួង ៖ បាទ!

ដានី ៖ ពួយ គាត់នៅរស់ ឬខូចហើយ?

ឈួង ៖ គាត់ខូចនៅឆ្នាំ៧៧ ។

ដានី ៖ ៧៧?

ឈួង ៖ បាទ!

ដានី ៖ ជិតនាន់៣ឆ្នាំ?

ឈួង ៖ បាទ!

ដានី ៖ ចុះលោកពូមានបងប្អូនប៉ុន្មាននាក់?

ឈួង ៖ បងប្អូនមាន៦នាក់ ។

ដានី ៖ បងប្អូន៦នាក់ ។ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ឈួង ៖ ស្រី២ ប្រុស៤ ។

ដានី ៖ ស្រី២ ប្រុស៤ ។ ពូកូនទីប៉ុន្មានដែរ?

ឈួង ៖ ខ្ញុំកូនទីពូចគេ ។

ដានី ៖ កូនពៅ?

ឈួង ៖ បាទ!

ដានី ៖ កូនពៅ ។ លោកពូកាលពីក្មេងៗរៀនសូត្រដល់ថ្នាក់ណាដែរ?

ឈួង ៖ ខ្ញុំមិនបានរៀនច្រើនទេ រៀនដល់ថ្នាក់ទីបទីកដ្ឋាន ថ្នាក់ទី១០ ។

ដានី ៖ រៀនថ្នាក់ទី១០?

ឈួង ៖ ទី១០ចាស់ ។

ដានី ៖ ១០ចាស់ នៅសាលាណាដែរ?

ឈួង ៖ នៅព្រះនេត្រព្រះ ។

ដានី ៖ នៅព្រះនេត្រព្រះ ហើយកាលនឹងពូឈប់រៀនឆ្នាំណា?

ឈួង ៖ អូ! មិនដឹងឆ្នាំណា ។

ដានី ៖ មុនរដ្ឋប្រហារយូរ?

ឈួង ៖ បាទ! អូ!មុនយូរហើយ រដ្ឋប្រហារខ្ញុំបានប្រពន្ធហើយ ។

ដានី ៖ អូ! ដល់ពេលឈប់រៀនហើយ ពូធ្វើអីទៀតទៅ?

ឈួង ៖ ដើរស៊ីឈ្នួលគេ ។

ដានី ៖ ដើរស៊ីឈ្នួល?

ឈួង ៖ បាទ! ធ្វើការរោងម៉ាស៊ីនស៊ីឈ្នួលភ្ជួរគេ អត់ដែលមានស្រែធ្វើ ស៊ីឈ្នួលចិញ្ចឹមម្តាយៗខ្ញុំគាត់ចាស់ជរាទៅ ឪពុកខ្ញុំគាត់ខ្វាក់ ។

ដានី ៖ ស៊ីឈ្នួលគេធ្វើស្អីគេ នៅរោងម៉ាស៊ីន?

ឈួង ៖ រោងម៉ាស៊ីន ប៉ិ ង៉ៅ ស៊ី ព្រះនេត្រព្រះ ។

ដានី ៖ រោងម៉ាស៊ីននឹង រោងម៉ាស៊ីនអីគេ?

ឈួង ៖ កិនស្រូវ ។

ដានី ៖ កិនស្រូវ?

ឈួង ៖ បាទ!

ដានី ៖ រោងម៉ាស៊ីនកិនស្រូវ ហើយនឹងស៊ីឈ្នួលនឹងនៅរោងម៉ាស៊ីនកិនស្រូវ ធ្វើអីគេនឹង?

ឈួង ៖ ទេ! កាលនឹងនៅកិនស្រូវ ប៉ុនចេញពីនោះមក ខ្ញុំចូលធ្វើស្រែធ្វើស៊ីឈ្នួលគេម៉ារដូវកាលដូចថាម៉ារដូវ ចូលភូមិនេះម៉ារដូវ នោះក៏ទៅភូមិនោះទៅណា ខែច្រូតភូមិនេះ ខែភ្ជួរក៏ភូមិនោះ ។

ដានី ៖ បាទៗ ពូធ្វើស៊ីឈ្នួលធ្វើស្រែច្រូត?

ឈួង ៖ បាទ!

ដានី ៖ កាលនឹងយើងស៊ីឈ្នួលគេរហូតដល់ឆ្នាំណាបានឈប់?

ឈួង ៖ ខ្ញុំស៊ីឈ្នួលគេរហូតដល់ឆ្នាំ៧២ ។

ដានី ៖ ដល់ឆ្នាំ៧២ ហើយយ៉ាងម៉េចទៀត?

ឈួង ៖ ដល់ឆ្នាំ៧២ ខ្ញុំរត់ម៉ូតូរឺម៉ក់ ពីដើមមិញ រត់រឺម៉ក់ម៉ូតូ ។

ដានី ៖ រត់រឺម៉ក់ម៉ូតូ ពូរត់រឺម៉ក់ម៉ូតូពីណាទៅណា?

ឈួង ៖ រត់រឺម៉ក់ម៉ូតូនោះ ពីស្វាយយើងនេះទៅសៀមរាប ។

ដានី ៖ ពីស្វាយ?

ឈួង ៖ ទៅសៀមរាប ។

ដានី ៖ ទៅសៀមរាប?

ឈួង ៖ បាទ!

ដានី ៖ យើងរត់យ៉ាងម៉េចអានឹង យើងរត់?

ឈួង ៖ រត់ដឹកអំបិល កាលនោះខ្មែរក្រហមវ៉ៃដាច់ផ្លូវច្រើន យើងដឹកអំបិលទៅលក់ឯសៀមរាប ប៉ុនយើងមិនមែនលក់ទេ យើងស៊ីឈ្នួលដឹកឲ្យគេ ។

ដានី ៖ ដឹកអំបិលពីស្វាយទៅសៀមរាប?

ឈួង ៖ បាទ!

ដានី ៖ អត់មានដឹកអីទៀត?

ឈួង ៖ អត់ទេ មានដឹកតែប៉ុននោះឯង ។

ដានី ៖ មានដឹកតែអំបិល?

ឈួង ៖ បាទ! ដល់ពេលដល់ឆ្នាំ ដល់ចុងឆ្នាំ៧២ ខ្មែរក្រហមចាប់ ។

ដានី ៖ ខ្មែរក្រហមចាប់?

ឈួង ៖ បាទ!

ដានី ៖ កាលពេលដឹកអំបិល យើងដឹកម៉ាថ្ងៃប៉ុន្មានដើង?

ឈួង ៖ ម៉ាដើង ។

ដានី ៖ ដឹកម៉ាដើង?

ឈួង ៖ បាទ!

ដានី ៖ ដល់ឆ្នាំ៧២ ខ្មែរក្រហមចាប់នៅណា?

ឈួង ៖ ចាប់នៅខាងកើតសសរស្តម្ភ ហៅផ្លូវវត្តប្រាសាទ ។

ដានី ៖ ខាងកើត?

ឈួង : ខាងកើតសសរស្តម្ភ ។

ដានី : សសរស្តម្ភ?

ឈួង : ហៅវត្តប្រាសាទ ។

ដានី : សសរស្តម្ភ វត្តប្រាសាទ?

ឈួង : នោះហើយ ។

ដានី : កាលនោះនៅដីអ្នកណាគេ ដីសៀមរាប ក៏ដីព្រះនេត្រព្រះ?

ឈួង : ដីសៀមរាប ។

ដានី : សៀមរាប ។ ចាប់ហើយយ៉ាងម៉េចទៅ?

ឈួង : ដល់ខ្មែរក្រហមចាប់ គេចាប់ទាំងអស់វា៦គ្រឿង ម៉ូតូវា៦គ្រឿង ។

ដានី : ចាប់៦គ្រឿង?

ឈួង : បាទ! ដល់យប់ឡើងគេនាំគ្នារត់ ទាំងខ្ញុំអីចេញមកវិញណា ។

ដានី : រត់ចោលម៉ូតូ?

ឈួង : បាទ! ដល់រត់ចោល ដល់ខ្ញុំអត់ហ៊ានរត់ ខ្ញុំនឹកឃើញថា បើរត់ទៅខ្លាចមកដល់នេះ គេទារម៉ូតូខ្ញុំមិនមានអីសងគេ ។

ដានី : អូ! ជួលម៉ូតូគេទេ?

ឈួង : បាទ! ម៉ូតូគេ ខ្ញុំកូលីគេ កម្មករគេ ។ ហើយគេអ្នកដែលមានម៉ូតូខ្លួនគេ គេរត់ចោលម៉ូតូមកដល់ខ្ញុំនេះ ខ្ញុំនឹងរត់ចោលម៉ូតូដូចគ្នា ខ្លាចគេឲ្យសងនោះ ខ្ញុំមិនមានអីសង បានខ្ញុំក៏នៅធ្វើខ្មែរក្រហមជាមួយគេទៅ ។ ដឹងមកមិនមានអីសងគេ សុខចិត្តថា តស៊ូនៅជាមួយគេមិនហ៊ានរត់ ។ ផុតពីនោះគេរត់ចេញមកអស់ ។

ដានី : អត់រត់ក៏នៅជាមួយខ្មែរក្រហមទៅ?

ឈួង : បាទ!

ដានី : យើងនៅជាមួយ យើងធ្វើអីខ្លះទៅកាលនឹង?

ឈួង : នៅកាលនោះគេឲ្យខ្ញុំកិនស្រូវ គេឲ្យកិនតែស្រូវ ។

ដានី : កិនស្រូវនៅម្តុំណា?

ឈួង : កិនស្រូវនៅនឹងភ្នំខ្សាច់ ខាងលិចភ្នំក្រោម ។

ដានី : យើងកាលនឹងនៅជាមួយខ្មែរក្រហមកិនស្រូវ មានធ្វើអីទៀត?

ឈួង : បាទ! ដល់កិនស្រូវបានម៉ាឆ្នាំ បានគេបញ្ជូនឲ្យមកនៅគោកខ្ពស់ ។

ដានី ៖ នៅទួលខ្ពស់?

ឈួន ៖ បាទ! គោកខ្ពស់ ។

ដានី ៖ គោកខ្ពស់?

ឈួន ៖ បាទ!

ដានី ៖ គោកខ្ពស់នៅណាទៅ?

ឈួន ៖ គោកខ្ពស់យើងនៅខេត្តបន្ទាយមានជ័យយើង អូ!គោកខ្ពស់វានៅខាងយើងនេះ ។

ដានី ៖ ព្រះប្រទល់បាត់ដំបង បន្ទាយមានជ័យ?

ឈួន ៖ បាទ! បាត់ដំបងបន្ទាយមានជ័យ ។ ប៉ុនណា ប្រជាជនវានៅខាងនោះ អាវត្តគោកខ្ពស់វានៅត្រើយខាងយើងនេះ ។ ប៉ុនយើងមិនបាននៅវត្តគោកខ្ពស់ទេណា នៅគោកខ្ពស់ គេហៅគោកខ្ពស់មួយនៅក្នុងព្រៃ គេហៅគោកខ្ពស់ណា គេហៅបងដើរគោកខ្ពស់ ។

ដានី ៖ នៅធ្វើអីទៅនៅនឹង?

ឈួន ៖ នៅកិនស្រូវ ក៏ទៅគេឲ្យធ្វើប្រធានក្រុមៗកិនស្រូវនឹងឯង ។

ដានី ៖ ធ្វើប្រធានក្រុមកិនស្រូវ?

ឈួន ៖ ហ្នឹងហើយ ។

ដានី ៖ កាលនឹងយើង ម៉េចបានកិនស្រូវច្រើនម៉េច កាលពូនៅអ្នកកិនស្រូវដែរ ទៅដល់នោះកិនស្រូវទៀត?

ឈួន ៖ បាទ! ចុះដូចថាស្រូវវាយកបានទៅ ដូចថាវាអត់មានអីហូបនោះ ពួកខ្មែរក្រហមគ្នាវាច្រើននោះ យើងកិនស្រូវបានចែកគ្នាហូប ។

ដានី ៖ បាទ! យើងកិនស្រូវនឹង កិនម៉ាស៊ីន ហើយកិនដៃ?

ឈួន ៖ ទេ! កិនដៃ អាត្បាល់ដៃយើងនឹង ។

ដានី ៖ ត្បាល់ដៃ?

ឈួន ៖ នោះហើយ កិនដៃ ។

ដានី ៖ គ្នាប៉ុន្មាននាក់ អ្នកកិនស្រូវនឹង?

ឈួន ៖ អូ! ច្រើនណាស់ ស្រីផង ប្រុសផង ដូចមិនបាន មិនបានជារៀបរាប់ទេ ។

អ្នកជិតខាង ៖ ម៉ាក្រុម១០នាក់ដឹង ត្បាល់មួយ ។

ឈួន ៖ តែម៉ាក្រុមខ្ញុំ៣០នាក់ ហៅកងតូច ។ ហើយខ្ញុំគេឲ្យធ្វើអាប្រធានកងតូច គេឲ្យកិនតែស្រូវនឹងឯង ។

ដានី ៖ យើងកិនតែស្រូវទេ អត់មានធ្វើប្រធានទេ?

ឈួង ៖ បាទ!

ដានី ៖ ហើយយ៉ាងម៉េចទៀតទៅ?

ឈួង ៖ ដល់ពេលគេឡើងមកវៃសមរភូមិ មកវៃពាមកំពង់សាំងយើងនេះ គេឲ្យពួកកិនស្រូវនេះ មកអីវ៉ាន់ គេអ្នកវៃ យើងអ្នកយក ។

ដានី ៖ ឆ្នាំណា ពេលដែលគេវៃ?

ឈួង ៖ ឆ្នាំ៧៣ ។

ដានី ៖ ពេលឆ្នាំ៧៣ ពេលវៃនៅណា កំពង់អី?

ឈួង ៖ កំពង់ក្រសាំង ពាមកំពង់ក្រសាំង ។

ដានី ៖ ពាមកំពង់ក្រសាំង?

ឈួង ៖ បាទ!

ដានី ៖ នៅណានឹង ពាមកំពង់ក្រសាំង?

ឈួង ៖ នេះ ពាមកំពង់ក្រសាំងយើង នៅឃុំភ្នំលាភ ។

ដានី ៖ អានឹងពេលដែលគេវៃបានទៅគេឲ្យក្រុមរបស់ពូមកយកអីវ៉ាន់?

ឈួង ៖ បាទ! យកអីវ៉ាន់ទៅសម្រាប់ហូបខ្លួនយើង យកស្បៀង ខ្វះស្អីយកនោះ ខ្វះយក ។

ដានី ៖ មកប្រមូលអីវ៉ាន់?

ឈួង ៖ បាទ!

ដានី ៖ ប្រមូលអីវ៉ាន់ទៅណាទៅ?

ឈួង ៖ យកទៅចែកគ្នាហូបទៅ ទៅទុកកន្លែងអគ្គការ កន្លែងរួមទៅគេហៅកន្លែងអគ្គការ ។

ដានី ៖ ហើយម៉េចទៀតទៅ?

ឈួង ៖ ដល់ក្រោយមកបានគេបញ្ជូនខ្ញុំមកនៅយើងតាខ្មៅនេះ ។

ដានី ៖ អាហ្នឹងឆ្នាំណា ដែលបញ្ជូនមក?

ឈួង ៖ ឆ្នាំ៧៤ អូ!នែក! ៧៤ ។

ដានី ៖ ៧៤ បញ្ជូនពូក្រុមកិនស្រូវ៣០នាក់នឹង?

ឈួង ៖ បាទ! បញ្ជូនប្រុសៗមក៣០នាក់ មកឲ្យជួយលើកទំនប់គេនេះ លើកទំនប់តាខ្មៅ ។

ដានី ៖ ប្រុសៗមក៣០នាក់?

ឈួង ៖ បាទ!

ដានី ៖ មកជួយលើកទំនប់?

ឈួង ៖ បាទ!

ដានី ៖ ទំនប់នៅណា?

ឈួង ៖ នៅតាខៀវ ។

ដានី ៖ នៅតាខៀវ នៅណា?

ឈួង ៖ ស្រណាល តាខៀវនៅ ។

ហ៊ុយ ៖ បាទ! ស្រណាល ឃុំសំបួរ ។

ឈួង ៖ នោះហើយ ឃុំសំបួរ ។

ដានី ៖ ឃុំសំបួរ?

ឈួង ៖ បាទ!

ហ៊ុយ ៖ ស្រុកមង្គលបូរី ។

ដានី ៖ សំបួរ ដូនឡឹក ។

ឈួង ៖ សំបួរ ដូនឡឹក ស្រុកមង្គលបូរី ។

ដានី ៖ ដូនឡឹក?

ឈួង ៖ បាទ!

ដានី ៖ មកលើកទំនប់នឹង កាលនឹងពូអ្នកដឹកនាំលើក?

ឈួង ៖ ទេ! ឲ្យមានគេធំជាងខ្ញុំទៅទៀត ប៉ុនខ្ញុំវាប្រធានកង ។

ដានី ៖ ប្រធានកង?

ឈួង ៖ បាទ!

ហ៊ុយ ៖ ប្រធានធំឈ្មោះអី?

ឈួង ៖ ឈ្មោះ នែក!អឺ!ភ្លេចឈ្មោះ មើលចាំរកនឹកគិត ។

ដានី ៖ បាទៗ មកលើកនឹង ទំនប់លើកដំបូងហើយឆ្នាំ៧៨ យើងចាប់ផ្ដើមលើកទំបន់ លើកអី?

ឈួង ៖ បាទ! ដែលលើកកាលនោះ មិនទាន់រំដោះទេ នៅក្នុងព្រៃ ។

ដានី ៖ កាលនឹងគេមានផែនការឲ្យលើកទំនប់?

ឈួង ៖ បាទ!

ដានី ៖ យើងអត់ទាន់រំដោះ?

ឈួង ៖ បាទ! នោះគេមានផែនការលើកទំនប់ក្នុងព្រៃ ។

ដានី ៖ ទំនប់ គេហៅទំនប់តាខៀវ?

ឈួង ៖ នោះហើយទំនប់តាខៀវ ។

ដានី ៖ លើករយៈពេលប៉ុន្មានទៅ?

ឈួង ៖ លើកមិនដឹងប៉ុន្មានទេ លើកដឹងបានប៉ុន្មានក៏ចាប់ពួកអ្នកព្រះនេត្រព្រះទៅ ។ កាលចាប់ពួកព្រះនេត្រព្រះទៅបង់ៗយើង អ្នកប៉ោយគ្មៀង អ្នកខាងជើងវត្ត ដែលបង់ត្រីរហាល ក្រពើ ច្រើន ក៏មកកៀរយកទៅទាំងអស់ ។

ដានី ៖ មកកៀរពួកណា?

ឈួង ៖ ពួកអ្នកបង់ ។

ដានី ៖ អ្នកបង់សំណាញ់?

ឈួង ៖ បង់សំណាញ់ ប្រជាជន បង់ត្រី ។

ដានី ៖ នៅណា នៅរហាល?

ឈួង ៖ នៅរហាល ក្រពើច្រើន ។

ដានី ៖ ដល់ពេលចាប់ កៀរយកទៅណាទៅ?

ឈួង ៖ ចាប់ទៅឲ្យទៅជួយលើកទំនប់នឹងហើយ ។

ដានី ៖ ឲ្យទៅជួយលើកទំនប់?

ឈួង ៖ បាទ!

ដានី ៖ កាលនឹងលើកទំនប់រយៈពេលប៉ុន្មានទៅបានហើយ?

ឈួង ៖ ទេ! លើកមិនបានហើយទេ លើកបានតិចក៏សន្តិភាព ។

ដានី ៖ ចុះលោកពូមានប្រសាសន៍ថា មិញថាលោកពូរៀបការតាំងពីមុនរដ្ឋប្រហារឆ្នាំ៧០?

ឈួង ៖ បាទ! នោះប្រពន្ធមុនខ្ញុំ ។

ដានី ៖ ចឹងឆ្នាំណាដែលលោកពូរៀបការនឹង?

ឈួង ៖ ឆ្នាំ៦៨ ខ្ញុំបានសែន នោះប្រពន្ធដើមខ្ញុំ ។

ដានី ៖ ជាមួយប្រពន្ធមុន?

ឈួង ៖ បាទ!

ដានី ៖ ប្រពន្ធមុន គាត់ឈ្មោះអីដែរ?

ឈួង ៖ ឈ្មោះ ទូច ភាន ។

ដានី ៖ ទូច ភាន ។ ចុះដល់ពេលពូរៀបការហើយបានពូទៅស៊ីឈ្នួលគេ?

ឈួន ៖ បាទ!

ដានី ៖ ស៊ីឈ្នួលដូចដឹករ៉ឺម៉កម៉ូតូអីនឹង

ឈួន ៖ បាទៗ ។

ដានី ៖ ចុះពេលដែលពូចេញមកនៅជាមួយខ្មែរក្រហមគស៊ូអីនឹង នៅជាមួយប្រពន្ធដែល ហើយក៏អត់ទេ?

ឈួន ៖ ទេ! ប្រពន្ធខ្ញុំនៅជាមួយម៉ែឪឯផ្ទះនោះ ។

ដានី ៖ អូ! ចឹង?

ឈួន ៖ បាទ!

ដានី ៖ លោកពូចេញមកគស៊ូតែឯងទេ?

ឈួន ៖ បាទ!

ដានី ៖ ដល់យើងចេញទៅចឹង ខស្សរាហ៍ជួបប្រពន្ធកូនទេ?

ឈួន ៖ អត់ទេ អត់ដែលបានជួប ខ្ញុំភ្លេចឈ្មោះ មេឃុំសំបួរ បងដានៗឈ្មោះដាន ដែលគាត់ធ្វើប្រធានលើកទំនប់នោះណា ឈ្មោះដាន ។

ដានី ៖ ឈ្មោះ ដាន?

ឈួន ៖ នោះឯង ។

ដានី ៖ នៅកន្លែង តាខៀវ នឹង?

ឈួន ៖ បាទ!

ដានី ៖ ប្រធានមេឃុំសំបួរម៉េង?

ឈួន ៖ នោះហើយ មេឃុំសំបួរ មេឃុំដែលគេរំដោះបាន គេឲ្យគាត់ធ្វើមេឃុំ ។

ដានី ៖ ចឹងលោកពូលើកទំនប់នៅតាខៀវនឹង ដល់ពេលណាទៅបានចប់?

ឈួន ៖ ដល់ពេលចាប់ប្រជាជនពីព្រះនេត្រព្រះទៅជួយលើកទៅ ដល់ក្រោយមកគេយកកម្លាំងពួកខ្ញុំនេះទៅដឹកផ្លូវនៅមេឃច្បារ ដឹកផ្លូវជាតិ ដឹកថ្នល់ជាតិ ។ ដល់ដឹកថ្ងៃនោះ ប្រហែលម៉ោង ៩ សន្តិភាពបណ្តោយ កំពុងដឹកនោះសន្តិភាពបណ្តោយ ។

ដានី ៖ កំពុងតែដឹក?

ឈួន ៖ បាទ!

ដានី ៖ បានន័យថា ពេលដែលដឹកទៅ កំពុងតែដឹកនឹង ខ្មែរក្រហមរំដោះបានភ្នំពេញឆ្នាំ៧៥?

ឈួន ៖ បាទៗ ។

ដានី ៖ កំពុងដឹកនៅណា?

ឈួង ៖ ទេ! ដឹកថ្នល់មេយប្បារយើង ថ្នល់អូរញ៉ែរ ។

ដានី ៖ ដឹកធ្វើអីអានឹង?

ឈួង ៖ ដឹកមកកាត់ផ្ដាច់ផ្លូវថ្មី ឲ្យឡានមកជួយគ្នាបាន ព្រោះទ័ពយើងវ៉ៃងអាខាងខ្មែរក្រហមកំពុងវ៉ៃ នឹងភ្នំតូច ដល់ហើយដឹកកាត់ផ្លូវកុំឲ្យវាមកជួយ ។

ដានី ៖ ចឹងដល់ពេលឆ្នាំ ពេលកំពុងតែដឹកនឹង ក៏បែកឆ្នាំ៧៥ទៅ?

ឈួង ៖ បាទ!

ដានី ៖ ហើយយ៉ាងម៉េចទៀតទៅ ពេលបែកពូយ៉ាងម៉េចទៀត?

ឈួង ៖ ដល់ពេលបែកទៅ ខ្ញុំក៏មកផ្ទះមក ខ្ញុំមិនទៅអង្គភាពវិញទេ ខ្ញុំមកឃើញកូនប្រពន្ធខ្ញុំ អឺ! ឃើញម៉ែ ឃើញឪខ្ញុំវេទនា ខ្ញុំក៏នៅផ្ទះ ខ្ញុំក៏ឈប់ធ្វើខ្មែរក្រហមទៅ ។

ដានី ៖ ត្រឡប់មកផ្ទះវិញ?

ឈួង ៖ បាទ!

ដានី ៖ ហ្នឹងពូត្រឡប់មកផ្ទះវិញ នៅណាទៅនឹង?

ឈួង ៖ នៅប៉ោយសំរោងនឹងឯង ។

ដានី ៖ ត្រឡប់មកផ្ទះ?

ឈួង ៖ នៅប៉ោយសំរោង ភូមិប៉ោយសំរោង ។

ដានី ៖ នៅប៉ោយសំរោង កាលនឹងលោកពូមានកូនដែរអត់?

ឈួង ៖ អត់ ។

ដានី ៖ អត់មានកូនទេ?

ឈួង ៖ អត់ មានតែប្រពន្ធ ។

ដានី ៖ ប៉ោយសំរោង ។

ឈួង ៖ ហើយបានដល់គេចូលបានរៀបចំមេឃុំអីទៅ បានគេហៅខ្ញុំចូលទៅធ្វើការវិញ ។

ដានី ៖ ពេលណាដែលពូ ដែលគេរៀបចំហើយ គេឲ្យពូទៅធ្វើការវិញ?

ឈួង ៖ គេរៀបចំឆ្នាំ៧៨ អូ!៧៥ ប៉ុន្តែក្នុងខែ៤ ដែលគេហៅខ្ញុំទៅវិញ ។

ដានី ៖ បានន័យថារំដោះ ថ្ងៃ១៧មេសា ៧៥ បានន័យថា១៧ ខែ៤?

ឈួង ៖ បាទ!

ដានី ៖ ខែ៤ ៧៥ គេរំដោះភ្នំពេញ?

ឈួង : បាទ!

ដានី : ចឹងខែប៉ុន្មានទៅ ដែលលោកពូគេបានទៅ?

ឈួង : ដែលគេហៅខ្ញុំទៅវិញ វាត្រូវខែ៧ ខែ៨នឹងឯង ព្រោះខែដែលយើងភ្ជួរ ។

ដានី : បាទ! ខែ៧ ខែ៨ ៧៥នឹង?

ឈួង : បាទ!

ដានី : ៧៥នឹង យ៉ាងម៉េចគេហៅពូទៅ?

ឈួង : ទៅធ្វើការនៅឃុំព្រះនេត្រព្រះ ជាមួយគេមេឃុំ អ្នកគេប្រជាជនព្រះនេត្រព្រះគេជម្លៀសចេញអស់ហើយ ។

ដានី : ធ្វើការនៅឃុំព្រះនេត្រព្រះ?

ឈួង : បាទ!

ដានី : កាលនឹងពូធ្វើអីទៅនៅឃុំព្រះនេត្រព្រះ?

ឈួង : កាលនៅឃុំព្រះនេត្រព្រះ គេឲ្យខ្ញុំក្តាប់យុវជន ម៉ាឃុំព្រះនេត្រព្រះ ។

ដានី : យុវជនឃុំ?

ឈួង : ហ្នឹង!

ដានី : គេឲ្យក្តាប់យុវជនឃុំនឹង កាលនឹងគេហៅអីគេទៅ គេហៅ?

ឈួង : គេហៅនែក! គេឲ្យក្តាប់យុវជន១៧មេសា ។

ដានី : មិនមែនកងចល័តទេ កាលនឹង?

ឈួង : អត់ទាន់មានកងចល័តទេ ។

ដានី : អត់ទាន់មានកងចល័តទេ?

ឈួង : ឲ្យក្តាប់យុវជន ១៧មេសា ។

ដានី : បាទ! នៅឃុំ ភូមិ ៗ តែពួក១៧មេសា អត់មានពួកប្រជាជនចាស់ ដែលអត់?

ឈួង : នោះឯង ពួកប្រជាជន១៧មេសានោះឯង អត់មានប្រជាជនចាស់ទេ ៗ នោះហើយពួកមូលដ្ឋាន ។

ដានី : ចុះ១៧មេសា កាលនឹងច្រើនអត់ ម៉ាឃុំ?

ឈួង : ច្រើន ប៉ុនវាភ្លេចកំណត់អស់ហើយ ដល់ដូចថាខ្ញុំគ្រប់គ្រងបានប្រជាជនក្នុងម៉ាភូមិដូចថាយុវជនមានប៉ុន្មាន ឲ្យឡើងមកនៅកន្លែងខ្ញុំ ។ ដល់នៅទៅដូចកន្លែងពេទ្យ គេត្រូវការយុវជនប៉ុន្មាននាក់ គេមកសុំខ្ញុំ ឲ្យចូលកន្លែងពេទ្យ យោធាគេត្រូវការប៉ុន្មាននាក់

គេមកសុំខ្ញុំចូលទៅ ខាងយោធា ខាងពាណិជ្ជត្រូវការប៉ុន្មាននាក់ គេសុំខ្ញុំមើលសំណាំទៅខាងពាណិជ្ជក៏រុញទៅ ពាណិជ្ជ ទៅអាណាសំណាំទៅពេទ្យក៏រុញទៅពេទ្យទៅ ទៅប៉ុននោះឯង ។

ដានី ៖ ចឹងយើងក្តាប់យុវជនចឹង ដល់ពេលគេមកដូចថាគេត្រូវជ្រើសរើសត្រូវចូលពេទ្យ ពូឲ្យចូលពេទ្យទៅពាណិជ្ជ ឲ្យទៅពាណិជ្ជ អ្នកធ្វើយោធាៗ?

ឈួង ៖ បាទៗ ដូចថិន ដូចអី ខ្ញុំបញ្ជូនខាងពាណិជ្ជ ។

ដានី ៖ ហើយកាលនឹងគណៈឃុំឈ្មោះអី?

ឈួង ៖ តាក្រុក ។

ដានី ៖ តាក្រុក គណៈឃុំ?

ឈួង ៖ បាទ!

ដានី ៖ ពីណាទៀត ដូចថាក្នុងជួរគណៈឃុំ?

ឈួង ៖ តាសន ។

ដានី ៖ តាក្រុក តាសន?

ឈួង ៖ ហើយនឹងតាជន ។

ដានី ៖ តាជន?

ឈួង ៖ បាទ!

ដានី ៖ ពូក្តាប់ក្នុងយុវជននឹង យើងក្នុងគណៈឃុំដែរអត់?

ឈួង ៖ បាទ! ក្នុងឃុំដែរ ប៉ុនដូចថាក្រោមក្របខ័ណ្ឌ យើងនៅតែមានសិទ្ធិដូចថាគ្រប់គ្រងយុវជនប៉ុននោះ ។

ដានី ៖ ចឹងដល់ពេលពូអ្នកក្តាប់ចឹង ដល់ពេលយើងបែងចែក កាលនឹងម៉ាឃុំនឹងពូមានដឹងប៉ុន្មាននាក់ នៅយុវជន កាលឃុំព្រះនេត្រព្រះ?

ឈួង ៖ អត់ដឹងចំនួនកាលនោះ ទេ!មុនកាលដែលធ្វើការដឹង ដល់នេះទៅវាក្លេចព្រោះម៉ាភូមិបាន៦ ៧នាក់ទៅៗ ភូមិមួយ៦-៧នាក់ទៅៗ ។ ដល់ហើយអ្នកដែលខ្ញុំយកទៅនោះ អត់មានឲ្យ ទៅចល័តទេ ។ អាអ្នកដែលមិនបានទៅវាទៅចល័តៗទៅតាមសហករណ៍ ចល័តឃុំ ចល័ត អីណានោះ ។

អ្នកជិតខាង ៖ ចល័តតំបន់ ។

ឈួង ៖ ហ្នឹងហើយ ។

ដានី ៈ ចឹងនៅក្នុងយុវជនឃុំធ្វើអីខ្លះទៅ?

ឈួង ៈ យុវជនឃុំអត់មានធ្វើអីទេ ដូចថាពេលដែលខ្ញុំត្រូវជញ្ជូនរបស់របរ នៅតាមឃុំដូចថា យើងជញ្ជូនពីផ្ទះមួយទៅផ្ទះមួយ អីវ៉ែអីវ៉ាន់នោះណា យើងនាំគ្នាជញ្ជូនទៅ អត់មានធ្វើអីទេ ។ ដល់ពេលគេស្នើទៅក៏ឲ្យទៅគេទៅ ។ រហូតដល់អស់ពីខ្លួនទៅ បានគេហៅខ្ញុំចូលចល័ត ។

ដានី ៈ រយៈពេលប៉ុន្មានទៅ បានពូក្តាប់នៅយុវជននឹង?

ឈួង ៈ រយៈ អូ!ខ្ញុំក្តាប់តាំងពីខែ៧រហូតដល់ខែ១ ។

ដានី ៈ ដល់ខែ១ ៧៦?

ឈួង ៈ បាទ! ដល់ខែ១ ៧៦នេះ បានគេឲ្យខ្ញុំរៀបចំលើកទំនប់កំប៉ោរ ។

ដានី ៈ ខែ១ ៧៦ នឹងពូផ្លាស់ចេញពីយុវជនហើយ មិនចឹង?

ឈួង ៈ បាទៗ ខាងតំបន់គេស្នើខ្ញុំយកទៅហើយ ឲ្យទៅនៅខាងតំបន់ ។

ដានី ៈ តំបន់ណា?

ឈួង ៈ នៅតំបន់៥ ។

ដានី ៈ តំបន់៥ ស្នើពូឲ្យទៅនៅ?

ឈួង ៈ ឲ្យទៅនៅដើម្បីរៀបចំសមរភូមិ លើកទំនប់ ជីកប្រឡាយ ក្នុងតំបន់ ។

ដានី ៈ កាលនោះគេស្នើទៅ ពូមានតួនាទីអី?

ឈួង ៈ ខ្ញុំជា គេហៅថារងៗពីតាវ៉ាល់ រងទៅ តួនាទីខ្ញុំដូចថាក្តាប់យុវជនក្នុងចល័តតំបន់៥ ប៉ុន្តែរងគេទេ រងពីតាវ៉ាល់ ។

ដានី ៈ អនុ គេហៅអនុ?

ឈួង ៈ បាទ!

ដានី ៈ អនុតាវ៉ាល់ៗ ក្តាប់ចល័តតំបន់៥?

ឈួង ៈ បាទ! ចល័តតំបន់៥ ។

ដានី ៈ ចឹងកាលក្នុងចល័តតំបន់៥នឹង តាវ៉ាល់ គាត់ធ្វើប្រធានចឹង?

ឈួង ៈ បាទ!

ដានី ៈ តាវ៉ាល់ប្រធាន ចុះអនុប្រធានមានប៉ុន្មាននាក់ទៅ?

ឈួង ៈ អត់ទេ មានតែខ្ញុំមួយនឹងឯង ។

ដានី ៈ តាវ៉ាល់?

ឈួង ៈ អត់ពីគាត់ ខ្ញុំ ការងារឯលើនៅលើគាត់ ការងារក្រោមនៅលើខ្ញុំ តែប៉ុននោះឯង ។

ដានី ៖ ចឹងកាលនោះចាប់ផ្ដើមរៀបចំធ្វើជាកងចល័តតំបន់នឹង នៅខែ១ឆ្នាំ៧៦?

ឈួន ៖ បាទ! រៀបចំលើកទំនប់កំពោរយើងនេះ ។

ដានី ៖ តាវ៉ាល់ គាត់ជាប្រធានចល័ត ហើយលោកពូជាអនុ?

ឈួន ៖ បាទ!

ដានី ៖ តែ២នាក់នោះ អត់មាន?

ឈួន ៖ បាទ! ២នាក់ ។

ដានី ៖ កាលនឹង គណៈតំបន់ គាត់ឈ្មោះអីគេ?

ឈួន ៖ ឈ្មោះ បង ០៧ ឈ្មោះគាត់ ឈ្មោះ តាហ៊ីង ។

ដានី ៖ បង០៧?

ឈួន ៖ បាទ!

ដានី ៖ ឈ្មោះគាត់ពេញឈ្មោះអីគេ?

ឈួន ៖ ឈ្មោះ ហ៊ីង ។

ដានី ៖ ឈ្មោះ ហ៊ីង ឈ្មោះបដិវត្ត ឈ្មោះជំនាន់ណា?

ឈួន ៖ អូ! ដឹង១ពីដើមគាត់ឈ្មោះអី អត់ដែលដឹងទេ ។

ដានី ៖ អត់ដែលមានឈ្មោះអីផ្សេងទៀតទេ?

ឈួន ៖ បាទ! ឮតែឈ្មោះ ហ៊ីង ចេះឯង ។ បើតាវ៉ាល់ ឈ្មោះមុនឈ្មោះ ហួន ។

ដានី ៖ ឈ្មោះ ហួន?

ឈួន ៖ បាទ!

ដានី ៖ ហួន ហ្នឹងឈ្មោះដើមគាត់?

ឈួន ៖ បាទ! ដល់គាត់ធ្វើខ្មែរក្រហម គាត់ដាក់ឈ្មោះវ៉ាល់ ។

ដានី ៖ ឈ្មោះវ៉ាល់ ពូអត់ដែលដូរឈ្មោះទេ?

ឈួន ៖ ទេ! ខ្ញុំមិនដែលដូរទេ ។

ដានី ៖ ចឹងតាហ៊ីង គាត់គណៈតំបន់ ហើយឈ្មោះលេខគាត់ ឈ្មោះ០៧?

ឈួន ៖ បាទ!

ដានី ៖ គណៈតំបន់៥ គាត់ចាប់ផ្ដើមគណៈតំបន់តាំងពីឆ្នាំណា?

ឈួន ៖ តាំងពីសន្តិភាពមកក៏ដឹងថាតាហ៊ីង គណៈតំបន់១ ។

ដានី ៖ អូ! ពេលឆ្នាំ៧៥នឹង?

ឈួង ៖ បាទ!

ដានី ៖ តាហ៊ឹង គាត់គណៈតំបន់ ចុះអនុដូចជាបន្ទាប់គាត់?

ឈួង ៖ អនុ មិនដឹងថានរណាជាអនុគាត់ ខ្ញុំ ព្រោះអានោះវាខ្លះថាអ្នកនេះ ខ្លះថាអ្នកនោះទៅ វាមិន ដឹងអ្នកណាពិតទេ ។

ដានី ៖ ចុះជៀល?

ឈួង ៖ ជៀល នោះ គាត់មកក្រោយទេ ជៀលនោះ កូនតាមូល សម្បត្តិទេ ។

ដានី ៖ បាទ! ជៀល កូនតាមូល សម្បត្តិ តាញ៉ឹមនោះ?

ឈួង ៖ ហ្នឹងហើយ តាញ៉ឹមកូនតាញ៉ឹម ។

ដានី ៖ ជៀល មកក្រោយ?

ឈួង ៖ ក្រោយ ។

ដានី ៖ ចុះ ខ្មៅៗស៊ីទេ ខ្មៅអេង អេង ខ្មៅ?

ឈួង ៖ អត់ស្គាល់ ។

ដានី ៖ អត់ស្គាល់?

ឈួង ៖ បាទ!

ដានី ៖ កូនតាញ៉ឹម កូនតាមូល សម្បត្តិ ។ ចុះអនុគាត់ផ្សេងទៀត ពួអត់ចាំ?

ឈួង ៖ អត់ៗចាំ ជៀល ខ្ញុំឃើញមុខមួយភ្លែតៗមិនបានសំណេះសំណាល បើដូចតាហ៊ឹង និងខ្ញុំ បានសំណេះសំណាលគ្នាច្រើនខែ ។

ដានី ៖ ចឹងពូតាហ៊ឹង គាត់ជាគណៈតំបន់៥ ចុះកន្លែងមន្ទីរតំបន់នៅកន្លែងណាទៅ?

ឈួង ៖ មន្ទីរតំបន់នៅកន្លែងមន្ទីរបក្សសព្វថ្ងៃ ។

ដានី ៖ នៅមន្ទីរបក្សសព្វថ្ងៃនៅស្វាយនឹង?

ឈួង ៖ បាទ! នោះឯង ។ កាលនោះគេហៅថាកន្លែងនយោបាយ ។

ដានី ៖ កាលនោះផ្ទះតាហ៊ឹង គាត់នៅណា?

ឈួង ៖ ផ្ទះគាត់នៅកៀនមន្ទីរបក្សនឹងឯង ។

ដានី ៖ ផ្ទះនៅមន្ទីរបក្ស?

ឈួង ៖ បាទ! នៅអែបនឹងម៉ាស៊ីនព្រហូត ។

ដានី ៖ ចុះផ្ទះគាត់មិនមែននៅខាងព្រះនេត្រព្រះយើង នៅខាងជប់ទេ?

ឈួង ៖ ទេ!

ដានី ៖ គាត់អត់មានមកនៅនឹង?

ឈួង ៖ ទេ! មិនដែលទេ ។

ដានី ៖ គាត់អត់មាននៅនឹង?

ឈួង ៖ អត់ទេ គាត់នៅតែស្វាយ ។

ដានី ៖ គាត់នៅតែស្វាយ?

ឈួង ៖ បាទ! នៅនេះ នៅតែតាមោង តាសំអាត គណៈស្រុក ។

ដានី ៖ តាមោង ហើយតាសំអាត គាត់?

ឈួង ៖ គណៈស្រុកនៅព្រះនេត្រព្រះ ។

ដានី ៖ គណៈស្រុកព្រះនេត្រព្រះ?

ឈួង ៖ បាទ!

ដានី ៖ ហ្នឹងផ្ទះគាត់នៅណា?

ឈួង ៖ ផ្ទះគាត់នៅផ្ទះអាអីនៅចុងភូមិយើង ចេញទៅៗជប់ អឺ!ចេញទៅជ្រាំ ផ្ទះអាស្តីឈ្មោះ អាធី អាទិញត្រាក់ទ័រ អាផ្ទះនៅខាងនោះផ្លូវ ។

ហ៊ុយ ៖ អូ! ផ្ទះអ្នក.... (ស្តាប់មិនបាន) ។

ឈួង ៖ នោះហើយដឹង ។

ហ៊ុយ ៖ អាផ្ទះដែល ។

ឈួង ៖ ខាងជើងវត្តគោកថៃ(ស្តាប់មិនច្បាស់) ។ ចេញពីផ្ទះនោះទៅតិចទៅវា ។

ហ៊ុយ ៖ ផ្ទះអាសាលី?

ឈួង ៖ អូ! អាសាលីនោះឯង ផ្ទះសាលី ។

ដានី ៖ ចឹងតាមោង ហើយតាសំអាត គាត់នៅជិតគ្នានឹង?

ឈួង ៖ បាទ!

ដានី ៖ ហើយចុះតាវ៉ាល់គាត់នៅណា?

ឈួង ៖ តាវ៉ាល់ គាត់នៅអាកន្លែងបៀតមាត់ស្រះៗជប់យើង កន្លែងពីដើមមិញអាហេងវាធ្វើស្ថី ប្រៃសណីយ៍នៅត្រង់នោះ ផ្ទះមេព្រៃចាស់ពីដើម ។

ដានី ៖ ជិតផ្ទះមេព្រៃចាស់?

ឈួង ៖ ជិតអី នៅនឹងផ្ទះមេព្រៃចាស់នឹង ។

ដានី ៖ កន្លែងជប់នឹងម៉ង?

ឈួង ៖ បាទ!

ដានី ៖ ចុះពូនៅណា?

ឈួង ៖ ខ្ញុំចល័តរហូត ផ្ទះខ្ញុំនៅប៉ុស្ដិ៍ចាស់ឯងនេះ ។

ដានី ៖ នៅប៉ុស្ដិ៍?

ឈួង ៖ បាទ! ខ្ញុំនៅនឹងផ្ទះខ្លួន ។

ដានី ៖ ប៉ុស្ដិ៍ចាស់ ចុះតាវ៉ាល់ គាត់អ្នកស្រុកកំណើតនៅណាដែរ?

ឈួង ៖ ទេ! មិនដឹងជាស្រុកកំណើតគាត់នៅណា ខ្លះថានៅតាកែវ ខ្លះថានៅណា ខ្ញុំក៏មិនហ៊ានសួរគាត់ដែរ ព្រោះគាត់អ្នកធំដែរ ក៏ខ្ញុំក៏មិនដឹងថាគាត់នៅណាពិតប្រាកដដែរណា ។

ដានី ៖ គាត់រៀនម៉េចដែរ កាលនឹងកាលពី?

ឈួង ៖ ស្គមដូចខ្ញុំចេះឯង រៀនខ្ញុំនិងតាវ៉ាល់ ដើរចល័តច្រឡំ ។

ដានី ៖ ច្រឡំ?

ឈួង ៖ នោះហើយ ឃើញតែខ្ញុំទៅ ។

ដានី ៖ ស្គមដូចពូចឹង?

ឈួង ៖ បាទ! ស្គមដូចគ្នា កំពស់ដូចគ្នា ។

ដានី ៖ ចុះសក់គាត់អី?

ឈួង ៖ មិនសូវខុសគ្នាទេ ។

ដានី ៖ សំបុរ សំបកអីក៏ប្រហែលគ្នាដែរ?

ឈួង ៖ បាទ! ប៉ុនគាត់មុខស្រួចជាងខ្ញុំតិច ។ បើដើរយប់ចល័តច្រឡំតែខ្ញុំរហូត ផ្ដើលតាវ៉ាល់ ។

ដានី ៖ ប្រពន្ធគាត់ឈ្មោះអី?

ឈួង ៖ ប្រពន្ធគាត់ឈ្មោះ មើលភ្លេចបាត់ហើយ គិន ឈ្មោះនាង គិន ។ កូនមួយដាក់ឈ្មោះអាដួង ។

ដានី ៖ គាត់នៅណាឥឡូវ?

ឈួង ៖ គិន នៅមុខឈ្នាង ។

ដានី ៖ នៅភូមិមុខឈ្នាង ។

ឈួង ៖ បាទ! គិន នៅសព្វថ្ងៃ ។

ដានី ៖ មុខឈ្នាង នៅស្ពានស្រែងនឹងដែរ?

ឈួង ៖ នឹងហើយ មុខឈ្នាងស្ពានស្រែង ។

ដានី ៖ ទៅកន្លែងស្ពានស្រែងសួរគេៗស្គាល់ហើយ?

ឈួន ៖ បាទ! ទៅរកទៅនឹងរូបទៅៗជួបអាមេតៗ ហៅអាសំរេចមក សួរអាសំរេចមកស្គាល់ទាំងអស់ៗ ព្រោះអាសំរេច និងខ្ញុំ វានៅជាមួយគ្នារហូតដែលនោះៗ

ដានី ៖ ចុះលោកពូ ដល់ពេលចឹងទៅ លោកពូនៅប៉ុស្តិ៍ចាស់ នៅជាមួយប្រពន្ធដែរ?

ឈួន ៖ ទេ! ប្រពន្ធខ្ញុំចល័តបែកទៅផ្សេងៗ

ដានី ៖ ចឹង?

ឈួន ៖ ប្រពន្ធខ្ញុំគេធ្វើខាងពេទ្យសង្គមកិច្ច ស្មោរថ្នាំខ្មែរឲ្យអ្នកជម្ងឺៗ

ដានី ៖ ចឹងអត់នៅជុំគ្នាទេ?

ឈួន ៖ អត់ទេ អត់ជុំទេៗ

ដានី ៖ ចឹងយើងធ្វើការយើងធ្វើផ្សេងទៅ ប្រពន្ធផ្សេងទៅ?

ឈួន ៖ បាទ!

ដានី ៖ អត់ដូចនៅជុំគ្នាដូចឥឡូវ យើង?

ឈួន ៖ អត់ទេៗ

ដានី ៖ ម៉េចចឹង ដូចពូមានតួនាទីអីធំដែរ យើងអត់ឲ្យប្រពន្ធនៅជុំ?

ឈួន ៖ វាមិនដឹងថាយកទៅទុកត្រង់ណា យើងអត់ទាន់មានកន្លែងទិសដៅកំណត់ គិចគេឲ្យទៅនៅត្រង់នេះ គិចគេឲ្យទៅនៅនោះៗ

ដានី ៖ ចុះពូដែលគណៈដែលយើងខែ១ ឆ្នាំ៧៦នឹង ពេលនឹងដូចថាគេតែងតាំងពូឲ្យទៅជាអនុប្រធានចល័តតំបន់អីចឹង កាលនឹងតែងតាំងចេញមកពីណាមក?

ឈួន ៖ ក្នាឯងនឹងឯង មានត្រង់ណា គ្រាន់ថាហៅទៅគណៈតំបន់នឹងឯង គាត់អ្នករៀបចំការងារសមរភូមិផ្ទាល់ គឺតួនាទីនៅលើឈួនឯងគ្រប់គ្រង អត់ពីតាវ៉ាល់ទៅ ចេះឯងៗ ហើយពេល តាវ៉ាល់នៅ តាវ៉ាល់គាត់អ្នកគ្រប់គ្រងទៅ ពេលគាត់ចេញ គឺយើងៗ

ដានី ៖ អានឹងគេហៅថាគណៈបញ្ជាការសមរភូមិតំបន់៥?

ឈួន ៖ បាទៗ ៗ

ដានី ៖ អានឹង ប៉ុន្តែវាជាកងចល័ត?

ឈួន ៖ បាទ!

ដានី ៖ ប៉ុន្តែវាជាទូទៅគេហៅថាគណៈបញ្ជាការសមរភូមិ?

ឈួន ៖ គណៈបញ្ជាការសមរភូមិក្នុងតំបន់ៗ

ដានី ៖ គណៈបញ្ជាការសមរភូមិនឹង បានន័យថាយើងធ្វើការងារ ឬយើងឡើងវិញ អានឹង ព្រោះបើ ចាំពាក្យបច្ចេកទេសកងទ័ព បើគណៈសមរភូមិពេលដែលយើងវិញ យើងបញ្ជាទ័ព?

ឈួង ៖ អត់ទេ បញ្ជាការសមរភូមិនេះ ពួកអ្នកស៊ើបការណ៍ ពួកអ្នករៀបចំមុនវិញ រៀបចំរួចដឹងថា ត្រង់នេះខ្លាំងធូរដៃយើងអាចចូលបុកត្រង់នេះ ត្រង់នោះ បានបញ្ជាការសមរភូមិនោះឯង បញ្ជាទៅមេបញ្ជាការកាន់ទ័ពនៅសមរភូមិឲ្យទៅវិញ ។

ដានី ៖ ចុះអានឹងពូមានតួនាទីនឹង?

ឈួង ៖ បាទ!

ដានី ៖ ប៉ុន្តែយើងបែកឆ្នាំ៧៥ ហើយ ដល់៧៦ យើងមានសមរភូមិ ណាវិញទៀត?

ឈួង ៖ ទេ! អានេះក្នុងនាមដែលគេនិយាយពីទ័ព បើនិយាយកងទ័ពដូចថាយើងក្តាប់ចល័ត ដូចតែ យើងក្តាប់ទ័ព ។ ទៅវិញសមរភូមិភ្នំកំបោរ ដូចទំនប់ប្រឡាយនេះ គេហៅសមរភូមិ ។ យើង ប្រយុទ្ធនៅសមរភូមិទី១ នៅទំនប់កំបោរ ប៉ុន្មានខែឲ្យដាច់ៗយើងប្តេជ្ញា ។ ហើយយើងដឹក នាំកម្លាំងធ្វើម៉េចឲ្យរួច អ្នកឯងធ្វើមិនរួច គឺមិនបាន នឹងឯងវាទៅជាបេះ ។ វាដូចតែគ្នាតែ នឹងមេបញ្ជាការទ័ពនឹងឯង ។

ដានី ៖ បាទៗ ដូចថាយើងពេលនឹងគេហៅគណៈបញ្ជាការសមរភូមិ ដូចថាពេលដែលយើងត្រូវដាក់ ផែនការលើកទំនប់ស្អីមួយចឹង ពូរៀបចំផែនការយើងធ្វើម៉េចវិញដាច់ ៣ខែវិញឲ្យដាច់ ត្រូវ ធ្វើឲ្យហើយ ។ ចឹងត្រូវរៀបចំយ៉ាងម៉េច បញ្ជាទៅអ្នកដូចថាតាមកងតូច តាមកងធំអីចឹង ។

ឈួង ៖ បាទ! តាមវរៈសេនាតូច វរៈសេនាធំវា ។

ដានី ៖ បាទ! ឲ្យរៀបចំធ្វើម៉េចឲ្យហើយក្នុងរយៈពេល៣ខែ?

ឈួង ៖ បាទ!

ដានី ៖ អានឹងបញ្ជាចេញមកពីពូមក ឬក៏ចេញមកពីតាវ៉ាល់?

ឈួង ៖ ចេញមកពីតាវ៉ាល់ ។

ដានី ៖ ចេញពីតាវ៉ាល់?

ឈួង ៖ នោះហើយ ។

ដានី ៖ ចឹង ប៉ុន្តែតាវ៉ាល់ចេញមកពីខាងណាទៀត?

ឈួន ៖ តាវ៉ាល់ចេះ ចាំមើលនិយាយទៅវាមានចេះតែវែងឆ្ងាយ ។ ព្រោះមេបញ្ជាការដូចតាហ៊ីន គាត់ចល័តប្រធានធំ គណៈតំបន់ គាត់ថាឥឡូវទិសដៅទំនប់កំពោរនេះ យើងរើសម្រេចឲ្យរួចក្នុងរយៈពេល៣ខែកន្លះឬក៏៤ខែ តើមិត្តទាំងអស់គ្នាហ៊ានប្តេជ្ញាថា ប៉ុន្មានខែរួច ។ ហើយយើងម្នាក់ៗចង់បានគុណសម្បត្តិ ដូចតាវ៉ាល់ ដូចអីគាត់ចង់បានគុណសម្បត្តិដូចគាត់ដែរ ដល់គាត់ប្តេជ្ញាថាវើ៣ខែឲ្យរួច ។ ដល់ទិសដៅគេថា៤ខែ គ្រាន់គាត់សម្រេចថា៣ខែគឺឲ្យរួច ។ ដើម្បីយកដែលស្នាដៃ ។ ហើយប៉ុនក្នុងការដែលសម្រេច៣ខែនេះរួច កម្លាំងគឺយើងប្រមូលធ្វើម៉េចឲ្យបានយកឲ្យរួចត្រូវទៅតាមផែនការរបស់យើង ។ បើសិនជាមិនគ្រប់ផែនការទេ វាត្រូវតែ៤ខែ យើងដូចថាមេបញ្ជាការខ្សោយ ដល់ហើយគេចង់យកអាខ្លាំង បានប្រជាជនវាត្រូវទទួលការលំបាកនោះខ្លាំងដែរ ។

ដានី ៖ ចឹងតាហ៊ីង គាត់ដាក់បញ្ជា ដូចថាពេល អានឹងពេកប្រជុំ?

ឈួន ៖ បាទ! ពេលប្រជុំ ។

ដានី ៖ ពេលប្រជុំ គាត់ប្រាប់មក ដូចថាតាវ៉ាល់គាត់អ្នកទទួលបញ្ជាការសមរភូមិនឹង ៣-៤ខែចឹង ហើយតាវ៉ាល់ ពេលនឹងគាត់ពិភាក្សាជាមួយតាហ៊ុង តាអី តែ៣ខែទៅ៤ខែ អានឹង ។

ឈួន ៖ បាទ! នោះហើយ ដល់ពិភាក្សារួចបានដាក់ដូចថាយើងសម្រេចថា៤ខែរួចហើយ ក៏យើងសម្រេចសួរទៅមេបញ្ជាការសមរភូមិផ្ទាល់ ដូចថាអ្នកក្តាប់ចល័តផ្ទាល់ តើយើងអាចសម្រេចបាន ឬមិនបាន ។

ដានី ៖ កាលនឹងពេលប្រជុំនឹង ពូដូចតាវ៉ាល់ តាហ៊ីងនឹងប្រជុំជាមួយគ្នា?

ឈួន ៖ បាទ!

ដានី ៖ ពីណាទៀតប្រជុំជាមួយគ្នា?

ឈួន ៖ ពូក មានតាស្រួច ហើយក្មេងឈ្មោះគាត់ តាឡុំៗគេហៅតាយៀកៗនៅអារក្សបាក់-ក ។

ដានី ៖ តាឡុំ?

ឈួន ៖ នោះឯង ។

ដានី ៖ តាឡុំ តាស្រួច?

ឈួន ៖ ហើយនោះ តាអីទៀតនៅខាង ខ្ញុំវាក្មេងឈ្មោះគេទៅ ។

ដានី ៖ តាឡុំ គាត់ធ្វើអីគេ?

ឈួន ៖ តាឡុំ គាត់មេបញ្ញាការក្នុងការដ្ឋាន១ក្នុងចល័តតំបន់ដែរ ប៉ុនអានោះការដ្ឋានខាងស្រែខាងអីណា ។

ដានី ៖ មេបញ្ញាការការដ្ឋាន?

ឈួន ៖ ហ្នឹងហើយ ការដ្ឋាន អារក្សបាក់កយើង ។

ដានី ៖ ខាងស្រែនឹងរបស់តំបន់ដែរ?

ឈួន ៖ បាទ!

ដានី ៖ ចុះតាស្រួច?

ឈួន ៖ តាស្រួច ក៏ខាងស្រែដែរ ប៉ុនលើកទំនប់ ប្រឡាយធ្វើស្រែនៅខាងសាលាក្រហម ត្រូវផ្លូវផ្គត់ដើរអីនោះឯង កូនចៅតាស្រួច ។ ស្រួចងាប់ហើយដឹង បាត់មិនដឹង ស្រួចនោះក្មេងដូចខ្ញុំ ប៉ុនគេហៅតែតា១ ។

ដានី ៖ ប៉ុន្តែតាស្រួចនៅខាងណា ខាងសាលាក្រហម?

ឈួន ៖ សាលាក្រហម ។

ដានី ៖ សាលាក្រហម?

ឈួន ៖ បាទ! សាលាក្រហម ការដ្ឋានតំបន់ដែរ ។

ដានី ៖ អានឹង ប៉ុន្តែទទួលទិសតែខាងនឹងទេ?

ឈួន ៖ បាទ!

ដានី ៖ ប៉ុន្តែយើងបែកចែកគ្នាដាច់កាលនឹងដូចថាខាងតាវ៉ាល់ តាអីផេង ខាងទទួលកង ចល័ត?

ឈួន ៖ បាទ! អានេះចេះ ពេលប្រជុំ គេដាក់ដូចថាកងចល័តលើកទំនប់៤ខែ ឧទាហរណ៍៤ខែចឹងណា ហើយខាងការដ្ឋាន ធ្វើស្រែធ្វើភ្លឺ គេសម្រេចប៉ុន្មានខែជាស្ថាពរគេដាក់ដូចថា៤ខែ ។ ម្លោះហើយ គេឲ្យគណៈបញ្ញាការទាំងអស់ឡើងប្តេជ្ញា តើយើងសម្រេចប៉ុន្មានខែបានស្រេច ។ ដល់គេដាក់ឲ្យយើង៤ខែ យើងថា៣ខែ អានេះគេថា៣ខែ ខ្លះគេថា៣ខែកន្លះទៅតាមបញ្ញាការរៀងខ្លួន ដឹងខ្លួន ។

ដានី ៖ ប្រជុំតែប៉ុននឹងទេ តែតាហ៊ឹង តាវ៉ាល់ ពូ តាឡុំ?

ឈួន ៖ តាស្រួច ។

ដានី ៖ ហើយនឹងតាស្រួច?

ឈួន ៖ បាទ! ហើយឈ្មោះទោមួយទៀត ខ្ញុំភ្លេច១រកនឹកមិនឃើញ យូរ១បាននឹកឃើញ នោះគាត់នៅការដ្ឋានខាងដាំកប្បាស ។

ដានី ៖ ខាងដាំកប្បាស?

ឈួង ៖ បាទ! ខាងដាំកប្បាស ខាងពោត ខាងសណ្ដែកដី នោះខាងអ្នកគ្រូៗយើងនៅប៉ុស្ដិ៍ចាស់ គាត់នៅជាមួយគ្រូសម្បត្តិ។

ហ៊ុយ ៖ សុខ សម្បត្តិ?

ឈួង ៖ នោះហើយ។

ហ៊ុយ ៖ សុខ សម្បត្តិនាយកសាលាកណ្ដាល។

ឈួង ៖ នោះហើយ។

ដានី ៖ ខាងដាំកប្បាស។ ចុះគណៈតំបន់មានតែតាហ៊ឹងមួយ គាត់ចូលប្រជុំ?

ឈួង ៖ បាទ! មានតែតាហ៊ឹងមួយ។

ដានី ៖ អត់មានពីណា?

ឈួង ៖ អត់មានរង អត់មានឃើញរងឃើញអីទេ ប្រជុំប៉ុន្មានសារ ឃើញតែគាត់មួយ។ គាត់នោះ និយាយពិរោះណាស់ យូរទៅពិរោះទៅៗ។

ដានី ៖ ពីណាគេ?

ឈួង ៖ តាហ៊ឹង។

ដានី ៖ តាហ៊ឹង?

ឈួង ៖ កំពូលអ្នកចេះ មិនមែនអ្នកល្ងង់ណា។

ដានី ៖ គាត់មកពីណាមក?

ឈួង ៖ ថាមកពីតាកែវដែរ។

ដានី ៖ តែគាត់អី! បានន័យថាគាត់អ្នកចេះរៀនសូត្រមកពីណាមក?

ឈួង ៖ ទេ! មិនដឹងចេះរៀនសូត្រមកពីខាងណាមក ប៉ុនគាត់និយាយនោះ គេគិតអ្នកចេះ មិនមែនអ្នកល្ងង់ទេ អ្នកល្ងង់និយាយផ្សេង ព្រោះនិស្សិតបញ្ញវ័ន្តអី ដែលបញ្ជូនមកពីភ្នំពេញ ចុះចូលក្នុងចល័តនោះ គាត់ហៅទៅប្រជុំទាំងអស់។

ដានី ៖ គាត់ហៅប្រជុំ?

ឈួង ៖ អឺ! ឲ្យតែពួកបញ្ញវ័ន្តចុះមក គាត់ហៅទៅប្រជុំ គាត់និយាយ ខ្ញុំស្ដាប់ទៅពិរោះណាស់ គេអ្នកចេះៗនិយាយ។

ដានី ៖ ចុះពេលដែលប្រជុំនឹង គាត់ថាគាត់មានទទួលផែនការមកពីណាទៀត ឬក៏គាត់រៀបចំផែនការខ្លួនគាត់ ដូចថាពេលលើកទំនប់ ពេល?

ឈួន ៖ ទេ! មិនដឹងទេ អានោះអត់ដឹងទេ ចេញពីខ្លួនគាត់ទៅបណ្តោយ ។

ដានី ៖ គាត់អត់មានថាអីអន្តការ ឬខាងមជ្ឈិម ឬក៏ខាងណាមក?

ឈួន ៖ អត់ទេៗ ចេញពីគាត់តែម្តង ។

ដានី ៖ ចេញពីគាត់?

ឈួន ៖ នោះហើយ ចេញពីតំបន់ ។

ដានី ៖ ចុះពីខាងភូមិភាគមក ដូចជាតាមូល សម្បត្តិ តាញឹមអី គាត់មានដែលចូលប្រជុំជាមួយ?

ឈួន ៖ អត់ទេ ពេលភូមិភាគ គេចង់ប្រជុំ គេប្រជុំគណៈតំបន់ គេហៅគណៈតំបន់ប្រជុំកន្លែងគេ ហើយតូចតាចដូចយើងចេះអត់ដែរដឹង ។

ដានី ៖ អត់ដែរ?

ឈួន ៖ បាទ! អត់ដែលដឹង ។

ដានី ៖ ប៉ុន្តែ គាត់ដែលចុះមកប្រជុំអី?

ឈួន ៖ អត់ទេ អត់ដែលចុះទេ ។

ដានី ៖ អូ! អត់ដែរមកទេ?

ឈួន ៖ នោះ ។

ដានី ៖ បាទ! អឺ!ចឹងពូដូចការចាប់ផ្តើមដឹបូងពីឆ្នាំ៧៦ ពេលពូទទួលឋានៈជាអនុបញ្ញាការអីនឹង កាលនឹងយើងចាប់ផ្តើមដឹបូងទំនប់ណាដែរ?

ឈួន ៖ ទំនប់កំបោរ ។

ដានី ៖ ទំនប់កំបោរ ពីណាទៅណា កំបោរ?

ឈួន ៖ ពីកំបោរមកភ្នំស្រេះ ។

ដានី ៖ ពីកំបោរមកភ្នំស្រេះ?

ឈួន ៖ បាទ!

ដានី ៖ ប្រវែងប៉ុន្មាន?

ឈួន ៖ ១៣គីឡូ ។

ដានី ៖ ១៣គីឡូ?

ឈួន ៖ បាទ!

ដានី ៖ អានឹងលើកប៉ុន្មាន?

ឈួន ៖ លើក៣ខែរួច ។

ដានី ៖ ១៣គីឡូពីកំបោរមកស្រែះនឹង លើកទទឹងប៉ុន្មាន កំពស់ប៉ុន្មានទៅ?

ឈួង ៖ ខ្នង៥ម៉ែត្រ បាត១០ម៉ែត្រ ។

ដានី ៖ ខ្នង៥ម៉ែត្រ ដល់បាត១០ម៉ែត្រ?

ឈួង ៖ បាទ!

ដានី ៖ អានឹងពីតាហ៊ីង គាត់ដាក់ផែនការមកដែរ មកដឹបូងដូចតាវ៉ាល់ ដូចពូ ជាអ្នកផ្តើមគំនិត?

ឈួង ៖ ទេ! គាត់ដាក់ឲ្យលើកទំនប់ ប៉ុនការបច្ចេកទេសយើងរៀបចំ យើងរៀប២នាក់តាវ៉ាល់ ។

ដានី ៖ រៀប២នាក់តាវ៉ាល់?

ឈួង ៖ នោះឯង ។

ដានី ៖ ប៉ុន្តែកន្លែង ដូចថាយើងជ្រើសរើសកន្លែងពីកំបោរមកស្រែះនឹង តាហ៊ីងគាត់ដាក់ផែនការត្រូវលើកពីកំបោរមកស្រែះ ឬក៏តាវ៉ាល់ហើយពូជាអ្នក ជ្រើសទីតាំង?

ឈួង ៖ តាហ៊ីង។ គាត់ដាក់ថាចាប់ពីកំបោរមកស្រែះ គឺធ្វើម៉េចឲ្យចំវត្តស្រែះ គេនិយាយយកទិសដៅឲ្យចំវត្តស្រែះ គេនិយាយយក ទិសដៅឲ្យចមវត្តស្រែះ ។ ចេញពីភ្នំកំបោរមកឲ្យចំស្រែះនឹងក៏នាំគ្នាគំរង់ ។ ខ្ញុំមុនដឹបូងខ្ញុំគំរង់ខុសពីដឹបូង បានដកម៉ាសារទៀត ក្រោយមកខ្ញុំហៅអ្នកភូមិកណ្តាលទៅនៅជាមួយខ្ញុំ ប៉ុន្មាននាក់ ពួកអាឃួន ពួកអឺអាបូរី អាអួង ពួកអាចន ពួកអឺហៅជាមួយខ្ញុំ ពួកតាវ៉ាន់ អាឆៃ ខ្ញុំហៅទៅនោះ ។ ពួកនោះវាមានរទេះក្របីធំៗសម្រាប់ដឹកឫស្សី ។ ហើយពួកឃុន ពួកអឺ ។

ដានី ៖ ដល់ពេលពូគំរង់ចឹងហើយ ពេលខ្នង៥ម៉ែត្រ បាត១០ម៉ែត្រ?

ឈួង ៖ បាត១០ ។

ដានី ៖ បាត១០ កំពស់ប៉ុន្មាន?

ឈួង ៖ បាទ! កំពស់២ម៉ែត្រ តាមសភាពទឹក ។

ដានី ៖ ចឹងយើងប្រើកម្លាំងប៉ុន្មានដើម្បីលើក៣ខែឲ្យហើយ?

ឈួង ៖ កម្លាំងកាលនោះ ការដែលខ្ញុំសរុបកម្លាំងនោះវា៦៥០០នាក់ ។

ដានី ៖ ៦៥០០នាក់?

ឈួង ៖ បាទ!

ដានី ៖ ១៣គីឡូ ។ រយៈពេល៣ខែនោះ?

ឈួង ៖ បាទ!

ដានី ៖ ហើយអានឹងបន្ទាប់ពី ។ ចឹងបន្ទាប់ពីចប់ពីទំនប់កំបោរនឹងហើយយ៉ាងម៉េចទៀត?

ឈួន :	អត់ទាន់ចប់ទេ ចាំមើលបានលើកទំនប់កំបោរបានពាក់កណ្តាលនេះ ឲ្យលើកពីស្មាច់ ពីចារ គោកទឹម មកទាំងការទៀត។ អានោះ ១៨គីឡូ។ បានគាវ៉ាល់ដកខ្ញុំចេញពីកំបោរនេះ ឲ្យរៀបចំនៅនោះ គាត់នៅនេះ ខ្ញុំនៅនោះ។

ដានី :	នៅណាទៅ នៅចារគោកទឹម?

ឈួន :	គោករំចេក ទំនប់គោករំចេក។

ដានី :	គោករំចេក ទំនប់គោករំចេក?

ឈួន :	បាទៗ។

ដានី :	យ៉ាងម៉េចទៅទំនប់គោករំចេក?

ឈួន :	នៅគោករំចេក វាបណ្តោយ១៨គីឡូ ប៉ុនកម្លាំងមានតែ៤០០០នាក់។ មាន៤៥០០ ហើយអាសានីពាគ្រឿង អាឈូស សានីឈូសពាគ្រឿង។ ហើយគាត់ហៅខ្ញុំឲ្យប្តេជ្ញា ៣ខែ ឲ្យរួចដូចគ្នា។

ដានី :	ម៉េចទៅ ប្តេជ្ញាអត់?

ឈួន :	ទេ! ខ្ញុំមិនហ៊ានប្តេជ្ញាទេ ខ្ញុំអត់ហ៊ានប្តេជ្ញាព្រោះកម្លាំងតិច បើកម្លាំងច្រើនខ្ញុំហ៊ាន ដល់ហើយរួចក្រោយគេ មិនរួចមុន។

ដានី :	រួចក្រោយ៣ខែ?

ឈួន :	បាទ!

ដានី :	១៨គីឡូ?

ឈួន :	បាទ!

ដានី :	ខ្ពង់៥ម៉ែត្រ បាត១០ម៉ែត្រដូចគ្នា កំពស់២ម៉ែត្រដូចគ្នា?

ឈួន :	បាទ! ដូចគ្នា។

ដានី :	ពីណានឹង ពីគោករំចេក?

ឈួន :	ពីគោករំចេក។

ដានី :	ទៅណា?

ឈួន :	ទេ! និយាយពីដើមខាងកើតពីចារ គោកទឹម។

ដានី :	បាទ! ពីចារ គោកទឹម។

ឈួន :	ចារ គោកទឹមរហូតដល់ទាំងកាំ។

ដានី :	ដល់ទៀនកាំ?

ឈួន ៖ បាទ!

ដានី ៖ តែក្នុងឃុំគោករវេក?

ឈួន ៖ គោករវេក នៅខាងស្រុកភ្នំស្រុក ។

ដានី ៖ ចុះលើកប៉ុន្មានខែអានឹង ពីខែប៉ុន្មានដល់ខែប៉ុន្មាន?

ឈួន ៖ លើក៤ខែដាង ។

ដានី ៖ ៤ខែដាង?

ឈួន ៖ បាទ!

ដានី ៖ ពីឆ្នាំណាមក?

ឈួន ៖ លើកឆ្នាំជំណាលគ្នានឹងឯង ជំណាលគ្នានឹងទំនប់កំបោរនោះឯង មុនក្រោយខុសគ្នាម៉ាខែកន្លះ ។

ដានី ៖ ម៉ាខែកន្លះ?

ឈួន ៖ បាទ!

ដានី ៖ ចឹងចប់ៗថ្ងៃណាទៅ?

ឈួន ៖ ដល់ថ្ងៃចប់នេះអត់ដឹងដែរ ។

ដានី ៖ អត់ដឹងដែរ?

ឈួន ៖ បាទ! ព្រោះខ្ញុំលើកមិនទាន់ចប់ផង គេទុកអាសានីឲ្យនង្វើយណា ។ ទុកអាសានីឲ្យបង្វើយដកកម្លាំងពួកខ្ញុំទាំងអស់ ទាំងកម្លាំងកំបោរ តាំងកម្លាំងពួកខ្ញុំនេះ ឲ្យសំរុងជួយដាំកប្បាសនៅភ្នំកង់វ៉ា ។

ដានី ៖ នៅភ្នំកង់វ៉ា?

ឈួន ៖ បាទ! ទៅធ្វើចំការកប្បាសម៉ាចំនួន ។

ដានី ៖ ដកទៅនឹងឆ្នាំណា ដកទៅចំការកប្បាស ខែប៉ុន្មានទៅ ឆ្នាំណា ខែប៉ុន្មាន?

ឈួន ៖ ទៅមើលបើមិនខែ៩ ខែ១០ ។

ដានី ៖ ខែ៩ ខែ១០ ឆ្នាំ?

ឈួន ៖ ឆ្នាំ៧៦នោះឯង ។

ដានី ៖ ៧៦ដកកម្លាំងទាំងអស់ម៉ង់ទាំងកំបោរ ពីកំបោរនិងគោករវេក?

ឈួន ៖ បាទ!

ដានី ៖ គោករវេកទៅដាំកប្បាសនៅ?

ឈួន ៖ ភ្នំកនវ៉ា ។

ដានី ៖ ភ្នំកនវ៉ានៅណា?

ឈួន ៖ ភ្នំកនវ៉ាខាងជើងស្វាយ ។

ដានី ៖ បាទ?

ឈួន ៖ ខាងជើងស្វាយ ។

ដានី ៖ ខាងជើងស្វាយ?

ឈួន ៖ បាទ! ខាងជើងស្វាយ ។

ដានី ៖ កប្បាសច្រើន ដកកម្ទាំងទៅ បើសរុបទៅ ពូថាមិញ?

ឈួន ៖ ច្រើនៗ ។

ដានី ៖ ម៉ឺននាក់?

ឈួន ៖ ម៉ឺននាក់ជាង ដីរាប់ហិចតាដែរ ។

ដានី ៖ ដាំរយៈពេលប៉ុន្មានទៅនៅនោះ?

ឈួន ៖ ទៅដាំប្រហែលម៉ាខែជាងដាំរួច ។

ដានី ៖ បាទ! ដាំរួចម៉ាខែជាង?

ឈួន ៖ បាទ!

ដានី ៖ ដល់ពេលរួចទៅធ្វើម៉េចទៀតទៅ?

ឈួន ៖ ដល់រួចទៅ បានដកកម្ទាំង ចូលតាមកន្លែងសមរភូមិក្នុងគោករំចេក ប៉ុនដកកម្ទាំងនោះ ដកយកតែកម្ទាំងចាស់ដែរណា កម្ទាំងចាស់ៗ វ៉ៃយកណ្ដាលឲ្យបិទអូរស្នាច់ ។

ដានី ៖ បិទអូរស្នាច់ម៉េច?

ឈួន ៖ បិទកាត់អូរនោះ ទំនប់កាត់អូរ ។

ដានី ៖ ធ្វើទំនប់កាត់អូរមួយទៀត?

ឈួន ៖ បាទ! កាត់អូរស្នាច់នេះ ព្រោះទំនប់ដែលលើកនោះ វាចំវាមានអូរនៅចំយើងលើកៗអា អត់អូរសិន ដល់អាមានអូរយើងទុកចោល ។ ដល់លើកអាអត់អូររួចហើយនេះ អាឡែងដាំ កប្បាស ដកពីដាំកប្បាសវិញបានឲ្យចូលកម្ទាំងលើកបិទអូរៗទាំងកាំនេះមួយ អូរនេះមួយ អូរ២ដកបិទទៅ ។

ដានី ៖ ដកបិទហើយម៉េចទៀតទៅ?

ឈួន ៖ បាទ! ដល់ក្រោយមកបានគេដកធ្វើនោះទៅ បានគេឲ្យខ្ញុំនេះទៅរៀបចំអាងត្រពាំងថ្ម ។

ដានី ៖ ពេលណាដែលទៅរៀបចំអាងត្រពាំងថ្ម?

ឈួង ៖ ទៅក្នុងខែ១១ ស្រូវចេញ ។

ហ៊ុយ ៖ ស្រូវចេញខែ១១ ខែ១២ ។

ឈួង ៖ បាទៗ ស្រូវចេញខែ១២នឹងឯង ខែ១២វាស្រូវមិនទាន់នេះទេ វាចូលដំណើរខែ១០ ខែ ១១នោះឯង ។

ដានី ៖ ខែ១១ ១២ ៧៦នឹង?

ឈួង ៖ បាទ!

ដានី ៖ ៧៦យ៉ាងម៉េចទៅពូ?

ឈួង ៖ បាទ! ដល់ទៅរៀបចំទំនប់កំពោរនេះ ដូចថាខ្ញុំអាងត្រពាំងថ្មនេះ ខ្ញុំជាបញ្ហាការសមរភូមិ គេឲ្យខ្ញុំទៅត្រួសត្រាយមុន ។

ដានី ៖ ទៅត្រួសត្រាយមុន?

ឈួង ៖ បាទ! ខ្ញុំទៅត្រួសត្រាយមុន ទៅគ្នា៦នាក់ ទៅនាំខ្មោចអាគុយទៅ សៀម ។

ដានី ៖ បាទ! ចេះពូខ្ញុំចង់ដឹងពីដំបូងតិច ដំបូងពេលដែលមុននឹងទៅរៀបចំនឹង ពូមានទៅប្រជុំអីសិន ដែរអត់?

ឈួង ៖ ទេ! គេហៅខ្ញុំទៅប្រជុំដែរ ។

ដានី ៖ បាទ! កាលនឹងមានពីណាខ្លះ ដែលមុននឹងទៅរៀបចំអាងត្រពាំងថ្ម?

ឈួង ៖ ទៅប្រជុំនោះមានតាហ៊ីង១គាត់ជាប្រធាន គណៈតំបន់នោះ តាវ៉ាល់ ហើយខ្ញុំ ។

ដានី ៖ តាវ៉ាល់ ហើយពូ?

ឈួង ៖ បាទ! ៣នាក់នឹងឯង ។

ដានី ៖ កាលនឹងដូចថា កាលពេលនឹង ពេលប្រជុំនឹងមានផែនការយ៉ាងម៉េចដែរ ដូចថាដំបូងយើង អត់ទាន់ ពេលដែលប្រជុំនឹងយើងអត់ទាន់ដឹង?

ឈួង ៖ បាទ! អត់ទាន់ដឹងទេ ហៅទៅប្រជុំតែ៣នាក់ ប៉ុនកម្លាំងម៉ាចំនួននោះមិនទាន់ដកចេញពីកងវ៉ា អស់ទេ ។ ដល់ហៅទៅប្រជុំទៅគេ ព្រោះអង្គការខាងលើឲ្យយើងរៀបធ្វើ មុនដំបូងអត់មាន ធ្វើអាងទេ គេឲ្យយើងធ្វើផ្លូវដើម្បីទៅស្រុកថៃ ។ ឲ្យធ្វើចរន្តអគ្គីសនីបញ្ហាទឹកឲ្យទឹកនេះវារត់ ចេញពីនេះទៅរហូតទៅដល់ស្រុកថៃស្រែណូយនោះឯង ។

ដានី ៖ ស្រែណូយខាងភ្នំវិទ្ធ ខាងសៀមរាបនេះនឹង?

ឈួង ៖ ទេ! ស្រែណូយយើងខាងនេះ ។

ហ៊ុយ : ស្រែណូយយើងខាងបន្ទាយឆ្មារ ។

ឈួង : គោករមៀត ស្រែណូ ។

ដានី : បាទៗ ច្រឡំស្រែណូយ ។

ឈួង : អូ! ដូនណូយនោះឯង ខ្ញុំច្រឡំថាស្រែណូយ ។

ដានី : ដូនណូយ?

ឈួង : បាទ! ដល់ទៅ ខ្ញុំធ្វើការនោះ២ខែ ខ្ញុំដើរតំរង់២ខែ ដល់ដើរតំរង់ទៅចំទិសដៅអស់ហើយ រាយការណ៍ ទៅស្រាប់គេប្រែផែនការថា មិនបានធ្វើទេ ឲ្យធ្វើជាអាងទឹកវិញ ឲ្យធ្វើអាងទឹក ត្រពាំងថ្មវិញទៅ ។ បានឲ្យយកកម្លាំងទៅលើកហើយ លើកបាន៣ថ្ងៃ លើកនៅភ្នំកូនខ្វែង លើកចោលនៅ ។

ដានី : ចុះលោកពូ ចុះពេលប្រជុំដំបូងប្រជុំជាមួយតាហ៊ីង តាវ៉ាល់ ហើយលោកពូនឹង កាលនឹង ប្រជុំពេលណាខែណា ឆ្នាំណាដែលប្រជុំថា?

ឈួង : ដែលប្រជុំខែ១០នឹងឯង ដើមខែវស្សា ខែ១០ ។

ដានី : ប្រជុំខែ១០នឹង ប្រជុំខែ១០ ៧៦នឹង ប្រជុំដំបូងតាហ៊ីងថា អង្គការខាងលើ ឲ្យយើងរៀប ចំធ្វើផ្លូវ?

ឈួង : បាទ! ធ្វើផ្លូវ ។

ដានី : ធ្វើផ្លូវចាក់ទៅថៃ?

ឈួង : ចាក់ទៅថៃ ។

ដានី : ធ្វើផ្លូវពីត្រង់ណាទៅត្រង់ណា?

ឈួង : ធ្វើផ្លូវនេះឲ្យធ្វើចាប់ពីសំរោង កាំណាំ ណាំតាវ ។

ដានី : សំរោង ណាំតាវ ខាងត្រពាំងថ្មនឹង?

ឈួង : បាទ! ឲ្យរហូតដល់ដូនណូយ ។ ដល់ដូនណូយនេះ ហើយឲ្យខាងសៀមរាបគេចាប់ពីនេះរហូត ទៅអន្លង់វេង្គចេះ គេឲ្យធ្វើទៅចេះតគ្នា ។

ដានី : គាត់មាននិយាយថា អង្គការលើដែលថាដាក់បញ្ជាឲ្យធ្វើផ្លូវនឹង អង្គការលើណា ខាងណា?

ឈួង : អង្គការខាងលើស្តីគេហៅ០អឺ បងគណៈមជ្ឈិមបក្ស ។

ដានី : គណៈមជ្ឈិមបក្ស បានន័យថាមកពីភ្នំពេញមក?

ឈួង : បាទ! គណៈមជ្ឈិមបក្សប៉ុលពតនោះឯង គណៈមជ្ឈិមបក្ស ។

ដានី : គាត់ថាបងគណៈមជ្ឈិមបក្សឲ្យធ្វើផ្លូវ?

ឈួន ៖ នោះឯង ។

ដានី ៖ ថាឲ្យធ្វើផ្លូវពីត្រពាំងតាវមិញ?

ឈួន ៖ បាទ! ពីណាំតាវ ។

ដានី ៖ ពីណាំតាវៗចាក់ទៅរហូតដល់ដូនណូយ?

ឈួន ៖ បាទ!

ដានី ៖ ដូនណូយៗនៅកន្លែងណា?

ឈួន ៖ ដូនណូយនៅព្រំដែនថៃ ខាងលិច ព្រំដែនខាងលិច នៅក្នុងស្រុកស្វាយចេក ។

ដានី ៖ បាទ! ទៅដល់ស្រុកស្វាយចេក ។ ហើយពីខាងសៀមរាប គេធ្វើពីដូនណូយមកអន្លង់វែង?

ឈួន ៖ ទេ! ខាងសៀមរាបគេធ្វើពីណាំតាវចេះទៅអន្លង់វែង ទៅចេះវិញ ព្រោះវាតំបន់ខុសគ្នា ។

ដានី ៖ យើងចាក់ពីណាំតាវទៅដូនណូយ ហើយពីខាងសៀមរាបគេធ្វើពីណាំតាវទៅខាងអន្លង់វែង?

ឈួន ៖ បាទ!

ដានី ៖ បានន័យថាផ្លូវនឹងដូចណូយនឹង នៅព្រំដែនថៃជាប់ព្រំដែនថៃ?

ឈួន ៖ បាទៗ ។

ដានី ៖ បានន័យថាធ្វើនឹង ដើម្បីឲ្យមានផ្លូវពីថៃមកចូលមកណាំតាវ បានចាក់មកអន្លង់វែង ។

ឈួន ៖ បាទ! ដូនណូយនេះឆ្លងតែដូនណូយមក ល្បើកស្វាយៗថៃ ។

ដានី ៖ កាលនឹងដែនការប្រជុំនឹង គេមានគម្រោងថាត្រូវធ្វើផ្លូវទទឹងប៉ុន្មាន អីយ៉ាងម៉េចដែរកាលនឹង?

ឈួន ៖ កាលដែលធ្វើនោះ ប៉ុនឮដូចអត់ទាន់ច្បាស់ដែរ ប៉ុនគ្រាន់ឮថានិយាយថាគេធ្វើផ្លូវរទេះភ្លើងទេ ។

ដានី ៖ គេថាធ្វើផ្លូវរទេះភ្លើង?

ឈួន ៖ នោះហើយ ។

ដានី ៖ ធ្វើផ្លូវរទេះភ្លើង?

ឈួន ៖ នោះឯង ។

ដានី ៖ ធ្វើផ្លូវរទេះភ្លើងពីណាំតាវទៅ?

ឈួន ៖ បាទ! នោះឯង ធ្វើផ្លូវរទេះភ្លើង ។

ដានី ៖ ធ្វើផ្លូវរទេះភ្លើង ។ តាហ៊ីងគាត់និយាយប្រាប់ថា ខាងគណៈមជ្ឈិម?

ឈួន ៖ គណៈមជ្ឈិមបក្ស ។

ដានី ៖ គណៈមជ្ឈិមបក្សនឹង អ្នកឲ្យធ្វើ?

ឈួង ៖ បាទ!

ដានី ៖ មានប៉ុល ពត?

ឈួង ៖ ប៉ុល ពត នឹងឯងគណៈមជ្ឈិមបក្ស ។

ដានី ៖ មានពូនួន ជា អីដែរអត់?

ឈួង ៖ ទេ អត់ពូផង ។

ដានី ៖ ប៉ុន្តែគាត់និយាយថា គណៈមជ្ឈិមបក្ស ប៉ុន្តែអត់មនាឈ្មោះពីណាទេ?

ឈួង ៖ ហ្នឹង អត់មានថាឈ្មោះពីណាទេ ព្រោះខ្ញុំដឹងថា គណៈមជ្ឈិមបក្សនឹង មុខតែ ប៉ុល ពត ហើយ ព្រោះដែលធំជាងគេក្នុងម៉ាស្រុកខ្មែរ ។ ប៉ុនមិនដឹងជានរណា អានេះខ្ញុំថា ។

ដានី ៖ ចឹងគេឲ្យពូដូចថាធ្វើផ្លូវនឹង គេឲ្យយើងធ្វើរបៀបម៉េច ព្រោះគេធ្វើរទេះភ្លើង យើងត្រូវមានបច្ចេកទេសអីគេ?

ឈួង ៖ បាទ! អានេះគេឲ្យយើងតំរង់ឲ្យត្រង់រួច គេឲ្យយើងលើកដីធ្វើផ្លូវ ដល់អាគ្រឿងដែកគ្រឿងអីគេ អានោះតាមគេធ្វើក្រោយយ៉ាងណា យើងអត់ដឹង ។

ដានី ៖ បានធ្វើចឹង?

ឈួង ៖ បាទ!

ដានី ៖ គេឲ្យយើងតំរង់ៗយ៉ាងម៉េចអានឹង?

ឈួង ៖ តំរង់យកឲ្យត្រង់ ។

ដានី ៖ តំរង់យកឲ្យត្រង់?

ឈួង ៖ បាទ!

ដានី ៖ ឲ្យត្រង់ចាក់ចេញពីណាំគាវទៅដូនណូយនឹង?

ឈួង ៖ បាទ!

ដានី ៖ ប៉ុន្មានគីឡូពីនឹងទៅ?

ឈួង ៖ អូ! ច្រើនណាស់ ភ្លេចហើយ ភ្លេចប៉ុន្មានគីឡូ ភ្លេច ។ ព្រោះខ្ញុំតំរង់ឡើងដេកក្នុងព្រៃឡើងកន្ទះ ។

ដានី ៖ តែម្នាក់ឯងទេ តំរង់នឹង?

ឈួង ៖ ៦នាក់ ។

ដានី ៖ ៦នាក់ ពីណាខ្លះដែលអ្នកតំរង់?

ឈួង ៖ តាសឿន អាអន្ទិតអោង ហើយអាសៀម អាធុយនោះឯងសុទ្ធតែ ។

ដានី ៖ អ្នកតំរង់?

ឈួង ៖ នោះឯង ការងារខ្ញុំហៅទៅដូចថាគ្នាឯង ស្រុកឯង ។

ដានី ៖ ចុះពេលប្រជុំមានតែគ្នា៣នាក់នឹង អត់មានពីណាផ្សេង?

ឈួង ៖ បាទ! ៣នាក់ប៉ុននោះ ។

ដានី ៖ ប្រជុំនោះគ្រាន់ដាក់ផែនការអីនឹង ប្រជុំយ៉ាងម៉េច ដាក់ផែនការឲ្យយើងលើកផ្លូវ លើកអីរយៈពេលប៉ុន្មានដែរ?

ឈួង ៖ ទេ! អត់ទាន់ដាក់ផែនការថារយៈពេលប៉ុន្មានទេ ឲ្យតែតំរង់ឲ្យបានសិន ព្រោះក្នុងការតំរង់នោះ ឧទាហរណ៍ថា ខ្ញុំតំរង់ចេញពីភូមិដូនជ្រែងចេះ សំដៅទៅបឹងឃ្លាំង ឲ្យអ្នកដូនជ្រែងនេះ ឯងឆ្ការព្រៃឲ្យខ្ញុំឲ្យឆ្ការហូតទៅដល់ពាក់កណ្តាលវាល ។ ឲ្យអ្នកដូចជ្រែងមកវិញ ឲ្យភូមិបឹង ឃ្លាំងនេះយកកម្លាំងមកឆ្ការបន្ត ព្រោះខ្ញុំទៅគ្រាន់អ្នកតំរង់ ហើយនឹងបញ្ជាពួកនោះឲ្យឆ្ការប៉ុន នោះឯងមិនបានទៅធ្វើអីខ្លួនឯងទេ តែយប់ត្រង់ណា ដេកត្រង់នោះ ។

ដានី ៖ ចុះកាលនោះយើងយកអីតំរង់?

ឈួង ៖ តំរង់ ត្រីវិស័យ ។

ដានី ៖ ត្រីវិស័យ?

ឈួង ៖ បាទ!

ដានី ៖ យើងដាក់យ៉ាងម៉េច យើងអត់ចេះបច្ចេកទេស ខ្ញុំចេះឆ្ងល់តិច?

ឈួង ៖ ត្រីវិស័យនោះ យើងដូចត្រីវិស័យវាមិនវិល សញ្ញាទិសជើង ឧទាហរណ៍ជើង ដឹងថាចង្អុរទៅជើងហើយ យើងវង់ទៅណាដឹងថាជើងហើយ ដល់ហើយយើងតំរង់យកលិចកើតឲ្យតែ ឃើញអានេះទៅជើងហើយ លិខកើត យើងតំរង់ ។

ដានី ៖ ត្រីវិស័យចិន?

ឈួង ៖ បាទ! ប៉ុនត្រីវិស័យនោះមិនមែនដូចគ្នាចេះទេ មានទ្រនិចនេះវាតែមួយ ។

ដានី ៖ ដូចថាខាងលិចខាងកើត ខាងជើង ខាងត្បូង?

ឈួង ៖ បាទ! យើងតំរង់ធ្វើម៉េច ឲ្យតែទ្រនិចនេះត្រង់ទៅជើង គឺចំហើយលិចកើត ។

ដានី ៖ យើងប្រើត្រីវិស័យប៉ុន្មានគីឡូ យើងតំរង់ម្តងៗ?

ឈួន ៖ បាទ! ដូចថាយើងចំងាយដូចថា ប្រហែលជាម៉ាគីឡូ ប្អូនកន្លះគីឡូ យើងដាក់មួយ ដាក់ម្តង ហើយដាក់ម្តង ចំដើមឈើណាកាប់ដើមឈើនោះ បើចំអាដើមឈើធំចេះយើងគំរង់មិនកើត កាប់វាមិនបាន វាធំពេក ដល់កាប់មិនបានខាងនេះយើងគំរង់ថយមកក្រោយចេះៗ ថយមកបានចាក់យកចំហៀងចេះ នេះចាក់ចំហៀង ចាក់ទៅចេះអានោះចាក់មក ត្រូវគ្នាបណ្តោយ ។ ដល់កាប់ដើមឈើចេញទៅគ្រង់ភ្លឺង ចំជង្រុកគេមួយ ។ ចំជង្រុកឲ្យរើជង្រុក ។

ដានី ៖ ជង្រុកស្រូវ?

ឈួន ៖ ជង្រុកស្រូវ ។ ចំនៅភូមិថ្មី ខាងលិចទ្រា ។

ដានី ៖ ចុះការគំរង់ៗ ការនេះនឹងបានរយៈពេលប៉ុន្មាន បានដូរផែនការវិញ?

ឈួន ៖ ខ្ញុំទៅ ជាងកន្លះខែ វាចូលម៉ាខែជាង ការដែលទៅមកៗ រួចបានហៅកម្លាំងទៅលើកហើយ គាត់ឲ្យកម្លាំងទៅលើកបាន៣ថ្ងៃ ដកថាផែនការកែប្រែត្រូវធ្វើអាងទឹកវិញ ។ ដល់ហើយដកកម្លាំងមក ។

ដានី ៖ ចឹងបានន័យថា ពូបានប្រមូលយកកម្លាំងទៅលើកដី ប្រុងធ្វើផ្លូវពីដូនណូយនឹង លើកបាន៣ថ្ងៃហើយ?

ឈួន ៖ បាទ!

ដានី ៖ ចឹងឆ្ការព្រៃអស់ហើយ កន្លែងផ្លូវ?

ឈួន ៖ ឆ្ការអស់ហើយ ។

ដានី ៖ ឆ្ការអស់ហើយ យើងគំរង់អ្វីរួច យើងឆ្ការ?

ឈួន ៖ អឺ! គំរង់រួច ឡើងនាំកម្លាំងទៅលើក ។

ដានី ៖ បាន៣ថ្ងៃហើយ?

ឈួន ៖ បាទ! លើកបាន៣ថ្ងៃហើយ គេថាអូ!ដកកម្លាំងមកធ្វើអាងទឹកវិញទៅក៏ដីដែលលើកហើយក៏ នៅសព្វថ្ងៃនោះឯង ខាងជើងស្រះតាបាប់ភ្នំកូនខ្វែង ។

ដានី ៖ ដល់ចឹងប្រជុំម៉ាសារទៀត?

ឈួន ៖ អត់ប្រជុំទេ គេសម្រេចថាលើក ព្រោះខាងសៀមរាបគេលើកពីនោះហើយ វាត្រូវខ្សែគ្នាណា ។ ខាងសៀមរាបគេលើកចេញមកពីសែនសុខ ចេញមកពីអន្លុរ គំរង់អាផ្លូវចាស់ ផ្លូវបូរាណណា គំរង់មកចំអាងទឹកត្រពាំងថ្មនោះឯង ។ នេះបានគេឲ្យធ្វើអាងនឹងបណ្តោយ ។

ដានី ៖ ចឹងអាឯកាលដែលយើងដូរផែនការពេលធ្វើដូរមកធ្វើអាឯនឹង យើងមានប្រជុំម៉ាសារទៀតដែលអត់?

ឈួង ៖ ទេ! ប្រជុំ អាអ្នកធំៗគេប្រជុំរួចហើយ ។

ដានី ៖ ពីណា អ្នកធំណាមកប្រជុំ?

ឈួង ៖ ពួកតាវ៉ាល់ ពួកអីដែលគាត់មិនបានទៅជាមួយខ្ញុំ ខ្ញុំនៅឯព្រៃនេះខ្ញុំអត់ដឹង ដល់មកស្រាប់តែគេបញ្ជាប្រាប់ថា "ឥឡូវឈួងឯងត្រូវនាំកម្លាំងយើងរៀបចំធ្វើអាឯវិញ ។ ឥឡូវត្រៀមខ្សែត្រៀមដាក់កម្លាំងលើកអាឯ ។" បានខ្ញុំក៏រៀបចំខ្សែត្រៀម ។

ដានី ៖ ចឹងតាវ៉ាល់ តាហ៊ីង គាត់ប្រជុំម៉ាសារទៀតហើយ?

ឈួង ៖ បាទ! គាត់ប្រជុំប៉ុន្មានសារទេ ព្រោះខ្ញុំវាអត់ដឹងដែរ ។

ដានី ៖ ប៉ុន្តែអាឯនឹង មានផែនការដូរពីខាងមជ្ឈិមបក្សមក ដូរឲ្យមកធ្វើអាឯវិញ ឬក៏ត្រឹមតាហ៊ីងនឹង គាត់ដូរ?

ឈួង ៖ ទេ! ពីលើនឹងឯងដូរ ។

ដានី ៖ ពីលើណា ពី?

ឈួង ៖ ពីគណៈមជ្ឈិមបក្សនឹងឯង គាត់ដូរ ។

ដានី ៖ ដល់ពេលអ្នកដែល អានឹងពូច្បាស់ហើយ ប្រហែលមិនមែនតាហ៊ីងគាត់អ្នកដូរខ្លួនឯង?

ឈួង ៖ អត់ទេ អត់មានតាហ៊ីងទេ មកពីគណៈមជ្ឈិមបក្សបញ្ជាមកឲ្យតាហ៊ីងរៀបចំ ។

ដានី ៖ ការធ្វើដូរដំបូងតាហ៊ីង គាត់អ្នកនិយាយផ្ទាល់ខ្លួនឯងថា មជ្ឈិមបក្សអ្នកនេះចឹង?

ឈួង ៖ បាទ!

ដានី ៖ ពូឮផ្ទាល់ម៉ង?

ឈួង ៖ បាទ!

ដានី ៖ ដល់ពេលមកធ្វើអាឯត្រពាំងថ្មនេះវិញ តាវ៉ាល់ ឬក៏តាហ៊ីង អ្នកប្រាប់ឲ្យពូដកកម្លាំងមកធ្វើ?

ឈួង ៖ តាវ៉ាល់ ។

ដានី ៖ តាវ៉ាល់?

ឈួង ៖ បាទ!

ដានី ៖ តាវ៉ាល់ គាត់ថាម៉េចកាលនឹង?

ឈួង ៖ ឲ្យយើងដកកម្លាំងមកធ្វើអាឯត្រពាំងថ្មឯនេះវិញ ។

ដានី : ឲ្យដកមកធ្វើអាងត្រពាំងថ្មវិញ?

ឈួង : បាទ! បានខ្ញុំក៏ដកកម្លាំងមកវិញ ។

ដានី : ចុះពូមានសួរហេតុផល ម៉េចបានយើងដូរពីធ្វើផ្លូវមកធ្វើអាង?

ឈួង : បងហ៊ីង មិនហ៊ានសួរទេ ។

ដានី : អត់ហ៊ានទេនោះ?

ឈួង : បាទ!

ដានី : កាលនឹងគ្រាន់ថាគាត់ប្រាប់ឲ្យដកកម្លាំង មកធ្វើវិញ?

ឈួង : បាទ!

ដានី : ដល់ពេលយើងចាប់ផ្ដើមធ្វើអាងត្រពាំងថ្មនឹង ចាប់ពីថ្ងៃណា ខែណា?

ឈួង : អូ! រកថ្ងៃមិនឃើញទេ ។

ដានី : បើខែ ឥឡូវខែ?

ឈួង : ច្រូតរួច ព្រោះដែលយើងទៅនៅតែច្រាំង ។

ដានី : សល់ច្រាំង?

ឈួង : បាទ! ប្រហែលខែ២ ។

ដានី : ខែ១ ខែ២ឆ្នាំ៧៧?

ឈួង : ប៉ុនគេបានកត់ទុកនោះដែរតើ ។

ហ៊ុយ : ឯណា?

ឈួង : ក្នុងអាង គេមានកត់ត្រាថ្ងៃខែដែរតើ ។

ដានី : ចឹងថ្ងៃ១ ខែ២នឹង គេចាប់ផ្ដើមធ្វើ?

ឈួង : អានេះមិនកំណត់ទេ ថ្ងៃ១ ខែ២ ។

ដានី : ពូមួយទៀត មិញនឹង ផែនការដែលធ្វើនឹងចេញពីមជ្ឈិមបក្សមក ដែលធ្វើអាងនឹង?

ឈួង : បាទៗ ។

ដានី : ចឹងដែលគោលបំណង ដែលគេធ្វើអាងនឹង គេធ្វើដើម្បីអី?

ឈួង : គេអានេះតាមការណែនាំខាងក្រោម ការធ្វើអាងនេះ ដើម្បីស្ដុបទឹកធ្វើស្រែប្រាំង ។

ដានី : ធ្វើស្រែប្រាំង?

ឈួង : ហ្នឹងឯង ។

ដានី ៖ កាលនឹងគេមាននិយាយថាយើងធ្វើអាងនឹងស្តុបទឹក ដើម្បីធ្វើស្រែប្រាំង១នឹងកន្លែងដែលធ្វើទំហំប៉ុន្មាន នៅក្នុងឃុំណា ស្រុកណាខ្លះអីចឹង?

ឈួង ៖ ស្រែប្រាំងនឹង វាត្រីវបានស្រុកភ្នំស្រុក ត្រូវបានស្រុកព្រះនេត្រព្រះរហូតមកដល់យើងព្រះនេត្រព្រះ ដល់កំបោរដល់អីនេះ ដែនការដែលគេត្រូវធ្វើ។ ព្រោះគេដឹកធ្វើស្ពាន ដឹកពីស្ពានទី១មក គេធ្វើស្នាមភ្លោះ ធ្វើប្រឡាយ រហូតមកដល់ព្រៃមាន់។

ដានី ៖ គេដឹកប្រឡាយស្នាមភ្លោះពីត្រង់ណា ពី?

ឈួង ៖ បាទ! ដឹកពីស្ពានទី១ ។

ដានី ៖ ស្ពានទី១មក ដឹកមករហូត១ មកដល់ព្រៃមាន់?

ឈួង ៖ បាទ! មកដល់ព្រៃមាន់នៅសព្វថ្ងៃ អាផ្លូវទឹកហូរត្រង់ភ្លឺងសព្វថ្ងៃ តាមផ្លូវយើងទៅភ្នំស្រុក ។

ដានី ៖ បាទ! ចឹងគេគោលបំណងដែលគេធ្វើអាងទឹកនឹង ដើម្បីស្តុបទឹកធ្វើស្រែប្រាំងរបស់ស្រុកភ្នំស្រុក និងស្រុកព្រះនេត្រព្រះ?

ឈួង ៖ បាទ១ ។

ដានី ៖ តែ២នឹងទេ?

ឈួង ៖ បាទ!

ដានី ៖ អត់មានខាងថ្មពួក ខាងស្វាយចេកអត់មានបានទឹកនឹងទេ?

ឈួង ៖ អត់ទេ អត់បានទេ ។

ដានី ៖ បានតែ២នឹង?

ឈួង ៖ បាទ! បានតែ២ស្រុក ។

ដានី ៖ បើភ្នំស្រុកបើយើងធ្វើនឹង យើងអាចធ្វើស្រែប្រាំងគ្រប់ដណ្តប់ពេញម៉ាភ្នំស្រុកឬក៏បានផ្នែក ខ្លះ?

ឈួង ៖ បានប៉ែកខាងក្រោម បានទាំងអស់ ។

ដានី ៖ បានទាំងអស់ ដល់ពេលខាងព្រះនេត្រព្រះ?

ឈួង ៖ ខាងព្រះនេត្រព្រះបានប៉ែកខាងលើ ។

ដានី ៖ បានប៉ែកខាងលើចាប់ពីត្រឹមណាទៅ?

ឈួង ៖ ប៉ែកខាងលើចាប់ពីរហាល ឃុំរហាល មកបានរហូតបានទាំងអស់ អត់តែឃុំព្រះនេត្រព្រះ ។

ដានី ៖ ចឹងដល់ពេលយើងចាប់ផ្តើមកធ្វើអាងនឹង យើងធ្វើពីកន្លែងណាទៅកន្លែងណាទៅ?

ឈួង ៖ ចាប់ធ្វើ ចាប់ពីស្ពានទី១ ដល់ស្ពានទី៣ ។

ដានី ៖ ស្ពានទី១ ដល់ស្ពានទី៣?

ឈួង ៖ បាទ! ព្រោះវាមានស្ពានចាស់ពីដើម ស្ពានចាស់បូរាណ វាមានផ្លូវទឹកបូរាណមួយ ហើយផ្លូវនឹងក៏ជាផ្លូវចាស់ចេញពីអង្គរវត្តដែរ ចេញមកស្ពានស្រែង ស្ពានក្មេង មករហូតមកដល់ត្រពាំងថ្មនឹងឯង ។

ដានី ៖ គេហៅកន្លែងនឹងគេហៅអីគេទៅ?

ឈួង ៖ មុនដំបូងពីដើម?

ដានី ៖ បាទ!

ឈួង ៖ ហៅថាផ្លូវបូរាណៗ ស្ពានទី១ ស្ពានទី២ ស្ពានទី៣ ។

ដានី ៖ កាត់ភូមិអីខ្លះ?

ឈួង ៖ កាត់ភូមិត្រពាំងថ្ម ។

ដានី ៖ កាត់ភូមិត្រពាំងថ្មនឹងម៉ង?

ឈួង ៖ មានកាត់ភូមិមួយប៉ុននោះឯង ។

ដានី ៖ ចុះផែនការដែលយើងគេធ្វើអាង ការនឹងមិនលើកទំនប់ដែរ កាលនឹងមានដូចថាទំនប់នឹងខ្ពស់ ប៉ុន្មាន បាតក្រោមប៉ុន្មាន កំពស់ប៉ុន្មាន បណ្តោយប៉ុន្មាន?

ឈួង ៖ ទេ! កាលមុនដំបូងនោះ មានផ្លូវចាស់ ផ្លូវបូរាណ ផ្លូវចាស់សៀមរាបនោះ ត្រង់ណាក៏មានថ្មបាយក្រៀម ត្រង់ណាក៏អត់ ។ ទាល់តែក្រោយមកបានយើងតំរង់អានោះ ដើម្បីឯងរៀបចំធ្វើថ្មី ។

ដានី ៖ បាទ! រៀបចំធ្វើថ្មី?

ឈួង ៖ បាទ!

ដានី ៖ រៀបទៅយើងធ្វើយ៉ាងម៉េចទៅ យើងធ្វើកំពស់ប៉ុន្មាន?

ឈួង ៖ បាទ! ដែលរៀបចំធ្វើនោះ គឺអាងទឹកគេយកកំពស់៣ម៉ែត្រ ដែលគេទិសដៅគេដាក់ ហើយបាតក្រោមវា២៥ម៉ែត្រ ។

ដានី ៖ បាតក្រោមវា២៥ម៉ែត្រ ចុះកំពស់លើ?

ឈួង ៖ ខ្ពស់វា១០ម៉ែត្រ ។

ដានី ៖ ចុះបណ្តោយ?

ឈួន ៖ បណ្តោយវា ជីងប៉ុន្មានគីឡូភ្លេចហើយ ៨គីឡូ ៨ ខ្ញុំប្រឡំ ។ បើមិន៨គីឡូទេ ដល់ធ្វើត្រឹមស្ពានទី៣ទេ មិនមែនគទៅស្ពានទី៣គេមិនបានធ្វើទេ ។

ដានី ៖ អត់ច្បាស់ ប្រហែល៨គីឡូ?

ឈួន ៖ បាទ!

ដានី ៖ ចុះកាលនឹងយើងមានដាក់ផែនការយើងត្រូវធ្វើរយៈពេលប៉ុន្មាន ហើយត្រូវកម្លាំងប៉ុន្មានដែរ កាលនឹង?

ឈួន ៖ អូ! កម្លាំងច្រើនណាស់កាលនឹង ប៉ុនកម្លាំងវា២ស្រុក ស្រុកភ្នំស្រុក ស្រុកព្រះនេត្រព្រះ ។

ដានី ៖ កាលនឹងប្រហែលប៉ុន្មានទៅ កាលនឹង?

ឈួន ៖ កាលកម្លាំងដែលខ្ញុំក្តាប់បានតែខាងខ្ញុំ ដែលខ្ញុំក្តាប់បានវា៩០០០ជាង១ នេះដល់អាកម្លាំងខាងភ្នំស្រុក ខាងសហករណ៍គេចូលរួមនោះផង នោះគេអត់ជីងរបស់គេប៉ុន្មានទេ ។

ដានី ៖ នឹងសហករណ៍ភូមិស្រុកគេតើ?

ឈួន ៖ បាទ!

ដានី ៖ សហករណ៍ស្រុកព្រះនេត្រព្រះ និងស្រុកភ្នំស្រុក?

ឈួន ៖ បាទ!

ដានី ៖ អត់ជីងប៉ុន្មាន?

ឈួន ៖ អត់ វាក្តាប់របស់គេមិនច្បាស់ដែរ ។

ដានី ៖ បើរបស់លោកពូ ជាង៩០០០នាក់?

ឈួន ៖ បាទ! ប៉ុនជាង៩០០០នាក់ មិនមែនលើកទាំងអស់ទេណា ទាំងអាអ្នកនៅលើគោក ទាំងអ្នកនៅអីណា១ អ្នកដាំបាយ អ្នកស្អីទាំងអស់ ។

ដានី ៖ ចុះលើក១រយៈពេលប៉ុន្មានទៅបានហើយ?

ឈួន ៖ ដល់ហើយនេះ ខ្ញុំអត់បាននៅ ខ្ញុំលើកបានតែរៀបចំឲ្យគេរួច បានតែ៣ខែ បានកំពស់លិចក្បាល ខ្ញុំត្រូវគេដកឲ្យទៅនៅខាងប្រធាននេសាទតំបន់៥ ។

ដានី ៖ ចឹងពូនៅបានរយៈពេល៣ខែ?

ឈួន ៖ បាទ! ដល់ចល័តលើកទំនប់នោះវាអត់ត្រីស៊ីខ្លាំងទៅ គេឲ្យទៅរកត្រី ។ ដល់ឲ្យទៅរកត្រីនោះនាំចល័តនោះឯងមករក ។

ដានី ៖ ប៉ុន្តែលោកពូកាលនឹង តាមពូមីងម៉ាចំនួនដែលថាលើក មិនមែនកំពស់៣ម៉ែត្រទេ គាត់ថាងើយឡើងចង់ជ្រុះមួក មិនមែន៣ម៉ែត្រទេ?

ឈួន ៖ ទេ! ដល់គេលើករួចហើយមិនដឹងប៉ុន្មានដែរ ខ្ញុំអត់បាននេះ កាលផែនការដែលដាក់ថាលើក តែ៣ម៉ែត្រ ។

ហ៊ុយ ៖ ចាំទៅសួរ មេឃុំប៉ោយចារ វាបណ្ដោយវា១៥ ទទឹង១១ បណ្ដោយ១៥គីឡូ ប្រហែល បណ្ដោយវាពីជើង-ត្បូងដឹង អាទទឹងវា ។

ឈួន ៖ បាទ! នោះហើយទទឹង អាបណ្ដោយនោះវាលើកតូចតើ លើកពីប៉ោយពន្រទៅលើកជើង ។

ហ៊ុយ ៖ បាទ! ចាប់ពីត្រពាំងថ្មមករហូត ចាប់ពីស្ពានទី១ទៅជើង ។

ឈួន ៖ បាទ! ហ្នឹងរហូត ទប់កុំឲ្យទឹកវាបាក់ចូលទៅក្នុងភូមិ ។

ដានី ៖ ចឹងកាលនឹងលោកពូកាលនឹងលោកពូនៅនឹងបានតែ៣ខែទេ?

ឈួន ៖ បាទ! នៅបាន៣ខែទៅ គេដកមកធ្វើនេសាទ ។

ដានី ៖ តែបើតាពូចាំ ចាប់ពីយើងចាប់ពីខែ១ ខែ២ឆ្នាំ៧៧នឹង ដល់ពេលយើងរួចសព្វគ្រប់ ប្រហែលជាខែប៉ុន្មាន មើលទៅឆ្នាំណាទៅ?

ឈួន ៖ ទេ! ដែលរួចចប់សព្វគ្រប់នេះមិនទាន់ចប់ស្រួលទេ វាវៀតណាមចូលមកនេះ អត់ទាន់រួច ស្រួលបួលទេ ។

ហ៊ុយ ៖ អត់ទាន់រួចស្រួលបួលទេ ព្រោះខាងប៉ោយតាប៉ែនដែលសម្ភាសន៍មួយនឹង វៀតណាមវាស់ អត់ទាន់រួចទេ វៀតណាមចូល មិនទាន់រួចទេ ទំនប់ ។

ឈួន ៖ ដល់វៀតណាមចូលមក បែកគ្នាបណ្ដោយ ។

ដានី ៖ មិនទាន់ចប់សព្វគ្រប់ទេ ចឹង?

ឈួន ៖ បាទ!

ដានី ៖ ចឹងកម្លាំង៩០០០ ហើយកម្លាំងមកពីសហករណ៍ភ្នំស្រុក ហើយនឹងព្រះនេត្រព្រះទៀត ចឹងកម្លាំងរាប់ម៉ឺននាក់ លើកនៅនឹង?

ឈួន ៖ បាទ!

ដានី ៖ ចុះកាលនឹងដូចថា ពេលលើកចឹង យើងដាក់ផែនការយ៉ាងម៉េចទៅ?

ឈួន ៖ ដែលលើកនោះ អានោះខាងក្រោមគេរៀបផែនការខ្ញុំអត់ដឹងដែរ ប៉ុនទិសដៅចេញពីតាវ៉ាល់ ចេញពីខ្ញុំទៅ គឺហៅថាប្រធានកងធំ ហើយនឹងវរសេនាតូច វរសេនាធំមកធ្វើការទេ គឺថា ទិសដៅត្រូវវ៉ៃកំរិតយើងដូចថា ក្នុងម្នាក់៣ម៉ែត្រគឺប អ្នកឯងរួចទាំងថ្ងៃ គឺសម្រាកទាំងថ្ងៃ ឯងមិនរួច ក៏ធ្វើឲ្យទាល់តែរួច ។

ដានី ៖ អានឹងពូអ្នកសម្រេច ឬក៏យ៉ាងម៉េច ឬក៏មកពីយើងគាវ៉ាល់ ពូអ្នកសម្រេចថាម្នាក់នឹងត្រូវតែ៣ម៉ែត្រគីប ឬក៏ចេញពីតាហ៊ីង ឬក៏ចេញពីមជ្ឈមបក្ស?

ឈួង ៖ ចេញមកពីលើនោះឯង ចេញមកពីគណៈតំបន់ៗ

ដានី ៖ ចេញពីគណៈតំបន់?

ឈួង ៖ បាទ! ព្រោះគណៈតំបន់ប្រាប់ថា ផែនការ ផែនការក្តៅគគក់ យើងធ្វើម៉េចកម្លាំងម្នាក់ៗឲ្យបាន៣ម៉ែត្រៗ

ដានី ៖ ចឹងអា៣ម៉ែត្រគីបនឹង ចេញមកពីគណៈតំបន់មក?

ឈួង ៖ បាទ!

ដានី ៖ ចេញពីតាហ៊ីងមក?

ឈួង ៖ បាទ!

ដានី ៖ មិនមែនគាវ៉ាល់ហើយពូជាអ្នកសម្រេចថា ម្នាក់ៗត្រូវធ្វើឲ្យបាន៣ម៉ែត្រ?

ឈួង ៖ ទេ! អត់ទេៗ

ដានី ៖ តាហ៊ីងគាត់ថា បើពូនៅចាំគាត់មានប្រសាសន៍ថាម៉េច?

ឈួង ៖ គាត់ថាឥឡូវយើងសម្រេចផែនការឲ្យបានរួចឆាប់ ព្រោះកុំឲ្យកម្លាំង-ក គឺយើងវៃក្នុងម្នាក់ឲ្យ៣ម៉ែត្រគីបៗ

ដានី ៖ ឲ្យ៣ម៉ែត្រគីប?

ឈួង ៖ បើសិនជាកម្លាំងនោះម៉ោង១០រួច គឺអ្នកឯងដេកវាស់ល្ងាចចុះ សម្រាកចុះព្រោះអីបានកម្លាំងធូរៗ បើសិនជាយើងធ្វើមិនមានផែនការទេ វែកតាមដំណើរ វែកវាស់ល្ងាច ម្លេះហើយវានឿយវាស់ល្ងាច ហើយដំណើរការវាអត់លឿនៗ ហើយក្នុងការដែលឲ្យ៣ម៉ែត្រគីបនេះ គឺហូបក្នុងម៉ាថ្ងៃ៣ដង មិនខ្វះទេរឿងហូបៗ

ដានី ៖ គាត់ថាចឹង?

ឈួង ៖ បាទ!

ដានី ៖ ហើយហូប៣ដង?

ឈួង ៖ បាទ!

ដានី ៖ ហូបពេលណាខ្លះ?

ឈួង ៖ ហូបពេលព្រឹកហូបម្តងៗ

ដានី ៖ ហូបពេលព្រឹក ម៉ោងប៉ុន្មានហូប?

ឈួន ៖ ដូចថាព្រឹកឡើងមុននឹងចេញធ្វើការយើងហូបម្តង ។

ដានី ៖ ៣ដង?

ឈួន ៖ បាទ!

ដានី ៖ ព្រឹក ចុះថ្ងៃ?

ឈួន ៖ ហូបព្រឹករួចចេញទៅធ្វើការ ដល់ធ្វើការរួចថ្ងៃឡើងហូបម្តងទៀត ហើយល្ងាចម្តងទៀត៣ ។

ដានី ៖ ចុះហូប យើងហូបយ៉ាងម៉េច ហូបឲ្យឆ្អែត ឬយើងហូបចែករបប?

ឈួន ៖ ហូប ទេ! អត់មានចែករបបទេ ។

ដានី ៖ អត់មានចែករបបទេ?

ឈួន ៖ អត់ទេ ក្នុងម្នាក់ឲ្យរបបអង្ករ៣កំប៉ុង ក្នុងមួយម្នាក់ៗ ។

ដានី ៖ ក្នុងម្នាក់ៗនឹង?

ឈួន ៖ បាទ!

ដានី ៖ អ្នកណាចេញមកពីខាង?

ឈួន ៖ ខាងពួកខ្ញុំ ហើយនឹងតាវ៉ាល់ ខាងសេដ្ឋកិច្ចនៅនោះឯង ។

ដានី ៖ សេដ្ឋកិច្ច ពីណាគេអ្នកកាន់កាលនឹង?

ឈួន ៖ តាយឿក ។

ដានី ៖ តាយឿក គាត់អ្នកកាន់សេដ្ឋកិច្ច?

ឈួន ៖ បាទ!

ដានី ៖ តាយឿក គាត់ ពូ តាវ៉ាល់?

ឈួន ៖ តាយឿក ។

ដានី ៖ តាយឿក គាត់ទទួលខាងសេដ្ឋកិច្ច?

ឈួន ៖ បាទ! ខាងសេដ្ឋកិច្ច ។ ហើយគឺថាក្នុងម្នាក់ ។

ដានី ៖ ចឹងសេដ្ឋកិច្ច គឺម្នាក់៣កំប៉ុងចឹងម៉ង?

ឈួន ៖ បាទ! ដឹងតែ៣កំប៉ុង អត់មានថាខ្វះ អត់មានឲ្យអីទេ បើសិនជាហ៊ានថាឲ្យគេខ្វះ សេដ្ឋកិច្ចនោះ គឺត្រូវជាប់ទោស ព្រោះយើងលាក់របបគេទុកធ្វើអី នឹងគេធ្វើផែនការឲ្យតឹងរបស់គេចុះឯង ។

ដានី ៖ ផែនការដែលថាម្នាក់៣កំប៉ុងនឹង មិនមែនចេញពីត្រឹមតាមវ៉ាល់ ពូ តាយឿកទេ មិនមែនចេញពីមកពីខាងតាហ៊ីងនោះទេ?

ឈួន ៖ អឺ! ចេញមកពីនោះឯង ចេញមកពីតាហ៊ីននឹងឯង បានពួកខ្ញុំធ្វើតាមគាត់ ។

ដានី ៖ ចុះបើតាមខ្ញុំជួបពូមីនមួយចំនួន គាត់ថាកាលនឹងគេចែកតែរបបទេ យើងដូចថាម៉ាចឹងទៅ គេដាក់បាយ គេដាំទៅដាក់បាយម៉ាចាន់ស្វាបមាន់នឹង ថាម្នាក់ម៉ាពេលម៉ាចាននឹង គេចែកចឹងៗ ។

ឈួន ៖ អត់ទេ អានោះខាងសហករណ៍ ។

ដានី ៖ គេខាងសហករណ៍?

ឈួន ៖ បាទ! បើតួចល័តមិនដែលមានខ្វះខាតទេ ។

ដានី ៖ តួចល័តរបស់លោកពូ មិនដែលមានខ្វះខាតទេ?

ឈួន ៖ បាទ! អត់ទេ សួរចុះឲ្យតែចល័ត មិនដែល គ្រប់មកតាំងពីលើទំនប់កំបោរ តាំងពីណាលើក មកឲ្យតែចល័តតំបន់គ្រប់គ្រងផ្ទាល់ គឺរបបហូបចុះឯង ។

ដានី ៖ ចឹងដឹងថាម៉ាថ្ងៃ៣ពេល?

ឈួន ៖ បាទ! ដឹងថាក្នុងម្នាក់របបពាកំប៉ុង ។

ដានី ៖ ម្នាក់ពាកំប៉ុង?

ឈួន ៖ បាទ!

ដានី ៖ ចឹងការហូបចុកពីចល័តតំបន់ ហើយនឹងសហករណ៍ខុសគ្នាទៀត?

ឈួន ៖ បាទ! ខុសគ្នា ព្រោះសហករណ៍គេបើកអង្ករចេញពីសហករណ៍គេ ។ ហើយចល័តតំបន់បើក អង្ករចេញពីតំបន់ផ្ទាល់ ។ ហើយចំមើលដែលយើងបើកអង្ករនៅកន្លែងតំបន់ ហើយស្រុក បើកអង្ករពីកន្លែងតំបន់ដូចគ្នា បើមកដាក់នៅស្រុកៗចែកតាមសហករណ៍ ។ ហើយយើង ចល័តតំបន់ យើងបើកពីតំបន់ផ្ទាល់ អត់មានធ្លាក់ទៅណាទេ ។

ដានី ៖ អត់មានទំលាក់ទៅណាទេ?

ឈួន ៖ បាទ!

ដានី ៖ តែដល់ពេលលើកនឹង លើកពម៉ែត្រគីបនឹង គឺលើកពីចាប់ពីម៉ោងប៉ុន្មាន ដល់ម៉ោងប៉ុន្មានក៏ ដោយ ប៉ុន្តែឲ្យដឹងតែរួច?

ឈួន ៖ បាទ! ឲ្យដឹងតែរួច ។ មានអាខ្លះវាក្រោកពីយប់ទៅ ក៏ម៉ោង៩វារួច មកដេករំភើយ ។ ទៅវាមុជទឹកលេង រកត្រីស៊ី ។

ដានី ៖ ក្នុងកងចល័តរបស់តំបន់នឹងវាមានសុទ្ធតែប្រជាជន១៧មេសា ក៏មានប្រជាជនចាស់ដែរ?

ឈួង ៖ ប្រជាជនចាស់មាន គេហៅប្រជាជនមូលដ្ឋាន ព្រោះអ្នកនៅនេះ ១៧មេសាដែរ ក៏ប៉ុន្តែដល់ពេលគេបញ្ជូនប្រជាជនថ្មីមក វាទៅជាអា១៧មេសានេះ វាទៅជាមូលដ្ឋានចាស់ៗទៅ អាអ្នកមកពីភ្នំពេញនោះ ទៅជាប្រជាជនថ្មី គេហៅ១៧មេសាទៅវិញ ពួកនិស្សិតបញ្ញា វ័ន្តស្អីៗ ។

ដានី ៖ ពួកនឹងគាត់ចូលក្នុងកងចល័តតំបន់ដែរ?

ឈួង ៖ បាទ! ដឹកចេញពីភ្នំពេញទាំងវទេះភ្លើង មកដល់ទម្លាក់ឲ្យចល័តតំបន់ទាំងអស់ អត់មានឲ្យនៅតាមសហករណ៍ទេ ។

ដានី ៖ ចុះក្នុងនឹងដូចថាវាមានខ្លះជាសមាសភាពអី ដូចថាគាត់ជានិស្សិត ជាមន្ត្រីរាជការខាងលន់នល់អី យើងមានបែងចែកទេ យើងដាក់ម៉េចៗ យើងប្រគល់ខាងណាដែរ ក៏យ៉ាងម៉េច?

ឈួង ៖ ទេ! អានោះ យើងមានការស៊ើបអង្កេតនេះដែរ មានការស៊ើបអង្កេតទៅ ដូចថាអ្នកដែលនៅក្នុងនោះវាមានចង្រ្កោមច្រើនៗ ដូចខាងដែលនៅជាមួយខ្ញុំផ្ទាល់អី វាមានពួកគ្រូបង្ហាត់សេអ៊ី ព្រៃសអីវាមាន ពួកបង្ហាត់ទាហានណាៗ ហើយមានពួកបញ្ញាវ័ន្ត មានពួកតួកុនតួអីស្អីៗ ខ្ញុំស្គាល់គង់ ប៊ុនឈឿន ដែលនៅជាមួយខ្ញុំ ស្គាល់ច្បាស់ៗ

ដានី ៖ គង់ ប៊ុនឈឿន អ្នកនិពន្ធនឹង?

ឈួង ៖ នោះហើយ ព្រោះខ្ញុំឃើញមុខគាត់ទៅ ប្រហាក់ប្រហែលៗ ខ្ញុំស៊ើបសួរគាត់ទៅ គាត់ថាគាត់ប្អូនគង់ សំអឿន គាត់ឈ្មោះ គង់ ប៊ុនឈឿនៗ បានខ្ញុំថាប្អូនឯងនៅ ថែរក្សាទៅរក្សាការសំងាត់ទៅបានសុខៗ ខ្ញុំគ្រាន់តែប្រាប់ប៉ុននោះៗ

ដានី ៖ ប៉ុន្តែគាត់មានផែនការមកពីលើមក មកពីខាងតំបន់ មកពីខាងមជ្ឈិមបក្សមក គាត់មានប្រាប់ឲ្យបែងចែកថា ដូចថាអ្នកដែលសមាសភាព ដូចជាខាង?

ឈួង ៖ បាទ!

ដានី ៖ ជាពួកសមាសភាពដូចជាខាងទាហានលន់ នល់, ខាងមន្ត្រីរាជការ, និស្សិតបញ្ញាវ័ន្តឲ្យយើង បែងចែក ឬក៏ឲ្យយើងយកទៅដាក់ត្រង់ណា ឬក៏ធ្វើម៉េចទេ គេមានប្រាប់មក?

ឈួង ៖ អត់ទេ អានោះកម្លាំងគេបែងចែកស្រេចហើយៗ

ដានី ៖ គេបែងចែកស្រេចម៉េចទៅ?

ឈួង ៖ គេបែងចែកមកពីនោះស្រេច កម្លាំងដែលគេបែងចែករួចហើយៗ កម្លាំងដូចថាពួកនិស្សិតបញ្ញាវ័ន្ត គេប្រគល់ឲ្យចល័តតំបន់ទាំងអស់ៗ កម្លាំងដែលវាមិនមែនទាហាន មិនមែនស្អីគេ បញ្ជូនតាមសហករណ៍ បែងចែកនោះស្រេចៗ

ដានី ៖ បែងចែកមុនស្រេច?

ឈួង ៖ ឥឡូវយើងដឹង យើងអ្នកទទួលខុសត្រូវចល័តតំបន់ យើងដឹងថាពួកដែលមកចុះមករទេះភ្លើង ទាំងប៉ុន្មាន គឺសុទ្ធតែនិស្សិតបញ្ញាវ័ន្ត គ្រូបង្រៀន ទាហាន ស្អីៗយើងដឹងទាំងអស់ អត់បាច់ ពិបាកតាមដានទេ ។

ដានី ៖ អត់ពិបាកតាមដាន?

ឈួង ៖ បាទ! ប៉ុនតាមដានក្នុងកងមួយៗមេកង មេក្រុមតាមដានថា អ្នកណាមួយដែលបន្តកម្លាំងឲ្យ បែកបាក់ ។ បើថាមិនមានបន្តកម្លាំងទេ ចេះតែលើក ចេះតែស្រឡាញ់គ្នាដូចបងដូចប្អូន ។ ប៉ុនវាមានអាខ្លះវាមានបន្តៗដូចថាចេញជាបាតុភាពចេះចុះទៅវាមានគ្រោះថ្នាក់ដល់ខ្លួន ។ បើកុំមានបន្ត អត់មានគ្រោះថ្នាក់ទេ ។

ដានី ៖ ចុះអ្នកដែលបន្តបាតុភាពនឹង យាងម៉េចទៅ យើងចាត់វិធានការយ៉ាងម៉េច ដូចថាពូជាអ្នក ថ្នាក់ដឹកនាំ?

ឈួង ៖ ទេ!រឿងអ្នកបន្តនោះ ដូចថា លើកទី១យើងហៅគេមកណែនាំ ។ ដល់ណែនាំទៅ លើកទី២ ឡើងមានទៀត យើងឈប់ណែនាំហើយ ។ យើងណែនាំតែ២ដងទេ ដល់លើកទី៣ យើង ឈប់ហើយ ។ យើងឲ្យគេណែនាំម្តង មិនដឹងគេយកទៅខាងណាយើងអត់ដឹង ។ ប៉ុនមិន ដែលមានទេ តាមដែលខ្ញុំនៅ មានតែលើកទី៣ទេ មានតែលើកទី១ទៅណែនាំទៅក៏កែប្រែ ទៅ ព្រោះគេដឹង គេចង់រស់ដែរ ។ ប៉ុនវាមានគ្រោះថ្នាក់នៅកន្លែងខ្ញុំមួយ ប៉ុនអានោះមិន មែនក្នុងអាងត្រពាំងទេ កាលដែលនៅលើកទំនប់គោករំចេក មានគ្រោះថ្នាក់មួយដោយខុស មាត់ៗដូចថាកាលនោះ កាប៉ាល់ហោះអាមេរិចកាំងនៅសៀមរាបនោះ ។ ទម្លាក់នៅសៀម រាបៗអានេះវានៅ ដូចថារៀងចាល ទៅគេត្រុគេដឹងគេចាប់ ។

ដានី ៖ គេចាប់យកទៅណា?

ឈួង ៖ ចាប់បញ្ជូនមកស្វាយទៅ ប៉ុនមិនដឹងគេយកទៅខាងណា ។ បើសិនជានៅដូចនៅជាមួយខ្ញុំសុទ្ធ តែពួកនិស្សិតច្រើនណាស់ វាអនុគ្រោះគេច្រើនណាស់ ខ្ញុំដឹងថាអ្នកនេះគេយកទៅធ្វើនេះធ្វើ នោះខ្ញុំដឹងដែរ ប៉ុន្តែកម្លាំងដែលនៅជាមួយខ្ញុំៗអត់ឲ្យអ្នកណាទៅទេ ។ សូម្បីតែឡើងឡានខ្ញុំ ទាញចេញពីឡានទៅវិញ ទាញមិនឲ្យទៅព្រោះ ។

ដានី ៖ ចឹងបើសិនជាអ្នកដែលខុស ឬក៏អីគេបញ្ជូនទៅស្វាយទេ គេមិនមែនបញ្ជូនទៅ?

ឈួង ៖ បាទ! បញ្ជូនទៅស្វាយ ។

ដានី : ស្វាយនឹងកន្លែងមន្ទីរសន្តិសុខ មន្ទីរឃុំឃាំងគេនៅស្វាយទេ?

ឈួង : បាទ!

ដានី : នៅខាងត្រពាំងថ្ម នៅខាងជាមូលដ្ឋានអត់មានកន្លែងទេ?

ឈួង : អត់មានទេ អត់មានព្រោះចល័តអត់មានកន្លែងទេ ប៉ុន្តែអ្នកដែលគ្រប់គ្រងចល័តដូចជាខ្ញុំក្តី ដូចជាតាវ៉ាល់ក្តី ខ្ញុំការពារចល័តអត់មានឲ្យគ្រោះថ្នាក់ទេ ដូចថាចល័យជួនកាលអាខ្លះមានដៃមានជើងទៅលួចដំឡូងគេតាមសហករណ៍ ឬក៏អីប្រធានសហករណ៍គេរាយការណ៍មកចាប់ខ្ញុំ អត់ទេ។ ខ្ញុំធានាទាំងអស់ ខ្ញុំមិនឲ្យគេមើលងាយចល័តទេ ព្រោះចល័តខ្ញុំហូបគ្រប់គ្រាន់មិនមានខ្វះខាត។

ដានី : ចុះពូដូចថាពេលដែល បកទៅកន្លែងត្រពាំងថ្មតិចវិញ។ កន្លែងត្រពាំងថ្មនឹង ដូចថាពេលដែលយើងធ្វើអីចឹង យើងធ្វើខ្លួនឯង ដូចអាងទឹកអាងអីនឹង យើងច្នៃធ្វើខ្លួនឯង ឬក៏មានវិស្វករ ឬក៏មានដូចថាខាងបច្ចេកទេសណាគេមកជួយ?

ឈួង : អត់ៗមានទេ តែគ្នាឯង វាតាមទិស តាមបញ្ជាការ ដូចខ្ញុំប្រាប់ថាឥឡូវក្រុមនេះ ម៉ាវរៈនេះត្រូវលើកត្រង់នេះបំស្ពានទី១ ឥឡូវដាក់ទទឹង២៥ម៉ែត្រជើងវា។ ទទឹង២៥ដូចថាយើងចោលអណ្តូតប៉ុន្មាន យើងចោល២០ បានយើងជីកអន្លុង យើងមិនមែនជីកអែបទេកាល ណាការពារដីវាធ្លាក់ទៅកុំឲ្យវាដល់អន្លុងវិញ។ ឲ្យគេលើកវែកដាក់តាមដំណើរដូចយើងធ្វើ ថ្នល់ចឹង។

ដានី : ចុះស្ពាន?

ឈួង : ស្ពាននោះ គេត្រង់ស្ពាននោះ គេយកវិស្វករមកធ្វើផ្សេង អានឹងមិនមែនពួកខ្ញុំអ្នកទទួលខុសត្រូវទេ។

ដានី : វិស្វករមកណាមក?

ឈួង : មកពីភ្នំពេញ។

ដានី : វិស្វករ កាលនឹងយើងធ្វើស្ពានប៉ុន្មាន កាលនឹង?

ឈួង : ធ្វើស្ពានទី១។

ដានី : ទី១?

ឈួង : បាទ!

ដានី : មានម៉ាស្ពាននឹងទេ?

ឈួង : ស្ពាននឹងហើយដែលធំជាងគេ។

ដានី ៖ ហើយមានស្ពានណាទៀត?

ឈួង ៖ ហើយអាតូចៗ ដូចស្ពានព្រៃមាន់ ដែលឡានដើរសព្វថ្ងៃនេះ អានោះក៏វិស្វករដែរ ។

ដានី ៖ ចឹងអាស្ពាននៅអាងត្រពាំងថ្មនឹងវិស្វករគេមកធ្វើផ្សេង?

ឈួង ៖ បាទ!

ដានី ៖ ពូអត់ស្គាល់ វិស្វករនឹងមកពីខាងណា?

ឈួង ៖ ទេ! ដើរតាមសហករណ៍នេះឯង ។

ដានី ៖ អត់ទេ នៅខាងកាលត្រពាំងថ្ម?

ឈួង ៖ នោះឯង ទៅពីសហករណ៍ ។

ដានី ៖ វិស្វករ ដែលយើងរើសពួកប្រជាជនអ្នក១៧មេសាមកពីភ្នំពេញមក?

ឈួង ៖ បាទ! នោះ ។

ដានី ៖ មកទៅធ្វើ?

ឈួង ៖ បាទ! យកពីអ្នកភ្នំពេញ ។ ចុះមកដល់យើងសួរប្រវត្តិរូបគេៗប្រាប់ហើយ គេវិស្វករនេះ វិស្វករខាងនោះៗ ។ ម្លោះហើយវិស្វករយើងហៅយកទៅធ្វើ ព្រោះយើងគ្រាន់មានប្រធាន មួយគ្រប់គ្រងគេប៉ុននោះទេ ។

ដានី ៖ ពីណាអ្នកគ្រប់គ្រង?

ឈួង ៖ តាមោង ។

ដានី ៖ តាមោង?

ឈួង ៖ អឺ! តាមោងនោះ គាត់មេជាង ដល់ហើយកូនជាងមកពីណាៗ គាត់អ្នកគ្រប់គ្រងជាងទាំងអស់ ។

ដានី ៖ តាមោងនឹង មេជាងនៅណា?

ឈួង ៖ ហ៎!

ដានី ៖ គាត់មេជាងមកពីណា?

ឈួង ៖ មេជាងនៅតំបន់៥ ជាងមោង ហៅជាងមោង ។

ដានី ៖ បាទ! គាត់មិននៅក្រោមការគ្រប់គ្រងរបស់លោកពូ ហើយតា?

ឈួង ៖ បាទ!

ដានី ៖ នៅក្រោមការគ្រប់គ្រងរបស់តាវ៉ាល់?

ឈួង ៖ បាទ!

ដានី ៖ ចុះខាងចិនអី គេអត់មានមកជួយជាបច្ចេកទេសអីទេ?

ឈួង ៖ អត់ៗ ដែលមានឃើញមុខចិន ។

ដានី ៖ អត់ដែលមានមុខចិន?

ឈួង ៖ ទេ!

ដានី ៖ អត់ដែលឃើញចិនមកទស្សនកិច្ចនៅនឹងទេ?

ឈួង ៖ អត់ទេ ដែលខ្ញុំចូលធ្វើនឹង ឃើញសម្តេចមកម្តង ។

ដានី ៖ សម្តេចមក?

ឈួង ៖ បាទ! សម្តេចមក ហើយនឹងខៀវ សំផន គាត់មក ។

ដានី ៖ ខៀវ សំផន នឹងសម្តេចមកមើលអាងត្រពាំងថ្មដែរ?

ឈួង ៖ ទេ! គាត់មកមើលទំនប់គោករំចេកដែលខ្ញុំលើក ។

ដានី ៖ ទំនប់គោករំចេក?

ឈួង ៖ បាទ!

ដានី ៖ ចុះទំនប់ត្រពាំងថ្ម?

ឈួង ៖ ត្រពាំងថ្ម គាត់អត់ដែលបានមកទេ ។

ដានី ៖ អត់ដែលមកទេ?

ឈួង ៖ បាទ!

ដានី៖ កាលនឹងសម្តេចគាត់មកជាមួយពីណា?

ឈួង ៖ សម្តេចមកជាមួយប្រពន្ធគាត់ ហើយនឹងសម្តេចប៉ែន នុត ។

ដានី ៖ សម្តេច សម្តេចមហេសី ហើយនឹងសម្តេច?

ឈួង ៖ នោះហើយ សម្តេចប៉ែន នុត ។

ដានី ៖ ៣នាក់នឹងទេ ។ ដល់ក្រោយមកខៀវសំផនគាត់ខ្លួនគាត់ទៀត?

ឈួង ៖ បាទ! ក្រោយមកខៀវ សំផន គាត់មកតែគាត់ គ្នាគាត់២-៣នាក់ដែរ ប៉ុន្តែស្គាល់ច្បាស់តែខៀវ សំផន ម្នាក់ ។

ដានី ៖ កាលសម្តេចមកឆ្នាំណា ដែលមកមើលទំនប់គោករំចេកនឹង?

ឈួង ៖ សម្តេចមកឆ្នាំ៧៦ ។

ដានី ៖ ៧៦ ខែប៉ុន្មាន?

ឈួន ៖ មើលវាត្រូវមកៗខែៗយើងភ្ជួរនេះឯង ទេ! ខែស្រូវអត់ទាន់មានស្រូវទេ រវាងខែវស្សាខែ នេះ ពីខែ៨ ខែ៩ ។

ដានី ៖ ខែ៨ ខែ៩?

ឈួន ៖ នោះឯង ។

ដានី ៖ ខែ៨ ខែ៩ឆ្នាំ៧៦នឹងមកមើល?

ឈួន ៖ បាទ!

ដានី ៖ កាលនឹងមិនទាន់ធ្វើត្រពាំងថ្ម?

ឈួន ៖ អូ! អត់ទាន់ធ្វើទេ ធ្វើតែទំនប់គោករំចេក ហើយនឹងទំនប់កំបោរ ។

ដានី ៖ អានឹងពេលដែលសម្តេចគាត់យាងមកមើលនឹង បានសំណេះសំណាលអីជាមួយប្រជាជន បានជួបពូ បាននិយាយជាមួយដែរអត់?

ឈួន ៖ អត់ទេ កាលសម្តេចមកនោះ ផែនការវាគួរឲ្យសង្ស័យ អានេះខ្ញុំនិយាយទៅវាខុសត្រូវម៉េច ខ្ញុំនិយាយតាមឃើញ ព្រោះពេលថាសម្តេចយាងមកហើយ នេះគេប្រជាជនដែលនៅអែប ថ្នល់ ពួកអាស្កម ហើមឈឺអីគេបញ្ជូនចេញពីថ្នល់ទាំងអស់ បញ្ជូនចេញឲ្យទៅនៅក្រោមិនឲ្យ មានមនុស្សណាម្នាក់ទេ ជញ្ជូនមិនឲ្យឃើញ ។ ឲ្យឃើញតែពួកនារីនៅតាមការដ្ឋាន គាមអគ្គ ភាព ពួកអ្នកដែលមានស្បែកជើងបូកាំ ដែលមានខោខ្មៅអាវខ្មៅ សុទ្ធតែអ្នកស្អាតទាំងអស់ ចេញពីក្រសួងមន្ទីរមកគីឈរ គេភ្ជួរដើរមុននឹងសម្តេចមកគេភ្ជួរស្រេច គេភ្ជួររួច ដល់ពេល សម្តេចមកដល់ពេលសម្តេចមកដល់យើងគ្រាន់តែជញ្ជូនដីនឹង លើកជាទំនប់ ជាប្រឡាយ លើកឲ្យស្តេចឃើញ ។ ដល់រៀបចំកន្លែងសាលាមួយ ឲ្យស្តេចឡើងទៅសំណាក់នៅសាលា នោះ រៀបក្រណាត់ក្រហមការភ្ញីសព្វបែបយ៉ាង ។ ដល់សម្តេចយាងមកដល់ឃើញ ខ្ញុំនៅ នោះឯងខ្ញុំនៅជ្រុងចេះ ដល់សម្តេចយាងមកដល់ឃើញរៀបចំ ទៅសម្តេចអត់ឡើងទេ ។ សម្តេចចុះដើរតំរង់មកសាលានៅអែបព្រៃមាន់នេះវិញ ។

ដានី ៖ ឡើងសាលាធ្វើអីវិញ?

ឈួន ៖ ឡើងដូចថាទៅអគ្គុយ សំរាក ទៅនិយាយអីណា ចាប់អារម្មណ៍អរគុណកូនចៅ ដែលកូនចៅ បានសប្បាយចិត្ត មានសាច់មានឈាម ស្លៀកពាក់ល្អៗវាល្អមែន ដែលសម្តេចឃើញ វា សុទ្ធតែអ្នកល្អទាំងអស់ ។ ប៉ុនអាស្កមៗគេមិនឲ្យទៅឃើញ ព្រោះប្រធានសហករណ៍បញ្ជូន ចេញអស់អាស្កមៗ ហើមអីមានឲ្យឃើញណា ។

ដានី ៖ ចុះកាលនឹងអ្នកដែលហើម អ្នកដែលធ្វើអីនឹង នៅតាមសហករណ៍?

ឈួន ៖ តាមសហករណ៍ ។

ដានី ៖ មិនមែនចល័តក្នុងភូមិ?

ឈួន ៖ អត់ទេ ចល័តអត់មានទេ ចល័តស្អាតទាំងអស់ ចល័តហៅមកមើលអាណារូបរាងល្អៗមាំទាំ ខោអាវខ្មៅ ដាក់ត្រង់ជួរ ត្រង់ក្លឹង ។

ដានី ៖ ចុះខាងដូចថាអានឹងបញ្ជាមកពីខាងណា ដែលត្រូវដូចថាយក ដូចថាអ្នកដែលហើម អ្នកស្គមស្គាំចេញ?

ឈួន ៖ អានឹងមិនដឹងខាងណាទេ ខ្ញុំអត់ដឹងទេ ដឹងថាខាងពួកខាងឃុំ ខាងស្រុកគេឯង សហករណ៍ខាងស្រុកនេះឯង ។

ដានី ៖ វាចេញពីតាហ៊ឹងអីមកដែរ?

ឈួន ៖ មិនដឹងទេ ។

ដានី ៖ អត់ដឹងទេ?

ឈួន ៖ បាទ!

ដានី ៖ ប៉ុនគ្រាន់ដឹងថាគេបញ្ជូនអ្នកហើម អ្នកអីចេញ?

ឈួន ៖ បាទ! ព្រោះនៅចល័តខ្ញុំដឹងបញ្ជាពីលើមក ថាឲ្យរៀបចំចល័តដើម្បីទទួលសម្តេច ។

ដានី ៖ កាលនឹងពូបានមានប្រសាសន៍អីសម្តេច?

ឈួន ៖ អត់ទេ អត់មានទេ សូម្បីតែគណៈតំបន់ អឺ!គណៈស្រុកអីមិនបានទៅបៀតស្តេចផង ។

ដានី ៖ ពីណាអ្នកនាំមក?

ឈួន ៖ ទេ! ឃើញមកឡាន៣ មិនដឹងខាងណាខាងណៃ អត់ស្គាល់គេអស់ ។

ដានី ៖ តាហ៊ឹងគេមកជាមួយ?

ឈួន ៖ តាហ៊ឹងឃើញមកដែរ ប៉ុនតាហ៊ឹង គាត់មកក៏មិនបានទៅបៀតស្តេចដែរ ។

ដានី ៖ ចុះតាញឹមអី មូល សម្បត្តិ?

ឈួន ៖ បាទ! មូល សម្បត្តិឃើញមកដែរ ។

ដានី ៖ មកដែរ?

ឈួន ៖ បាទ! ពូមូល សម្បត្តិនេះឯង ខ្ញុំឃើញគ្រាសម្តេច ប៉ែន នុត ចុះពីឡាន ព្រោះសម្តេច ប៉ែន នុត ចុះពីឡាន ពីព្រោះសម្តេចប៉ែន នុត គាត់ចាស់ខ្លាំង ។

ដានី ៖ ចាស់ខ្លាំង?

ឈួន ៖ បាទ!

ដានី : ចុះខៀវ សំផន គាត់មកឆ្នាំណា?

ឈួន : ខៀវ សំផន គាត់មកឆ្នាំដែលសម្ដេចមក ប៉ុន្តែគាត់មកក្រោយប្រហែលជាង២ខែ គាត់មកក្រោយ ខ្ញុំអត់ដឹងថាខៀវ សំផនទេ ព្រោះខ្ញុំនៅលើកទំនប់គោករំពេកនេះឯង ស្រាប់ដើរទៅឃើញឡានមួយឈប់ គាត់ឈរច្រត់ចង្កេះមើលលិច មើលកើត ហើយខ្ញុំដើរទៅបៀតគាត់ដែរ ។ ដើរទៅបៀត ខ្ញុំក៏ឈរមើលគាត់ គាត់ក៏ឈរមើលខ្ញុំ អត់មាននិយាយអីទេ ស្រាប់តែទៅដល់នោះ ឡានក៏ចុះឡើងភ្នំស្រុក បានគាវ៉ាល់មកដល់វិញថា "មេ៉ចឈួនៗឯងមិនឃើញទេ ខៀវ សំផន មកមិញ" ។ អូ! ខ្ញុំឃើញឡានឈប់ត្រង់នេះ ប៉ុន្តែខ្ញុំមិនដឹងនរណា ។ គាត់ថា "ខៀវ សំផន" ទៅភ្នំស្រុកហើយ ។

ដានី : គាត់ឡានតែមួយគាត់?

ឈួន : ឡានតែមួយ ។

ដានី : គាត់អត់មានបានសួរនាំអី?

ឈួន : អត់ ។

ដានី : ចុះអត់មានរៀបចំ ទទួលអីគាត់ទេ?

ឈួន : អត់ មានអ្នកណាដឹង ថាគាត់មក ។

ដានី : អត់មានដឹង អត់មានបានរៀបចំប្រជាជនអីឲ្យគាត់?

ឈួន : អត់ទេ ។

ដានី : គាត់បានមើលប្រជាជនច្បាស់លាស់ អ្នកស្គម អ្នកស្គាំអីគាត់ឃើញដែរ?

ឈួន : បាទ!

ដានី : អត់មានពីណាចាំទទួលគាត់ទេ?

ឈួន : បាទ! អត់មានបានទទួល ។

ដានី : គាត់ជិះឡានអីកាលនឹង?

ឈួន : កាលនោះឡានរបៀបដូចឡាន ឡង់គ្រីសឺរក៏មិនដឹង ឡានស្ដី ។

អ្នកជិតខាង: ឡានទាហាន?

ឈួន : ទេ! ឡានស្អាតចេះឯង ឡាន...របៀបដូចឡានពួកអន្តការចេះខ្ពស់ ។

ដានី : ពណ៌អី?

ឈួន : ពណ៌ស ។

ដានី : ពណ៌ស?

ឈួង ៖ បាទ!

ដានី ៖ គាត់មកគ្នាប៉ុន្មាននាក់?

ឈួង ៖ ខ្ញុំឃើញគាត់ចុះតែម្នាក់ទេ នៅក្នុងឡាននោះ២នាក់។

ដានី ៖ ក្នុងឡាន២នាក់?

ឈួង ៖ បាទ!

ដានី ៖ មកពេលណា ដែលគាត់ឈរមើល ពូឈរមើលគាត់ដែរនឹង?

ឈួង ៖ គាត់មកប្រហែលជាថ្ងៃម៉ោង១០កន្លះម៉ោង១១មកដល់។

ដានី ៖ ម៉ោង១០កន្លះ ម៉ោង១១ ពេលថ្ងៃ?

ឈួង ៖ ហ្នឹងហើយ ពេលថ្ងៃ។

ដានី ៖ ហើយគាត់ជិះហួសទៅភ្នំព្រឹក្សទៀតទៅ?

ឈួង ៖ ទៅភ្នំស្រុក។

ដានី ៖ តាមផ្លូវណាដែលពូ?

ឈួង ៖ ព្រៃមាន់។

ដានី ៖ ព្រៃមាន់?

ឈួង ៖ បាទ! ព្រៃមាន់ភ្នំស្រុក។

ដានី ៖ ឈរលើថ្នល់ អាថ្នល់?

ឈួង ៖ បាទ! អាថ្នល់ដែលលើកថ្មីនឹង អាកន្លែងគោករំចេក គាត់ឈរនៅនោះឯង។

ដានី ៖ នៅលើថ្នល់ជាតិ អាផ្លូវទៅក្រឡាញ់ ហើយមិនមែនទេថ្នល់ជាតិ?

ឈួង ៖ ទេ! អាផ្លូវយើងចុះទៅភ្នំស្រុក គាត់ទៅផ្លូវក្រហមទៅៗដល់គោករំចេក ដែលពួកខ្ញុំលើកទំនប់គោករំចេកនឹងទៅ គាត់ឈរមើលលើទំនប់ លើខ្នងទំនប់។

ដានី ៖ គាត់ឈរយូរទេ មើលនឹង?

ឈួង ៖ ឈរយូរ ខ្ញុំឃើញឈរយូរបានខ្ញុំដើរទៅ ហ៎!ស្មានតែតាវ៉ាល់ ឬតាហ៊ីងមកដឹង ខ្ញុំក៏ទៅចុះថាអ្នកធំមកហើយ ឯងមិនទៅមិនកើត ដល់ទៅអត់ស្គាល់។

ដានី ៖ ចុះកាលនឹងតាហ៊ីង តាអ៊ីគាត់អត់ទៅជាមួយទេ?

ឈួង ៖ អត់ទេ អត់ឃើញទៅជាមួយទេ។

ដានី ៖ ចឹងពូកាលនឹង កាលយើងលើកទំនប់នឹង ចិនអីអត់មានមកនេះ?

ឈួង ៖ អត់មានមកនេះ មិនដែលឃើញមាននរណាមក។

ដានី ៖ ចុះពេលដែលលើកទំនប់អីនឹង យើងប្រជុំអីជាមួយអ្នកចល័តដែលអីអត់ទេ ដូចយើងអ្នកដឹកនាំយើងប្រជុំ?

ឈួន ៖ ទេ! ដល់មានផែនការហើយបានយើងប្រជុំប្រាប់ ។

ដានី ៖ ប្រជុំប្រាប់?

ឈួន ៖ ហ្នឹង ប្រជុំប្រាប់ថាយើងត្រូវរៀបចំធ្វើអាងទឹក ក្រែងលត្រូវឲ្យប្រធានវរៈនីមួយៗប្រមូលកម្លាំងឯងមានប៉ុន្មាន អាណាទៅសុំទៅផ្ទះអាណាសុំទៅណែ ត្រូវប្រមូលចេញថ្ងៃនេះថ្ងៃនោះ យើងប្រាប់ថ្ងៃស្រេច ។

ដានី ៖ អានឹងយើងប្រជុំជាមួយប្រធានវរៈ កងធំកងអីនឹង?

ឈួន ៖ បាទៗ ។

ដានី ៖ ចុះជាមួយកងចល័តទាំងមូលម៉ង ទាំងរាប់ពាន់នាក់ ទាំងប៉ុន្មាន៩០០០?

ឈួន ៖ អឺ! ប្រជុំទាំងមូល គេហៅប្រជុំបើក ។

ដានី ៖ សន្និបាទ?

ឈួន ៖ បើកសមរភូមិ ។

ដានី ៖ បើកសមរភូមិ?

ឈួន ៖ បាទ! បើកសមរភូមិ គេប្រជុំទាំងអស់ ប៉ុនអានោះតាវ៉ាល់គាត់អ្នកនិយាយ គាត់អ្នកចាប់អារម្មណ៍ ។

ដានី ៖ តាវ៉ាល់?

ឈួន ៖ បាទ!

ដានី ៖ កាលនឹងអ្នកដែលចូលរួមមានតាវ៉ាល់?

ឈួន ៖ មានតាវ៉ាល់ប៉ុននោះឯង ខ្ញុំ ។

ដានី ៖ ខាងតាហ៊ុំងអី គាត់អត់មក?

ឈួន ៖ អត់ទេ ។

ដានី ៖ យើងចាប់អារម្មណ៍ថាម៉េចខ្លះទៅ ដើម្បីប្រាប់ ពួកគាត់ឲ្យដឹង ថាយើង?

ឈួន ៖ ទេ! ប្រាប់ថា អឺ!តាវ៉ាល់គាត់តែងនិយាយគាត់ របៀបដូចថាយើងផ្ដែផ្កាអីដែរណា គាត់និយាយថា“ពួកយើងទាំងអស់គ្នាសុទ្ធតែនិស្សិត បញ្ញាវ័ន្ត កុំចង់ទាមទាររកសញ្ញាប័ត្រ កុំចង់ ទាមទារបើកសាលារៀន សាលាអីណា ។ គាត់ថានាំឲ្យគ្រោះថ្នាក់ដល់ខ្លួន

ដល់យើងចង់ ឃើញសញ្ញាប័ត្រ មិត្តឯងធ្វើជាមួយខ្ញុំឲ្យកើតអានត្រពាំងថ្ម ដឹងទៅនោះហើយជាសញ្ញា ប័ត្ររបស់មិត្តឯង ។” គាត់និយាយ ។

ដានី : គាត់និយាយចឹង?

ឈួង : បាទ! ប៉ុនយើងក្តាប់គាត់ទៅ បែងចែក ពិចារណាទៅវាត្រូវដូចគាត់ថាមែន ។ អ្នកដែលទាមទារបើកសាលា ទាមទារអី ស្រាប់តែគេដឹកឡានទៅ បាត់មិនដឹងទៅខាងណា ។

ដានី : មានអ្នកទាមទារចឹងដែរ?

ឈួង : មាន ។

ដានី : ទាមទារហើយគេដឹកឡានទៅបាត់?

ឈួង : នោះហើយ ឲ្យតែអ្នកណាចង់ទាមទារចង់បើកសាលារៀន ចង់បើកស្អីៗទាមទារមានប៉ុន្មានៗ យើងធ្វើរបាយការណ៍មានទាមទារ គេមកយក ។ ដល់អាខ្លះនេះ ។

ដានី : យើងធ្វើរបាយការណ៍ឲ្យទៅអ្នកណា?

ឈួង : ទៅឲ្យគណៈតំបន់ ។

ដានី : ឲ្យគណៈតំបន់?

ឈួង : នោះហើយ ។ ដល់ហើយគណៈតំបន់គេឃើញរបាយការណ៍ទៅ ដល់ពេលត្រូវប្រជុំសន្និបាទ គេហៅពួកនោះហើយត្រូវទៅប្រជុំ ។ ដល់គេប្រាប់មកថា ត្រូវប្រជុំសន្និបាទ គេយកនិស្សិតបញ្ញាវ័ន្តទៅប្រជុំសន្និបាទ ហើយយើងអត់ដឹងម៉េចទេ ។ ដល់ហើយឡានគេមកទៅក៏ហៅពួកនិស្សិតបញ្ញាវ័ន្ត យើងក៏ប្រាប់ដែរ ឥឡូវនិស្សិតបញ្ញាវ័ន្ត ស្អែកនេះឡានគេមកយកហើយ ដែលត្រូវទៅប្រជុំសន្និបាតបើក មិត្តណាទៅគឺឡើងឡានទៅ មិត្តណាមិនទៅទេគឺនៅជាមួយខ្ញុំ ។ បើខ្ញុំៗចង់ប្រាប់បងប្អូនដែរ មិនចង់បានទេ សាលារៀនអីចង់បានសញ្ញាប័ត្រគឺធ្វើទំនប់នេះ ប្រឡាយនេះឲ្យតែកើតទៅបានសញ្ញាប័ត្រហើយ ។ ធ្វើអាខ្លះវាទៅខ្លះវាអត់ទៅ មានអាខ្លះទៅដូចថា អ្នកដែលធ្លាប់ខ្ញុំស្រឡាញ់រាប់អានស្រណោះវា ខ្ញុំដឹងតែទៅមុខ នឹងងាប់ ។ ខ្ញុំទៅទាញយកវាមកវិញ ។

ដានី : ពូធ្លាប់ទាញមកវិញដែរ?

ឈួង : នោះហើយ ។

ដានី : ឈ្មោះអីគេ ពូស្គាល់ទេ?

ឈួង : ឈ្មោះអាធឿន ។

ដានី ៖ ធឿនហ៎?

ឈួន ៖ អាធឿនៗនិងអាដល្លី ប៉ុនសព្វថ្ងៃបាត់មិនដឹងវាទៅខាងណាទៅខាងណែ។

ដានី ៖ ប៊ុនធឿន និងដល្លី?

ឈួន ៖ ហ្នឹងឯង។

ដានី ៖ គាត់មកពីណា?

ឈួន ៖ មកពីភ្នំពេញនឹងឯង ខាងអរិយក្សត្រខាងអី។

ដានី ៖ ខាងនឹង ធឿន ហើយដល្លី គាត់ធ្វើខាងអី គាត់រៀនខាងអី មុនកាលសម័យលន់ នល់?

ឈួន ៖ មិនដឹងគេរៀនខាងអីទេ ប៉ុនគេមកក្នុងចង្កោមនិស្សិតបញ្ញាវ័ន្តនេះឯង។

ដានី ៖ ដល់ពេលបែកៗ៧៩នេះហើយមានដែលជួបគាត់ទេ?

ឈួន ៖ អត់ដែលជួបទេ។

ដានី ៖ អត់ដែលជួប?

ឈួន ៖ ព្រោះវាបែកគ្នាជាមួយខ្ញុំ តាំងពីខ្ញុំចុះទៅធ្វើប្រធាននេសាទ ទៅវាបែកមិនទៅនៅជាមួយគេ មិនដឹងសុខទុក្ខវាយ៉ាងម៉េច ខ្ញុំអត់ដឹងដែរ។

ដានី ៖ ចុះពូទៅធ្វើប្រធាននេសាទនឹងឆ្នាំណា ខែប៉ុន្មាន?

ឈួន ៖ ទៅនៅខែ៨ខ្ញុំទៅ។

ដានី ៖ ខែ៨?

ឈួន ៖ បាទ!

ដានី ៖ ខែ៨ឆ្នាំ៧៧?

ឈួន ៖ ៧៧។

ដានី ៖ ទៅធ្វើនេសាទ?

ឈួន ៖ បាទ!

ដានី ៖ ចុះពូកាលនឹង ពេលខែ៨ឆ្នាំ៧៧នឹង កាលនឹងមានដូចថាយើងមានជ្រួលច្របល់អីនៅ ថាពួកខាងនិរតីគេចូលមកនៅ?

ឈួន ៖ នៅអត់ទាន់ចូលមកទេកាលនឹង។

ដានី ៖ អត់ទាន់ចូលមកទេ?

ឈួន ៖ បាទ! ចាំមើលខ្ញុំទៅបានប្រហែល២ខែ បានពួកបស្ចឹមគេមក។

ដានី ៖ ខាងបស្ចឹម មិនមែនខាងនិរតីទេ?

ឈួង ៖ បាទ! បស្ទីម ។

ដានី ៖ ខាងបស្ទីមមក?

ឈួង ៖ បាទ! បស្ទីមមកៗនេះ ក្នុងនាមបស្ទីមមកនេះ គេមិនមែនមកក្តាប់យើងដែរ គេមករស់នៅ តាមចល័ត រស់នៅតាមសហករណ៍តាមភូមិ ។ ម៉ាភូមិគេដាក់៣នាក់ៗ ហើយចល័ត៤-៥នាក់ ទៅម៉ាវរៈៗទៅ ប៉ុននៅយើងក្តាប់ដដែល ។

ដានី ៖ ចឹងកាលពូទៅនេសាទ ទៅធ្វើជាប្រធាននេសាទតំបន់៥នឹង កាលនឹងមិនមែនខាងនិរតីគេបញ្ជូន ទៅខាងពីណាគេអ្នករៀបចំពូទៅ?

ឈួង ៖ចេះ! កាលនោះតាវ៉ាល់ចាត់តាំងខ្ញុំ តាវ៉ាល់ខាងយើងពាយ័ព្យនេះ ឃើញថាចល័តយើងត្រីដឹកមកពីសៀមរាប យកមកឲ្យហូបៗវាអត់គ្រប់ ។ ដល់ហើយឲ្យខ្ញុំដកកម្លាំងទៅធ្វើនេសាទ ព្រោះនេសាទដែលរៀបចំនៅប៉ុន្មានក្រោមនេះ ឲ្យខ្ញុំប្រមូលធ្វើនៅតែម៉ាក្រុម ។ បានខ្ញុំរៀបចំទៅធ្វើនេសាទ ដើម្បីយកត្រីដោះស្រាយចេះមក បានប្រហែល២ខែ ពួកនិរតីមកពាយ័ព្យគេមក ។ ដល់ពាយ័ព្យគេមកនេះ មកបានតែរយៈពេលប្រហែលជា២ខែជាង បានខាងនិរតីមកចាប់តាវ៉ាល់ ។

ដានី ៖ ចឹងតាវ៉ាល់គាត់ចាត់តាំងពូឲ្យធ្វើនេសាទ ខាងដឹកជញ្ជូន ដោយសារត្រីមកពីខាងសៀមរាប គេដឹកមកអត់នេះ?

ឈួង ៖ បាទ!

ដានី ៖ ហើយកាលនឹងពេលពូទៅនឹង ពួកខាងបស្ទីម កាលនឹងពួកបស្ទីម ហើយពួកនិរតី?

ឈួង ៖ ពួកបស្ទីមមកមុន ។

ដានី ៖ ពួកបស្ទីមមកមុន?

ឈួង ៖ បាទ!

ដានី ៖ មក?

ឈួង ៖ មកនៅតាមសហករណ៍តាមកង តាមអី មកនៅក្នុងចល័ត ។

ដានី ៖ កាលនឹងពួកបស្ទីមមកខែណា?

ឈួង ៖ មកខែយើងស្ទូងកាលនោះ ។

ដានី ៖ ខែស្ទូងខែ?

ឈួង ៖ ខែស្ទូងខែ៧ ខែអី ។

ដានី ៖ ខែ៧ ខែអី ខែ៧ ៧៧នឹង?

ឈួន ៖ បាទ!

ដានី ៖ កាលនឹងពួកបស្ចឹមមក កាលពូទៅខែ៤នឹងបាន២ខែៗ ពួកបស្ចឹម ហើយពួកប្អូកពួកនិរតី ដែលចាប់ៗតា?

ឈួន ៖ បាទ!ពួកបស្ចឹម ទេ!ពួកបស្ចឹមមកៗបានប្រហែលជា២ខែ បានគេចាប់តាវ៉ាល់ៗ បាននិរតីមកចាប់តាវ៉ាល់បណ្ដោយៗ

ដានី ៖ ចឹងពួកមកពីនឹង ពួកបស្ចឹមផង ពួកនិរតីផង បាន?

ឈួន ៖ បាទ! ព្រោះពួកបស្ចឹមគេមកមុនៗ

ដានី ៖ ពួកបស្ចឹមគេមកមុន?

ឈួន ៖ បាទ!

ដានី ៖ ចឹងកាលទៅខាងនេសាទ ប្រធាននេសាទតំបន់៥នឹង ពូទៅតែម្នាក់ឯងទេ?

ឈួន ៖ បាទ!

ដានី ៖ ចុះតាយឿក?

ឈួន ៖ តាយឿក គាត់នៅកាន់អង្គរបហូត កាន់នៅ ព្រោះអីដូចថាគេចាប់តាវ៉ាល់ហើយ គេផ្លាស់ៗ ប្រធានចល័តតំបន់ណាៗ ផ្លាស់ប្រធានចល័តតំបន់ទៅ កាលនឹងតាចេងឲ្យតាចេងធ្វើ ប្រធានចល័តតំបន់២នាក់តាពាល់ៗ ហើយដល់ខ្ញុំៗបានត្រឹមកខ្ញុំយកមកឲ្យគាត់នេះឯង នៅក្នុងអង្គភាពដដែលៗ

ដានី ៖ ចឹងគេចាប់តាវ៉ាល់ខែប៉ុន្មាន?

ឈួន ៖ អឺ! រកចាំខែមិនបានៗ

ដានី ៖ ពូទៅខាងនេសាទតំបន់ខែ៤?

ឈួន ៖ បាទ! ខែ៤ ខែ៧ ខែ៨ បានគេ ខែ១០ ខែ១១នេះឯងចាប់តាវ៉ាល់ៗ

ដានី ៖ ខែ១០ ខែ១១ ៧៧នឹង?

ឈួន ៖ បាទ!

ដានី ៖ ចឹងពូទៅបានយូរដែរ ទៅខាង?

ឈួន ៖ បាទ!

ដានី ៖ ខែ១០ ខែ១១ៗ មុននឹងគេចាប់ គេមានមកនៅជាមួយតាវ៉ាល់ដូចពួកខាងនិរតីគេមក?

ឈួន ៖ ទេ! អត់មាននៅជាមួយទេៗ

ដានី ៖ អត់?

ឈួង ៖ អត់ ។

ដានី ៖ ពួកខាងបស្ចឹមមកខ្វង់ខែ៧ ៧៧?

ឈួង ៖ បាទ!

ដានី ៖ ខែ៧ ៧៧នឹង ដល់ពេល២ខែក្រោយពួកនិរតីមកម៉ាសារទៀត?

ឈួង ៖ បាទ! ពួកនិរតីមក ។

ដានី ៖ បាទ! ពេលពួកនិរតីមកនឹង មកក្នុងសភាពយ៉ាងម៉េច ពួកបស្ចឹម ពូមានប្រសាសន៍មិញថា មកនៅ២ ៣នាក់ មកនៅតាមសហករណ៍?

ឈួង ៖ បាទ! អានោះមកនៅចូលតាមសហករណ៍នោះ មកនៅចូលដូចថាធ្វើជាប្រជាជនតាមធម្មតា អត់មានធ្វើប្រធានអីទេ ។

ដានី ៖ បាទ! ដល់ពេលពួកនិរតីមក?

ឈួង ៖ ពេលពួកនិរតីមក បានតែងតាំងពួកនេះធ្វើប្រធាន ពួកបស្ចឹមធ្វើប្រធានសហករណ៍ ធ្វើប្រធានអីៗ ។ និរតីគេអ្នកតែងតាំង ។

ដានី ៖ និរតីដែលមកនេះ គេមកតែងតាំង?

ឈួង ៖ បាទ!

ដានី ៖ ហើយខ្លួនគេៗធ្វើអី?

ឈួង ៖ ខ្លួនគេធំៗជាងនោះទៅទៀត ។

ដានី ៖ ធំជាងនឹងទៅទៀត?

ឈួង ៖ បាទ!

ដានី ៖ ខ្លួនគេធំៗ គេមានតួនាទីអីដែរ ធំជាង?

ឈួង ៖ ដូចថាគេចល័តតំបន់ ទៅដល់គេមកគ្រប់គ្រងចល័តតំបន់ អ្នកដែលគ្រប់គ្រងចល័តតំបន់មុននោះ ដែលគេចាប់ទៅហើយ គេឲ្យដូចថាឲ្យតានេះដែលមកពីបស្ចឹម ។ ឲ្យតានេះគ្រប់គ្រងចល័តតំបន់ ។ ប៉ុនដល់គេៗក្តាប់ពីលើតានេះ ។

ដានី ៖ គេអត់មានបញ្ចេញថាគេចល័តទេ ប៉ុន្តែគេអាចគ្រប់គ្រងពីលើនឹងទៅទៀត?

ឈួង ៖ បាទៗនឹងហើយ ។

ដានី ៖ ចឹងនៅចល័តតំបន់ គេចាប់តែតាវ៉ាល់មួយទេ?

ឈួន ៖ ទេ! ចាប់តាវ៉ាល់មួយ ហើយក្នុងចង្កោមចល័តនោះគេចាប់ទាំងអស់ ប៉ុនអាខ្លះវារត់ ខ្លះអី តាំងពីប្រធានវរៈ ប្រធានអី អាក្រោមៗខ្ញុំវារត់អស់ រត់ទៅងាប់ប្រសេប្រសាចដឹងទៅខាងណាខាងណៃ ។

ដានី ៖ ចឹងតាវ៉ាល់ កាលនឹងពួកនិរតីចាប់ក៏ដោយសារ គេចោទគាត់ថាម៉េច?

ឈួន ៖ ទេ! ដែលគេថាគាត់ក្បត់នឹង ។

ដានី ៖ គេថាគាត់ក្បត់?

ឈួន ៖ នោះហើយ ។

ដានី ៖ កាលនោះពូមានដឹងសកម្មភាពអីក្បត់អីយ៉ាងម៉េចដែរ?

ឈួន ៖ អត់ ខ្ញុំអត់ដឹង ។

ដានី ៖ អត់ដឹងទេនោះ?

ឈួន ៖ អឺ!

ដានី ៖ គាត់ក្បត់មែន ឬក៏គេចេះចោទគាត់?

ឈួន ៖ តាមខ្ញុំនិយាយ ពួកនេះវាអត់ត្រូវគ្នា ។

ដានី ៖ អត់ត្រូវគ្នា?

ឈួន ៖ បាទ! ពួកអត់ត្រូវគ្នា ប៉ះនិយាយទៅវាប៉ះពាល់ខ្លាំងទៅខ្លាចវាម៉េចៗ ។

ដានី ៖ អត់ទេ ពូនិយាយទៅតាមអីដែលពូដឹង អត់មានប៉ះពាល់អី ។

ឈួន ៖ ព្រោះតាហ៊ីង ហើយនឹងតាវ៉ាល់នេះ គាត់ត្រូវគ្នា ដូចជាបក្សផ្សេង ហើយតាជៀល អាជៀល តាញឹមអីនេះ ដូចបក្សផ្សេង ។ ព្រោះបានខ្ញុំដឹងថាបក្សផ្សេង ព្រោះតាហ៊ីង និង តាវ៉ាល់នេះ គាត់បញ្ជាក់ប្រាប់ខ្ញុំម្តងហើយថា “កងចល័តទាំងអស់ ពេលដែលឡើងទៅកាប់ កប្បាសនៅភ្នំកងវ៉ា គាត់ដាំចំការកប្បាសណា ។ គាត់នឹងបំពាក់អាវុធឲ្យទាំងអស់ ។ បំពាក់ អាវុធឲ្យ យើងនាំគ្នាទៅថៃរត់ទៅថៃ” ។ រត់ទៅថៃ រហូតឲ្យខ្ញុំទៅមើលផ្លូវ បានដល់ពេល ដែនការនោះ ខាងមូល សម្បត្តិ គេដឹង ខាងតាញឹមៗហៅមូល សម្បត្តិនេះ ពួកអាជៀល គេដឹងទៅ គេតាមដានរហូត ។ ពួកនោះឯងចាប់ពួកតាវ៉ាល់ ។

ដានី ៖ អូ! ចឹងទេ?

ឈួន ៖ បាទ! មិនមែនពួកនិរតីទេ ។

ដានី ៖ មិនមែនពួកនិរតីចាប់?

ឈួន ៖ អត់ទេ គ្នាឯង ។

ដានី ៖ ចុះជៀល នឹងមកខាងតំបន់ពេលណា?

ឈួង ៖ ជៀលនឹងមកៗតំបន់ មកដូចថា ។

ដានី ៖ មកតំបន់៥?

ឈួង ៖ បាទ! មកនោះក៏វាមិនមែនធ្វើគណៈតំបន់ ដូចថាគេអាងគេកូនអ្នកធំទៅ មកគណៈតំបន់ក៏ត្រូវខ្លាចវាដែរ ។

ដានី ៖ គាត់ជាអនុរបស់តាហ៊ីងទេ?

ឈួង ៖ ហ្នឹងហើយ ប៉ុន្តែយើងក៏ត្រូវខ្លាចវាដែរ ។

ដានី ៖ គាត់មកឆ្នាំណា?

ឈួង ៖ គាត់មកឆ្នាំ៧៧ ។

ដានី ៖ មក៧៧ហើយទេ?

ឈួង ៖ បាទ! ៧៧ មកម៉ាសេរី ពួកបស្ចឹមមកនេះឯង ។

ដានី ៖ ចឹងកាលពីដំបូងមក តែតាហ៊ីងម្នាក់?

ឈួង ៖ បាទៗ ។

ដានី ៖ ដល់ពេលជៀលនឹង មកឆ្នាំ៧៧?

ឈួង ៖ បាទ!

ដានី ៖ មក៧៧នឹង ចុះពូមានប្រសាសន៍មិញថា តាវ៉ាល់គាត់ថា គាត់ប្រុងបំពាក់អាវុធឲ្យថា ប្រុងវត់ទៅថៃនឹងឆ្នាំណា?

ឈួង ៖ អានោះឆ្នាំ ដែលចប់ទំនប់កំបោរ ឆ្នាំ៧៦ៗវាចូលចុងខែហើយ ចុងខែចង់ដាច់ហើយ ចង់ចូលខែ១១ ខែ១២នេះហើយ ។ ព្រោះខែ១១ ខែ១២ យើងជិតគោកទឹកហើយ ។

ដានី ៖ ចឹងមុនលើកត្រពាំងថ្ម?

ឈួង ៖ មុន មិនទាន់រៀបចំត្រពាំងថ្មទេ ។

ដានី ៖ ចឹងគាត់ថាប្រុងរៀបចំបំពាក់អាវុធថាទៅថៃនឹង មុនៗ?

ឈួង ៖ មុនៗអាងត្រពាំងថ្ម ។

ដានី ៖ ចុងឆ្នាំ៧៦?

ឈួង ៖ បាទ! ដល់ពេលផែនការនឹងអត់ដំណើរការទៅ បានស្ងួបវិញទៅ ។

ដានី ៖ ម៉េចបានផែនការអត់ដំណើរការ គេដឹង?

ឈួន ៈ	បែបយើងរៀបកម្លាំងវាមិនស្រុះ វាមិនបានស្រួល គេដឹង ៗ បានគេដឹង បានតាព្រំ គេរត់ទៅមុន ៗ

ដានី ៈ	តាណា?

ឈួន ៈ	តាព្រំ ៗ

ដានី ៈ	តាព្រំ គាត់ធ្វើអី?

ឈួន ៈ	តាព្រំ គាត់គណៈភូមិភាគ ផ្នែកកងទ័ព គាត់កាន់កងទ័ពម៉ាភូមិភាគពាយ័ព្យ ៗ

ដានី ៈ	ឈ្មោះ?

ឈួន ៈ	តាព្រំ ៗ

ដានី ៈ	តាព្រំ?

ឈួន ៈ	បាទ!

ដានី ៈ	មិនមែនតាខ្វែង?

ឈួន ៈ	ទេ! ព្រោះតាព្រំ ៗ

ដានី ៈ	ចុះពូស្គាល់តាខ្វែងអត់?

ឈួន ៈ	អត់ ៗ

ដានី ៈ	តាខ្វែង គាត់កាន់យោធា គាត់កាន់យោធាភូមិភាគ?

ឈួន ៈ	អត់ ខ្លាចតាខ្វែងដឹង ខ្ញុំស្គាល់តែតាព្រំៗ ៗ

ដានី ៈ	តាព្រំៗ?

ឈួន ៈ	នោះហើយ គាត់បើកឡានរត់ចេញទៅផ្លូវប៉ោយប៉ែត ៗ

ដានី ៈ	គាត់ទៅមុនបាត់ទៅ?

ឈួន ៈ	ទៅមុន ៗ

ដានី ៈ	គាត់រួចខ្លួន?

ឈួន ៈ	បាទ! នាំថៅកែយ៉ែរៗទៅ ៗ

ដានី ៈ	អូ! នាំថៅកែយ៉ែរទៅដែរ?

ឈួន ៈ	បាទ!

ដានី ៈ	ថៅកែយ៉ែរ គាត់នៅណា?

ឈួន ៈ	ថៅកែយ៉ែរនៅមង្គលបូរី ៗ

ដានី ៈ	មង្គលបូរី?

ឈួង ៖ នោះ ។

ដានី ៖ ចៅកែយ៉រនឹង គាត់កាលពីមុន ព្រៃអីនៅម៉ាម្ខាងជួរ?

ឈួង ៖ បាទ! ព្រៃគុប ព្រៃអីនោះ សុទ្ធតែរបស់គាត់ ។

ដានី ៖ ព្រៃគុបពីត្រង់ណាដល់ត្រង់ណា?

ឈួង ៖ ទៅខាងគុតតាសិត ខាងម៉ាខ្សែ ខាងម៉កហឹន ។

ដានី ៖ សុទ្ធតែព្រៃរបស់គាត់?

ឈួង ៖ សុទ្ធតែព្រៃគាត់ ។

ដានី ៖ ខាងព្រៃម៉ក់ហឹន ខាងម៉ាខ្សែ នឹងសុទ្ធតែព្រៃរបស់ចៅកែយ៉រ?

ឈួង ៖ បាទ!

ដានី ៖ ចឹងចៅកែយ៉រ គាត់រត់ទៅថៃទេ មិនមែនគេសម្លាប់នៅនឹងទេ?

ឈួង ៖ រត់ទៅថៃ គាត់ទៅជាមួយតាព្រំនេះ តាព្រំនេះយកគាត់ទៅ ។

ដានី ៖ ឆ្នាំណា?

ឈួង ៖ ឆ្នាំ៧៧នេះឯង ។

ដានី ៖ ៧៧?

ឈួង ៖ បាទ!

ដានី ៖ ចឹងជៀល គាត់មកកគណៈតំបន់នឹងឆ្នាំនឹងទេ គាត់មក?

ឈួង ៖ បាទ! គាត់មកក្រោយទេ ។

ដានី ៖ ចំណាស់ណា ជៀលនឹង?

ឈួង ៖ ក្មេងៗ កំលោះមិនទាន់បានប្រពន្ធណា មកនឹង ។

ដានី ៖ កាលមកនឹងអត់ទាន់មានប្រពន្ធទេ?

ឈួង ៖ ទេ! ចាំមើល តាមូល សម្បត្តិ និងតាសោ ភីមៗ គាត់គណៈភូមិភាគបូព៌ា គាត់មានកូនក្រមុំ ហើយគាត់នឹងតាញឹមនេះ គាត់ពួកម៉ាក់គ្នា ។ ដល់ហើយគាត់ចង់ឲ្យកូនគាត់ និងកូនគាត់នោះបានគ្នា ។

ដានី ៖ ហើយបានដែរអត់?

ឈួង ៖ ដឹង ខ្ញុំអត់ដឹងដល់ដែរ ត្រង់នេះបានដឹង គេអ្នកធំដូចគ្នា ។

ដានី ៖ ប៉ុន្តែកាលនឹងជៀលមកខាងនេះនឹង អត់ទាន់ការទេ?

ឈួង ៖ ទេ! អត់ទាន់មានប្រពន្ធទេ ។

ដានី ៖ ចឹងអាយុតិចជាពូ?

ឈួង ៖ បាទ! អាយុតិច ។

ដានី ៖ អាយុតិច ។ ចឹងដល់ពេលអ្នកចាប់តាវ៉ាល់នឹង ខាងក្រុមរបស់ជៀល ក្រុមរបស់តាញឹម របស់មូល សម្បត្តិ ទេ អ្នកចាប់?

ឈួង ៖ បាទៗ អត់មានពួកនិរតីទេ ។ ដំណើរពួកនិរតីមកជួយមិនទាន់ ។

ដានី ៖ មកជួយអត់ទាន់?

ឈួង ៖ នោះហើយ ដំណើរខ្ញុំមើលទៅ អ្នកនេះ ខ្ញុំមិនមែនកាន់ជើងទេ តាមដែលសភាពការណ៍ដែលធ្លាប់រស់នៅជាមួយគាត់ នៅរឿងប្រជាជនរឿនអីគាត់និយាយមកមានល្អណាស់ ។ សូម្បីតែនិស្សិតបញ្ញាវ័ន្ត គាត់ហៅធ្វើការសំងាត់ នេះតាហ៊ីងនេះ ។ សុទ្ធតែពួកនារីស្រីៗដែលចេះៗ ហៅធ្វើការសំងាត់ទាំងអស់ ហើយរួចឲ្យមកនៅការចល័តវិញជាមួយគ្នានឹងខ្ញុំវិញដដែល ។

ដានី ៖ អូ! ចឹង?

ឈួង ៖ បាទ! បានខ្ញុំថាមនុស្សនេះមិនល្អ ប៉ុន្តែដល់ពួកគេមិនល្អនោះ គេឃើញថាសកម្មភាពគាត់បែបមិនស្រួល គេឆាប់កំចាត់មុន ។

ដានី ៖ ចុះគេចាប់គាត់ទៅណាទៅ តាវ៉ាល់តា?

ឈួង ៖ មិនដឹងគេចាប់ទៅណា ខ្ញុំអត់ដឹងដែរ ។

ដានី ៖ អត់ដឹងដែរ?

ឈួង ៖ បើគេចាប់តាំងពីគណៈស្រុក ចាប់តាំងអីណា មិនមែនចាប់តែតាវ៉ាល់ទេ ។

ដានី ៖ ចាប់ពីណាគេខ្លះ?

ឈួង ៖ ចាប់តាមោង ចាប់តាសំអាត ចាប់តាវ៉ាល់ ក្រោយមកចាប់ពួកប្រធានភូមិ ពួកអីនេះ ពួកនិរតីក្រោយចាប់ទេ ។

ដានី ៖ ចឹងខាងគណៈស្រុក តាមោង តាសំអាត ខាងតាហ៊ីងនឹង គឺខាងតាញឹមអ្នកចាប់ទេ?

ឈួង ៖ បាទ!

ដានី ៖ ដល់ចាប់ទៅ ដល់ពេលដូចតាមោងអី គេតែងតាំងពីណាជំនួសគាត់?

ឈួង ៖ ដល់ចាប់ទៅនេះ ពួកអាជៀលនេះ គេប្រុងតែងតាំងខ្លួនគេ ធ្វើគណៈតំបន់ ។ ហើយក្រោយ មក ប្រុងតែងតាំងចៅហ្វាយស្រុកចៅហ្វាយអី ប៉ុនតែងតាំងអត់ទាន់ពួកនិរតីគេមក និរតី គេដាក់ចៅហ្វាយស្រុក គណៈតំបន់ស្រេច ។

ដានី ៖ អូ! ចឹងដល់ពេលចាប់ហើយ គណៈតំបន់ពីណាវិញទៅ ដល់ហ៊ីងគេចាប់?

ឈួង ៖ ចាប់ហ៊ីង អាជៀលនេះហើយ គេគណៈតំបន់ខ្លួនគេ។ ដល់ពេលនៅរៀបចំស្រុក មិនទាន់បានរៀបចំស្រុក ពួកនិរតីមកដល់បាននិរតីរៀបចំស្រុករៀបចំអីឲ្យ យាយថែម ធ្វើចៅហ្វាយស្រុក។ យាយថែម ធ្វើគណៈស្រុកភ្នំស្រុក អូ! គណៈស្រុកព្រះនេត្រ។

ដានី ៖ យាយថែមធ្វើគណៈស្រុកព្រះនេត្រព្រះ?

ឈួង ៖ នោះហើយ។

ដានី ៖ ដល់ពេលគណៈតំបន់?

ឈួង ៖ គណៈតំបន់តារិន។

ដានី ៖ រិន?

ឈួង ៖ រិន មកពីនិរតី។

ដានី ៖ ឈ្មោះ រិន មកពីនិរតី?

ឈួង ៖ បាទ! ឈ្មោះ រិន។

ដានី ៖ ឈ្មោះរិន ឈ្មោះអីរិន?

ឈួង ៖ មិនដឹងស្អីទេ នាមត្រកូល ខ្ញុំមិនសូវដែលចាំ។

ដានី ៖ ចឹងកាលពីចាប់ៗ។ ចឹងតាវ៉ាល់ ហើយតាហ៊ីង គេចាប់ជាមួយគ្នា?

ឈួង ៖ បាទ!

ដានី ៖ ថ្ងៃ?

ឈួង ៖ ទេ! ចាប់តាហ៊ីង មុន។

ដានី ៖ តាហ៊ីង ចាប់ពីអង្កាល់?

ឈួង ៖ មុនគ្នាប្រហែលជា២-៣ថ្ងៃនោះឯង មិនមែនតែមុនរាប់ខែទេ។

ដានី ៖ អូ! ចឹងក្នុងចន្លោះខែ១០ ខែអីនឹង?

ឈួង ៖ នោះហើយចន្លោះខែដដែលនោះឯង។

ដានី ៖ ដល់ពេលចាប់ទៅ ជៀល នឹង ធ្វើគណៈតំបន់ម៉ារយះ?

ឈួង ៖ នោះហើយ បាទ! ។

ដានី ៖ ដល់ពេលគណៈស្រុកអីនឹង គេអត់ទាន់មាន?

ឈួង ៖ មិនទាន់បានរៀបទេ។

ដានី ៖ អត់ទាន់បានរៀបទេ?

ឈួង ៖ នោះហើយរៀបមិនទាន់ ពួកនិរតីគេមកដល់ ។

ដានី ៖ ពួកនិរតីគេមកដល់?

ឈួង ៖ នោះហើយមកដល់គេរៀបខ្លួនគេទៅ ។

ដានី ៖ បានគេរៀបតារិននឹង?

ឈួង ៖ គណៈតំបន់ ។

ដានី ៖ ពូស្គាល់គាត់ដែរ តារិននឹង?

ឈួង ៖ តារិននឹង ខ្ញុំភ្លេចគាត់ហើយ ខ្ញុំដូចថាពេលនោះ ដូចថាមិនបានជិតដល់នឹងគាត់ដែរណាពេល ខ្ញុំឡើងមកម្តងៗក៏បានជួបគាត់ បានដេកជាមួយគាត់ម៉ាយប់ទៅ ក៏ចុះទៅវិញទៅ ។ ព្រោះ គាត់នេះឯង គាត់រៀបចំខ្ញុំឲ្យធ្វើប្រធាននេសាទតំបន់៥ ។

ដានី ៖ ហាំ! ក្រែងពូទៅមុននឹងទៀត?

ឈួង ៖ ទៅមុន ប៉ុនទាន់បានឡើងនេសាទតំបន់៥ទេ ខ្ញុំគ្រាន់តែគេហៅថានេសាទចល័តតំបន់ ។

ដានី ៖ ចល័តតំបន់?

ឈួង ៖ បាទ!

ដានី ៖ នេសាទចល័តតំបន់?

ឈួង ៖ ដល់ពេលនេសាទតំបន់៥នេះឈ្មោះ អាជិន នៅស្រុកក្រោយនេះវាខុសសីលធម៌ៗបានពួកនិរតីគេចាប់ទៅនេះ បានតែងតាំងខ្ញុំទៅធ្វើប្រធាននេសាទតំបន់៥ ជាមួយតាចេង ។ ហើយតាចេងនោះ គាត់ធ្វើប្រធាន ខ្ញុំអនុប្រធាន ។ តាចេង គាត់មកពីនិរតី កំបុតមេដៃមួយ ។ ដល់គាត់មកពីនិរតី គាត់ថា *"ឈួងអើយ ខ្ញុំប៉ែកខាងក្រោមស្រេចតែឈួងឯងទៅ ទូកកាណូត ស្អីៗខ្ញុំមិនហ៊ានប៉ះទឹកទេ ខ្ញុំខ្លាចទឹកណាស់"* ។ គាត់សុខចិត្តនៅស្វាយនេះ គាត់នៅស្វាយនេះ គាត់នៅលើកគោកនេះ បើថាខ្ញុំខុះខាតអីរាយការណ៍មកគាត់ ដឹកជញ្ជូនអីគាត់អ្នកដោះស្រាយពីនេះទៅឲ្យ ។ ហើយខ្ញុំនៅខាងក្រោមលើខ្ញុំទាំងអស់បាន ។

ដានី ៖ ចឹងគាត់អត់ហ៊ានចុះទឹក គាត់ខ្លាចទឹក?

ឈួង ៖ បាទ! គាត់ខ្លាចទឹក ។

ដានី ៖ គាត់អត់ចេះហែលទឹក មើលទៅ?

ឈួង ៖ គាត់អ្នកស្រុកគោក ដំណើរ ។ ឈ្មោះ តាចេង កំបុតមេដៃ ។

ដានី ៖ ចឹងគាត់ឲ្យពូធ្វើប្រធាន?

ឈួង ៖ បាទ!

ដានី ៖ គាត់ទទួលខាងសេដ្ឋកិច្ច?

ឈួង ៖ បាទ! នោះឯង ខាងលើ ។

ដានី ៖ ចឹងកាលពីគេចាប់ ខ្ញុំចង់ដឹងតិចទាក់ទងជៀល ។ ចឹងគេចាប់តាហ៊ីងទៅបានរយៈពេលប៉ុន្មាន ដែលតាជៀលនឹងគាត់ធ្វើជាគណៈតំបន់?

ឈួង ៖ អាជៀលទៅធ្វើគណៈតំបន់នោះ គេមកធ្វើមិនទាន់ចាប់តាហ៊ីងទេ មកមុនៗ ដល់មកទៅ តាហ៊ីងនោះ ប្រធាន គេអនុ មកយើងនៅមិនបានដល់ ប្រហែលជា២ខែនេះឯង បានចាប់ តាហ៊ីង ។

ដានី ៖ បានចាប់តាហ៊ីង?

ឈួង ៖ បាទ! ចាប់តាហ៊ីង ។

ដានី ៖ ដល់ពេលចាប់តាហ៊ីងបានរយៈពេលប៉ុន្មាននោះ បាន?

ឈួង ៖ ចាប់តាហ៊ីង បានប្រហែលជាម៉ាអាទិត្យ បានចាប់តាវ៉ាល់ៗ ចាប់តាមោង តាសំអាតអី ។

ដានី ៖ តែចន្លោះនឹង មុនពេលដែលនិរតី ដែលតារិនមកធ្វើគណៈតំបន់នឹង?

ឈួង ៖ បាទ! មុនៗ

ដានី ៖ យូរទេ ប្រហែលជា តារិន មកធ្វើគណៈតំបន់?

ឈួង ៖ តារិន មកធ្វើគណៈតំបន់ បានប្រហែលជា អាជៀលគេធ្វើការប្រហែលបានជា៣ខែ នោះកំពុងឡានស មួយដើរចាប់ហើយ នោះកំពុងដើរចាប់ ។

ដានី ៖ កំពុងដើរចាប់?

ឈួង ៖ បាទ! ដើរចាប់ចល័តចាប់ចល័តអី អាណាកាច អាណាស្លូត ដើរចាប់ហើយ ។ រហូតដល់ទៅចាប់នៅកន្លែងខ្ញុំ ចាប់តាម៉ែនដែលនៅជាមួយខ្ញុំ ។ តាម៉ែននោះ ចាំមើលខ្ញុំនិយាយទៅកាន់ តែវែងទៀត ។ តាហាត់ គាត់គណៈស្រុកភ្នំស្រុក ដល់អាជៀលគេចាប់តាហាត់ ។ ដល់តា ម៉ែននោះបងតាហាត់ រកចាប់តាម៉ែនដែរ ដល់តាម៉ែនភ័យរត់ទៅនៅជាមួយខ្ញុំ ។ ដល់រត់ទៅ នៅជាមួយខ្ញុំ ទៅគេដឹងតាម៉ែនទៅនៅជាមួយខ្ញុំ គេឲ្យតាយឿកនេះទៅតាមខ្ញុំជាមួយតាម៉ែន មករៀនសូត្រ ។ ដល់ខ្ញុំ តាយឿកដឹងរឿងគេចាប់តាម៉ែន ប៉ុនអត់ប្រាប់ខ្ញុំទេ ។ ទៅដល់ថា និយាយឲ្យខ្ញុំថាឲ្យរៀនសូត្រ ដល់ខ្ញុំថាមករៀនសូត្រទៅក៏ទៅហោមកក៏ ខ្ញុំក៏មកៗនាំគ្នាជិះកង់មក ។ មកដល់ស្រុកភ្នំស្រុក ពួកនិរតី គេនៅយាមនឹងស្ពាន គេដាក់កុងត្រូយាមទៅ តាយឿក ជិះកង់ដល់មុន តាម៉ែន ជិះកង់ក្រោយ ខ្ញុំជិះកង់បន្ទាប់តាយឿក ។ ជិះកង់មកដល់

បានពួកនិរតីគេសួរ “ពូៗឯណាមនុស្សដែលឲ្យទៅយកពីក្រោមមក” ចេះបានតាយៀកថា ចេះ “កុំនិយាយ” ។ កុំនិយាយខ្លាចពួកខ្ញុំពូ ប៉ុនខ្ញុំពូបាត់ទៅហើយ ខ្ញុំពូខ្ញុំដឹងថា “អូ!ខ្ញុំងាប់ ហើយ” ខ្ញុំដឹងថាខ្ញុំងាប់ហើយ ។ ហើយតាម៉ននោះ អត់ពូទេ ដែលខ្ញុំម៉ាយប់នោះ ខ្ញុំដេក អត់លក់ទេ ខ្ញុំដឹងថាខ្លួនខ្ញុំងាប់ហើយ នឹកឃើញថា២នាក់តាម៉ននោះ តាម៉នឃើងរត់ទៅណា បើយើងស្មោះត្រង់នឹងអង្គការទាំងអស់គ្នាចេះ យើងមិនដឹងថារត់ទៅណាបានរស់ ។ ដល់ហើយបើថា អង្គការមិនជឿងដាក់លើយើងៗស្មោះត្រង់ប៉ុននឹងហើយ ងាប់ក៏ងាប់ចុះ សុខចិត្តងាប់ណា ខ្ញុំអត់រត់ទេ ។ ដល់ពេលព្រឹកឡើងៗតាម៉នថា “ទៅយើង មុននឹងងាប់ នាំគ្នាទៅដឹកទឹកត្នោតឲ្យឆ្អែតសិនទៅ” ដើរទៅដឹកនៅប៉ោយតាអុងៗ ទៅដេកនឹងអាងត្រពាំងថ្មនៅនោះ ដឹកប៉ោយតាអុងស្រាប់តែមកវិញដឹកទឹកត្នោត ឃើញឡានអាជៀល ឡានសរកចាប់ ។ ឡានមកវ៉ាវនេះ ខ្ញុំដើរបណ្តើរគ្នាខ្ញុំដើរមុន តាម៉ន ដើរក្រោយ ឡានគេមកអែបវ៉ាត់ គេបើកទ្វារវ៉ាត់គេស្ទើឡើងឡាន ខ្ញុំក៏ឈានជើងឡើងឡានទៅ គេរុញទ្រូងខ្ញុំចេញៗ គេរុញតាម៉នបញ្ចូន គេបិទទ្វារក្រឹបទៅ ខ្ញុំដួលទៅៗគេសែងដាក់កន្ទែងពេទ្យៗឡើងរហូតដល់ម៉ោង៤កន្លះបានខ្ញុំដឹងខ្លួន ។

ដានី ៈ ម៉េចចឹង?

ឈួន ៈ ខ្ញុំសន្លប់ ។

ដានី ៈ ម៉េចបានសន្លប់ គេរុញទម្លាក់ឡាន?

ឈួន ៈ ទេ! គេរុញចេញមិនឲ្យឡើងឡាន វាភ័យ ។

ដានី ៈ ភ័យ?

ឈួន ៈ ភ័យ ក្អកក្រហមក្នុងខ្លួនទាំងអស់ វាដូចជាអត់ដឹងអីទេ ដូចថាមិនមែនមនុស្សចេះឯង វាប្រហោងទាំងអស់ តក់ស្លុតដែលគេចាប់ ។ ប៉ុនគេមិនបានចាប់ខ្ញុំ គេចាប់អ្នកផ្សេង ចុះខ្ញុំស្មានតែគេចាប់ខ្ញុំ ។ ដល់ដឹងខ្លួនឡើងបានពេទ្យគេមកប្រាប់ ថា “បងឯងកុំភ័យ ព្រោះគេមិនបានចាប់ទេ បងឯង បើគេចាប់ៗទៅបាត់ទៅហើយ” ។ នេះបានខ្ញុំទៅជួបតារិនៗ គាត់ហៅទៅជួប គណៈតំបន់ “ឥឡូវឈួនឯង បើមិនជឿខ្ញុំទេ ឈួនឯងមើលឈ្មោះនេះដែលត្រូវចាប់ ហើយឈ្មោះដែលមិនត្រូវចាប់មានតែឈួនឯង ២នាក់តាយៀកទេ ដែលគេមិនមានចាប់ ដែលអត់មានឈ្មោះ” ។ ផុតពីនឹងត្រូវចាប់ទាំងអស់ ខ្ញុំមើលទៅឈ្មោះឃើញទាំងអស់ ។

ដានី : ឃើញឈ្មោះពីណាខ្លះ?

ឈួន : ឈ្មោះពួក ពួកអាវិត ពួកអាស្រេះ តាមរយៈដែលខ្ញុំស្គាល់ អាកូនក្រុមខ្ញុំ កូនកងខ្ញុំ ដែលខ្ញុំ ចាត់តាំងនឹង ។

ដានី : ចុះម៉េចចឹង ម៉េចបានគេអត់ចាប់ពូ ពីរនាក់តាយឿក?

ឈួន : មិនដឹងថាម៉េច បានខ្ញុំឆ្ងល់ខ្លួនឯងដែរ នេះបានខ្ញុំទៅប្រាប់អាវិតៗ ប្រាប់អាស្រេះ ។ ខ្ញុំដឹងហើយខ្ញុំទៅប្រាប់គ្នាឯងទៀតថា “ឯងកុំនៅ ត្រូវទៅនេសាទជាមួយអញ បើឯងនៅមុខតែស្លាប់ហើយ ព្រោះឈ្មោះត្រូវគេចាប់ហើយ” ។ ចឹងបានពួកអាដោយនោះដឹង វាអត់ទៅជាមួយខ្ញុំ វានាំគ្នារត់ទៅ ។ ដល់រត់ទៅមិនដឹងទៅស្លាប់នៅណានៅណៃ បាត់លុះសព្វថ្ងៃ ដោយទាំងប្អូនខ្ញុំ ប្អូនជីដូនមួយម្នាក់២នាក់ ។

ដានី : ចុះបើគេដឹងថាពូប្រាប់រឿងចឹង គេមិនរករឿងពូហើយ?

ឈួន : ទេ! មិនមានអ្នកណាដឹងទេ ព្រោះគាត់ទុកចិត្តខ្ញុំហើយ គាត់ស្រឡាញ់ខ្ញុំរហូតដល់បង្ហាញអាការអាថ៌កំបាំងមកខ្ញុំ ។

ដានី : ចុះម៉េចបានគាត់ទុកចិត្តពូ ពូស្គាល់គាត់ពីមុនមក?

ឈួន : អត់ទេ អត់មានស្គាល់ទេ ព្រោះគាត់អ្នកចាត់តាំងឲ្យខ្ញុំធ្វើប្រធាននេសាទ គាត់អ្នកចាត់តាំងខ្ញុំ ឲ្យពីរនាក់តាចេង ។

ដានី : ចឹងស្គាល់ពូរយៈពេលខ្លី?

ឈួន : បាទ! រយៈពេលខ្លី ។ ដល់ហើយដូចថា គាត់ដឹងថាខ្ញុំនេះមនុស្សត្រង់ ដឹងថាគាត់ព្រោះអីខ្ញុំក្នុងរយៈកន្លងមក វាមានអីមិនដែលប៉ះពាល់បងប្អូនណាទេ ។ ព្រោះចេះឈ្មោះដែលគេមិនត្រូវចាប់ ខ្ញុំដឹងចំនុចក្រោយ ។ កាលដែលតាវ៉ាល់នៅ ចល័តទាំងអស់គេហៅចូលទៅក្នុងមន្ទីរបក្សៗ គេនិយាយថា “ឥឡូវបក្សយើងគេបើកទ្វារហើយ ដើម្បីប្រមូលកម្លាំង បក្សយើងបើកទ្វារហើយ ដើម្បីទៅរៀបចំជាសម្ព័ន្ធយុវកក ជាស្នូលរបស់បក្ស” ។ ដល់ពេលខ្ញុំនៅនេសាទនោះ ហើយតាយឿកក៏នៅឆ្ងាយ ដល់ពេលគេហៅទៅនេះ គេមកទាំងអស់គ្នាទៅ គេឡើងឡានទៅអស់ ដល់ខ្ញុំមកក្រោយឡានវាទៅហួស ។ ដល់មកក្រោយបានតាវ៉ាល់ថា “ឈួនឯងចាំអាវគ្គក្រោយទៅ” ។ ដល់ហើយគេបានអាឈ្មោះនោះឯងៗ បានដល់ពេលរឿងកើតឡើង គេចាប់តាមឈ្មោះនេះ បានឈ្មោះខ្ញុំ២នាក់នោះវាអត់មាន ។

ដានី : ដោយសារ អានេះសំណាងរបស់ពូ?

ឈួន : បាទ! នោះឯង ។

ដានី ៖ ដោយសារ អ្នកដែលចូលយុវកក ដែលមានឈ្មោះប៉ុន្មានគេចាប់ហើយ ដល់ពេលពូអត់មាន បានន័យថា មិនមែនក្នុងសម្ព័ន្ធរបស់គេ?

ឈួង ៖ បាទៗនោះហើយ បាទ! មិនមែនក្នុងសម្ព័ន្ធរបស់គេ ។

ដានី ៖ តាមពិតវាមិនចឹងទេ ដោយសារយើងអត់បានទៅ?

ឈួង ៖ បាទ! យើងទៅអត់ទាន់ ព្រោះខ្ញុំនៅឆ្ងាយ ។

ដានី ៖ កាលនឹងពូទៅធ្វើនេសាទហើយ?

ឈួង ៖ បាទ! ខ្ញុំធ្វើនេសាទហើយ ។

ដានី ៖ ដល់ពេលតាយឿក គាត់ទៅណាកាលនឹង?

ឈួង ៖ តាយឿក គាត់នៅអាងត្រពាំងថ្មនោះ គាត់នៅបើកអន្លុរឲ្យគេ សេដ្ឋកិច្ចអន្លុរ សម្រាប់បើក អន្លុរ កម្លាំងលើកទំនប់នោះឯង ។

ដានី ៖ ប៉ុនដែរ?

ឈួង ៖ ដល់គេហៅៗឡើងឡានទៅជប់នេះឯង ។

ដានី ៖ កាលនឹងឈ្មោះដែលត្រូវចាប់នឹង និរតីគេអ្នកចុះឈ្មោះឲ្យចាប់ ឬក៏ដៀល?

ឈួង ៖ អត់ទេ ដៀល ។

ដានី ៖ ចឹងឈ្មោះ ដៀលនឹង ឲ្យទៅពួកនិរតីទៀត បានមានឈ្មោះដែរ នៅតារិននឹង?

ឈួង ៖ ពួកដៀល វាធ្វើឈ្មោះនោះ ឲ្យមកនិរតី ហើយវាអ្នកដើរចាប់ ។

ដានី ៖ ដៀល នឹងដើរផ្ទាល់ខ្លួនឯងដើរចាប់?

ឈួង ៖ ដើរផ្ទាល់ខ្លួនឯង ឡានសមួយ ឲ្យតែឃើញឡានសញ្ញ័រខ្លួនក៏ដើក ប្រធានសហករណ៍អីវ៉ាន់ ។

ដានី ៖ បានន័យថា ដៀល នឹងអ្នកនៅក្នុងឡាននឹង?

ឈួង ៖ នឹងហើយដៀលនោះ នៅក្នុងនោះឯង យោធាវាស្រេច ។ ហើយពួកនិរតីមកហើយ ប៉ុន ចេះចាំមើលវា អត់ទាន់ធ្វើសកម្មភាពអីទេ ពួកនិរតី ចាំមើល ។

ដានី ៖ ចាំមើល ដៀល នឹង?

ឈួង ៖ នោះហើយ ។

ដានី ៖ ចឹងពេលចាប់តាហ៊ីង ហើយ ដៀល នឹងក៏មិនបានធ្វើគណៈតំបន់ខ្លួនឯងដែរ?

ឈួង ៖ បាទ!

ដានី ៖ ចាប់ហើយ ប៉ុន្តែតាមគោលគំនិត ដៀល នឹងចង់ធ្វើគណៈតំបន់ខ្លួនឯង?

ឈួង ៖ នឹងហើយ ។

ដានី ៖ តែពួកនិរតីមកទៅ គេមានតែងតាំងតារិន ឲ្យធ្វើប្រធានទៅ?

ឈួន ៖ នោះហើយ ។

ដានី ៖ ហើយ ជៀល អនុដដែល?

ឈួន ៖ នោះហើយ នៅជាជំនួយការ មិនពេញជាអនុ ។

ដានី ៖ ជំនួយការគេ?

ឈួន ៖ នោះហើយ ។

ដានី ៖ មានតែតារិនមួយទេ?

ឈួន ៖ នោះហើយ ។

ដានី ៖ មានពីណាទៀត ដែលពួកនិរតីក្រៅពីតារិន?

ឈួន ៖ តាពាល់ៗគាត់គ្រប់គ្រងចល័ត ហើយតាចេង គាត់គ្រប់គ្រងចល័តដែរ ដកតាចេងទៅគ្រប់គ្រងនេសាទជាមួយខ្ញុំ ។

ដានី ៖ តែដូចថាក្នុងគណៈតំបន់វាមាន៣នាក់ វាមានលេខា អនុលេខា?

ឈួន ៖ បាទ! ខ្ញុំអត់ស្គាល់២នាក់ទេ ខ្ញុំស្គាល់តែប្រធានទេ ។

ដានី ៖ ស្គាល់ប្រធានឈ្មោះតារិន?

ឈួន ៖ បាទ! ស្គាល់តែតារិននឹងឯង ក៏គាត់បានតែងតាំងខ្ញុំ ហើយខ្ញុំ ។

ដានី ៖ តារិន ប្រពន្ធគាត់ឈ្មោះអី?

ឈួន ៖ អត់ៗស្គាល់ មិនដែលឃើញប្រពន្ធគាត់ផង ។

ដានី ៖ គាត់ចាស់ ហើយក្មេង?

ឈួន ៖ ទេ! ចាស់ ជាងខ្ញុំ គាត់បងខ្ញុំ ។

ដានី ៖ បងៗច្រើន អាយុច្រើន?

ឈួន ៖ ទេ! មិនជាច្រើនប៉ុន្មានដែរ វាបងខ្ញុំ៤-៥ឆ្នាំ ។

ដានី ៖ បង៤-៥ឆ្នាំ?

ឈួន ៖ បាទ! ប៉ុនមនុស្សគាត់ក៏មាំងដែរ ។

ដានី ៖ ដល់ពេលតារិន គាត់តែងតាំងគណៈស្រុកបន្តទៀត ឬក៏មានឈ្មោះមក?

ឈួន ៖ បាទ! តារិននឹង គាត់តែងតាំងគណៈស្រុក ។

ដានី ៖ ដល់ពេលចាប់តាមោងហើយអ៊ីចឹង តែងតាំងគណៈស្រុកព្រះនេត្រព្រះ?

ឈួន ៖ ទេ! មិនទាន់តែងតាំងទេ នៅឲ្យអាជៀល គេធ្វើការសិន រហូតដល់ចាប់អាជៀល១បាន គាត់តែងតាំងបណ្ដោយ ។

ដានី ៖ ចាប់ជៀល ចាប់ពីអន្លង់?

ឈួន ៖ ចាប់កំពុងនិរតីមក បស្ចិមមកអាជៀលកំពុងធ្វើការដេញចាប់ពួកពាយ័ព្យនេះឯង ចាប់ទៅគេ ចាំមើលសកម្មភាពអាជៀលនេះឯង ។ ឃើញអាជៀល ដេញចាប់សព្វបែបយ៉ាង ទៅបាន ដល់ដែនការគេចាប់អាជៀល ប្រឹប ។

ដានី ៖ ពូចាំដែរ ចាប់ជៀល?

ឈួន ៖ អត់ចាំ ។

ដានី ៖ ចាប់ក្នុងឆ្នាំ៧៧ ឬ៧៨?

ឈួន ៖ ៧៧ អូ! ៧៨ ។

ដានី ៖ ខែពេលណា គេចាប់៧៨នឹង?

ឈួន ៖ មិនដឹងថា ពេលណា ចាំអត់បានច្បាស់ទេ ។ មើលកាលខ្ញុំទៅនេសាទ ខ្ញុំឡើងប្រហែលជាខែ ៨ ខែ៩ ខែ១០ ព្រោះខ្ញុំបើកកាណូតហើយ ខែបើកកាណូត ។

ដានី ៖ ខែ១០ ៧៨ហើយនឹង ជិតចប់?

ឈួន ៖ នោះហើយ ។

ដានី ៖ ព្រោះ៧៩យួនចូល?

ឈួន ៖ នឹងហើយ ។

ដានី ៖ ដើមខែមករា?

ឈួន ៖ អូ! មិនមែនទេ ខុសហើយ ចាប់យូរគ្រាន់នោះឯង បានយួនចូលនោះ ។

ដានី ៖ ចុះក្រែងជៀល ចាប់គាហ៊ីង គាវ៉ាល់ បានយូរ បានគេចាប់គាត់បន្តទៀត?

ឈួន ៖ ទេ! មិនយូរប៉ុន្មានទេ ខុសគ្នាតែ២-៣ខែប៉ុណ្ណោះឯង ។

ដានី ៖ ២-៣ខែ?

ឈួន ៖ បាទ!

ដានី ៖ ប្រហែលជាដើម៧៨ ឬក៏ចុង៧៨?

ឈួន ៖ បាទៗ ដើម ៗ៧៨ ។

ដានី ៖ ដើម៧៨?

ឈួន ៖ នោះហើយ ។

ដានី ៖ ចុះហើយខាងគណៈស្រុកគេតែងតាំងមុនចាប់ដៀលទៀត ឬក៏យ៉ាងម៉េច?

ឈួន ៖ ទេ! តែងតាំងក្រោយ ៗ ចាប់អាដៀលរួច បានគេរៀបចំគណៈស្រុក ៗ

ដានី ៖ គណៈស្រុក?

ឈួន ៖ អឺ!

ដានី ៖ ដល់ពេលគណៈស្រុកព្រះនេត្រព្រះ?

ឈួន ៖ យាយចែម ៗ

ដានី ៖ យាយចែម?

ឈួន ៖ បាទ!

ដានី ៖ ពូស្គាល់យាយចែម?

ឈួន ៖ ស្គាល់ ៗ

ដានី ៖ យាយចែម គាត់មកពីណា មកពី?

ឈួន ៖ យាយចែមមកពីនិរតី ៗ

ដានី ៖ មកពីនិរតី ចុះខាងភ្នំស្រុក?

ឈួន ៖ ខាងភ្នំស្រុក តាអឿន ៗ

ដានី ៖ តាអឿន និរតីដែរ?

ឈួន ៖ បាទ! និរតីដែរ ៗ

ដានី ៖ ចុះខាងថ្មពួក?

ឈួន ៖ អត់ស្គាល់ ស្គាល់តែ២ប៉ុននោះឯង ៗ

ដានី ៖ ខាងភ្នំស្រុក ហើយនឹងយាយចែម?

ឈួន ៖ យាយចែម ស្រុកព្រះនេត្រព្រះ ៗ

ដានី ៖ យាយចែម ស្រុកព្រះនេត្រព្រះ?

ឈួន ៖ បាទ!

ដានី ៖ គាត់អត់មានគណៈតំបន់?

ឈួន ៖ ទេ!

ដានី ៖ គាត់មានតួនាទីអីទៅតំបន់ទៀតដែរអត់?

ឈួន ៖ ទេ! តំបន់ តារិន ៗ

ដានី ៖ តារិន?

ឈួន ៖ នោះហើយ ។

ដានី ៖ ប៉ុន្តែដូចថា យើងគាត់ជាសមាជិកតំបន់អីដែរអត់?

ឈួន ៖ ទេ! ដូចមិនមែនទេ ឬក៏ជាសមាជិកជនជីន យើងដឹងមិនដល់ដែរ ។

ដានី ៖ ហើយចុះនៅអាងត្រពាំងថ្ម បន្ទាប់ពីចាប់តាវ៉ាល់ទៅគេឲ្យឈ្មោះ?

ឈួន ៖ តាចេង ។

ដានី ៖ តាចេង?

ឈួន ៖ បាទ! តាចេងទៅគ្រប់គ្រង ។

ដានី ៖ តាចេង ថាប្រធានសហករណ៍មិញនឹង?

ឈួន ៖ បាទ! ឲ្យតាចេងគ្រប់គ្រង ខ្ញុំនៅសហករណ៍នោះ ។

ដានី ៖ តាចេង ខាងពួកណា ពួក?

ឈួន ៖ ពួកមកពីបស្ចិម ។

ដានី ៖ មកពីបស្ចិម?

ឈួន ៖ បាទ!

ដានី ៖ តាចេងនឹងគ្រប់គ្រង ពូនៅសហករណ៍?

ឈួន ៖ បាទ! ខ្ញុំនៅសហករណ៍ ។

ដានី ៖ ឈ្មោះ តាចេង តាអីមួយទៀត បន្ទាប់ពីតាចេង?

ឈួន ៖ តាចេង តាពាល់ ។

ដានី ៖ តាចេង ហើយតាពាល់?

ឈួន ៖ បាទ! ដល់នៅសហករណ៍ទៅ បានអាសហករណ៍តំបន់គេនោះខុសសីលធម៌ទៅ បានគេចាប់អានោះចេញទៅ ។ គេឲ្យនិរសាអាជៀលនោះ ធ្វើប្រធានសហករណ៍ ។

ដានី ៖ ឈ្មោះអីគេ និរសា?

ឈួន ៖ ឈ្មោះអា អឺ!និរសាអាជៀលអី និរសាតាហ៊ីង អូ! និរសាអាជៀល អឺ!ភ្លេចឈ្មោះវាបាត់ ហើយ នៅស្រុកវានៅខាងស្រុករូងនេះឯង អាប៉ុញៗ ២នាក់អាប៉ាក ឲ្យទៅធ្វើសហករណ៍ ទៅ បានពួកនិរតីមកចាប់អាប៉ុញ និងអាប៉ាកទៅ បានតែងតាំងឲ្យខ្ញុំធ្វើប្រធានសហករណ៍ បាន ឲ្យតាចេងទៅផង ។

ដានី ៖ ដល់ពេលពីណាគេ តាចេងទៅបាត់ទៅ ពីណាអ្នកនៅគ្រប់គ្រង?

ឈួន ៖ នៅតាពាល់ ។

ដានី ៖ តាពាល់គាត់ធ្វើ?

ឈួង ៖ តាពាល់ គាត់គ្រប់គ្រងចល័តតំបន់ទាំងអស់ ហើយនឹងតារិន គណៈតំបន់ ។

ដានី ៖ តារិន គណៈតំបន់ មកគ្រប់គ្រងនៅត្រពាំងថ្ម?

ឈួង ៖ ហ្នឹងហើយគាត់មកគ្រប់គ្រងនៅត្រពាំងថ្ម ។

ដានី ៖ តារិន មកគ្រប់គ្រងបន្តទៀត?

ឈួង ៖ បាទ!

ដានី ៖ ប៉ុន្តែពេលតាពាល់ តារិន អីមកនៅគ្រប់គ្រង នៅអាងត្រពាំងថ្ម នៅធ្វើដដែល?

ឈួង ៖ នៅធ្វើៗ ។

ដានី ៖ នៅតែធ្វើនៅឡើយ?

ឈួង ៖ បាទ!

ដានី ៖ ព្រោះហេតុអីបានគេធ្វើបន្តទៀត ពីព្រោះញ៉ីមុនមកខាងពាយ័ព្យយើងធ្វើ?

ឈួង ៖ បាទ!

ដានី ៖ អានេះមកពីខាងលើ ពីមជ្ឈិមបញ្ជាឲ្យធ្វើបន្តទៀត ឬក៏យ៉ាងម៉េច?

ឈួង ៖ បាទ! មិនដឹងយ៉ាងម៉េចដែរ ដែលខ្ញុំកាលនោះសុទ្ធតែខ្លាចហើយ ឮថាគេហៅដឹងថាសាប់ ។ តែគេហៅទៅ ថ្នាក់ម៉ែឪសាប់មិនបានធ្វើបុណ្យ មិនហ៊ាននៅដឹងថាម៉ែសាប់ដែរ គេហៅទៅប្រជុំ ភ័យខ្លាចសាប់ខ្លួនឯងទៀត ។

ដានី ៖ ចុះពូធ្លាប់ដែលទៅប្រជុំនៅបាត់ដំបង ទៅប្រជុំនៅកន្លែងមន្ទីរភូមិភាគ?

ឈួង ៖ ទេ! អត់ទេ ។

ដានី ៖ អត់ដែរ?

ឈួង ៖ អត់ ខ្ញុំប្រជុំបាននៅស្វាយ ព្រោះយើងតំបន់ ។

ដានី ៖ តាញឹម តាមូល សម្បត្តិអី អត់ដែលមកប្រជុំនៅស្វាយ?

ឈួង ៖ ទេ! គេមកគេប្រជុំ គេអ្នកធំៗគេមក ។

ដានី ៖ ពូអត់ដែលប្រជុំ?

ឈួង ៖ អត់ដែលបានជួបទេ ។

ដានី ៖ ចុះតារិន ពេលដែលគាត់មកនឹង ផ្ទះគាត់នៅណាទៅ?

ឈួង ៖ តារិន ផ្ទះគាត់មិនមានផ្ទះទេ គាត់នៅនឹងរោងកន្លែងចល័ត កន្លែងបើកសេដ្ឋកិច្ចបើកអង្ករ ។

ដានី ៖ កន្លែងសេដ្ឋកិច្ច បើកអង្ករនៅណា?

ឈួង ៖ នៅអាងត្រពាំងថ្ម ។

ដានី ៖ អូ! គាត់មកបោះទីតាំងនៅអាងត្រពាំងថ្មម៉ង?

ឈួង ៖ បាទ! គាត់មកនៅបាន៤-៥ថ្ងៃទៅ គាត់ទៅស្វាយទៅៗបាន៤-៥ថ្ងៃ គាត់មក ព្រោះគាត់ចល័ត ជួនកាលគាត់ដើរចុះស្រួងជាមួយប្រជាជន ។ គ្មានអ្នកណាដឹងថាគាត់គណៈតំបន់ ។

ដានី ៖ ពូស្គាល់ស្រុកកំណើតគាត់ទេ តារិន?

ឈួង ៖ អត់ៗស្គាល់ ដឹងថាគាត់មកពីនិរតី ។

ដានី ៖ ដឹងថាគាត់មកពីនិរតី?

ឈួង ៖ នោះ ។

ដានី ៖ អត់ស្គាល់ឈ្មោះ គាត់ពេញឈ្មោះអី?

ឈួង ៖ អត់ ។

ដានី ៖ ស្គាល់តែៗគាត់ស្និតស្នាលជាមួយពូដែរ ព្រោះគាត់ហ៊ាន?

ឈួង ៖ បាទ! ស្និតស្នាលជាមួយ ។

ដានី ៖ ម៉េចបានគាត់ស្រឡាញ់ពូ បើដូចថាពូអ្នកនៅនេះយូរហើយ គាត់អ្នកមកថ្មី គ្រាន់មកភ្លាមស្គាល់គ្នាស្រឡាញ់?

ឈួង ៖ ទេ! ខ្ញុំមិនដឹងថារកម៉េចដែរ ។

ដានី ៖ មិនដឹងថារកម៉េចដែរ?

ឈួង ៖ នឹងហើយ ប៉ុនគាត់នោះដូចអ្នកជិតល្អតែម្ដង ព្រោះដែលខ្ញុំចាប់ស្គាល់គាត់នេះ ដែលគាត់តែងតាំងឲ្យខ្ញុំធ្វើប្រធាននេសាទនេះ រហូតដែលពួកអាជៀលគេចាប់ ដែលខ្ញុំថាសន្ទប់នេះ ខ្ញុំ ងើបពីសន្ទប់ គាត់ត្រូវបង្ហាញឈ្មោះមនុស្សដែលត្រូវចាប់ ប៉ុនមិនដឹងថាគាត់មាននិស្ស័យ ជាមួយខ្ញុំយ៉ាងម៉េចក៏មិនដឹង ។ ប៉ុនគាត់មានមិនមានចំពោះខ្ញុំទេ ចំពោះអ្នកផ្សេងក៏គាត់ល្អ ដែរ ។

ដានី ៖ សំបុរសំបកគាត់ម៉េច?

ឈួង ៖ តារិន ខ្មៅ ។

ដានី ៖ តារិនខ្មៅ?

ឈួង ៖ បាទ!

ដានី ៖ ទាប ហើយខ្ពស់?

ឈួង ៖ មាឌ គាត់ធំ ។

ដានី ៖ ធំ?

ឈួង ៖ អឺ! ប៉ុនមិនមែនធំដឹបងទេ ដូចថាធំរៀងទាបដែរ ។

ដានី ៖ ធំ ទាប?

ឈួង ៖ នោះហើយ ។

ដានី ៖ សម្តីគាត់ សម្តីដូចថា?

ឈួង ៖ សម្តីមួយៗ ។

ដានី ៖ សម្តីមួយៗ?

ឈួង ៖ បាទ! និយាយមិនសូវស្តាប់បានទេ គាត់និយាយទ្រង់មួយៗទៅ ដូចថា ។ និយាយប្រុង ស្តាប់គាត់ ស្តាប់អត់បានទេ គាត់សម្លេងតូច ។

ដានី ៖ សំលេងតូច?

ឈួង ៖ នោះហើយ ។

ដានី ៖ សក់គាត់សក់ ពណ៌?

ឈួង ៖ សក់គាត់ សក់រៀងគេថាសក់អន្តាជីពីដើម ។

ដានី ៖ សក់អន្តាជី តូច?

ឈួង ៖ អឺ!

ដានី ៖ គាត់តាមមើលទៅ គាត់អាយុច្រើនជាង?

ឈួង ៖ ច្រើនជាងខ្ញុំ ប្រហែលបងខ្ញុំ៥-៦ឆ្នាំ ។

ដានី ៖ ៥-៦ឆ្នាំ បើឥឡូវប្រហែលខ្ទង់?

ឈួង ៖ ខ្ទង់៧០ហើយ ។

ដានី ៖ ខ្ទង់៧០អីនឹង?

ឈួង ៖ បាទ!

ដានី ៖ តែគាត់មនុស្សដូចថា គាត់ចិត្តល្អ?

ឈួង ៖ បាទ! មនុស្សចិត្តល្អ គាត់មិនមែនចិត្តល្អចំពោះខ្ញុំទេ ចំពោះបងប្អូនអ្នកស្រុក គាត់ចិត្តល្អដែរ ។

ដានី ៖ ដូចថាពេលដែលពូកាន់ជានេសាទតំបន់៥ កាលនោះយើងនេសាទត្រីយើងផ្ញើយកពីណាខ្លះមក?

ឈួង ៖ ត្រីទន្លេសាប ។

ដានី ៖ ត្រីទន្លេសាប?

ឈួង ៖ បាទ! វ៉ៃអួន ទន្លេសាប ។

ដានី ៖ គ្នាច្រើន ពួកកងនេសាទ?

ឈួង ៖ ៣០០នាក់ ។

ដានី ៖ ៣០០នាក់?

ឈួង ៖ បាទ!

ដានី ៖ ៣០០នាក់ អានឹងយើងរកនៅទន្លេសាបទាំងអស់?

ឈួង ៖ បាទ! ទេ! ចំមើលណា ទុកនៅកំពោយើង ពាមបំពង់ក្រសាំងទុកម៉ាចំនួន ទុកកៀនស្បូវម៉ាចំនួន ម៉ាក្រុមៗ ហើយនឹងក្បាលក្របីម៉ាក្រុម ស៊ីងកំបុតម៉ាក្រុម ដែលមានព្រែក មានដៃទុកឲ្យគេធ្វើ ហើយដែលចុះទៅទន្លេម៉ាក្រុម ។ ហើយខ្ញុំដូចថាធ្វើប្រធានចេះ គិចខ្ញុំទៅនេះម៉ាយប់ គិចទៅនោះម៉ាយប់ៗចេះទៅមកៗ ។

ដានី ៖ ចុះត្រីៗម៉ាថ្ងៃយើងរកបានប៉ុន្មានតោន?

ឈួង ៖ ត្រីពាអួន ម៉ាថ្ងៃបានម៉ាតោន ថ្ងៃណាបាន៧០០ ៨០០គីឡូ ថ្ងៃណាយើងរកបានដាងម៉ាតោន ដល់យើងរកមិនទាន់ យើងទៅសុំខាងភូមិភាគ ។

ដានី ៖ ខាងភូមិភាគទៀត?

ឈួង ៖ បាទ! ដូចថាយើងរកដោះស្រាយកម្លាំងយើងហូបមិនគ្រប់ យើងទៅសុំភូមិភាគ ដូចថាភូមិភាគគេចាប់សំរះ យើងទៅបើកកាណូតទៅដាក់ឌុបទៅ ។ សុំគេប៉ុន្មាន ដូចថា១៥០គីឡូគ្រប់២០០គីឡូយើងបើកទៅ ។

ដានី ៖ ទៅសុំខាងភូមិភាគគេឲ្យ?

ឈួង ៖ គេឲ្យ ។ យើងត្រូវការដឹកប្រហុកដឹកអីមកឡាន យើងខ្វះខ្វី ទៅសុំប្រហុកគេ ដូចថាម៉ាតោនកន្លះ គេឲ្យ ជូនតាមចល័ត ។

ដានី ៖ ចឹងយើងរកត្រីមកគ្រប់គ្រង ម៉ាតំបន់៥នឹងអត់គ្រាន់ទេ?

ឈួង ៖ អត់ៗគ្រាន់ទេ ។

ដានី ៖ អត់គ្រាន់ មកថែមសុំគេម៉ាថ្ងៃប៉ុន្មានទៀត?

ឈួង ៖ មិនមែនសុំគេរាល់ថ្ងៃទេ ដូចថាពេលវេលាដែលយើងត្រូវដឹកឡើង កន្លះខែយើងត្រូវដឹកឡើងម្តងណា ។ បើក្នុងរយៈកន្លះខែនឹង យើងរកអាចបានគ្រប់ចំនួនដែលយើងត្រូវឡើង

២គោន ឬ៣គោន ក៏យើងយកមក ។ បើយើងមិនគ្រប់ទេ យើងត្រូវសុំគេដើម្បីបំពេញ ។

ដានី : ចឹងម៉ាខែ កន្ទះខែបានយើងដឹកមកម្តង?

ឈួង : បាទ! កន្ទះខែ ។

ដានី : កន្ទះខែដឹកមកម្តង?

ឈួង : បាទ! កន្ទះខែឡើងម្តង ។

ដានី : កន្ទះខែឡើងមកម្តង ចុះត្រីយើងរកបានវាមិនខូចអស់ហើយ?

ឈួង : ទេ! ធ្វើប្រហុក ធ្វើផ្អក ធ្វើម៉ាំ ធ្វើងៀតធ្វើអី ។

ដានី : ធ្វើត្រីធំៗធ្វើងៀត?

ឈួង : បាទ!

ដានី : ចឹងយកមកម៉ាខែៗយកមកប៉ុន្មានគោន បើតាមតំរូវការកន្ទះខែ?

ឈួង : ម៉ាខែ៣គោន ។

ដានី : ម៉ាខែ៣គោន?

ឈួង : ៣គោននឹងទាំងត្រីងៀត ទាំងប្រហុក ។

ដានី : ទាំងត្រីងៀត ទាំងប្រហុក?

ឈួង : បាទ!

ដានី : ៣គោន តែកន្ទះខែយើងដឹកមកម្តង?

ឈួង : បាទ! កន្ទះខែ ។

ដានី : កន្ទះខែម៉ាគោនកន្ទះ?

ឈួង : បាទ!

ដានី : ដឹកយកមកដាក់កន្លែងណា?

ឈួង : ដាក់ស្មាយ កន្លែងសែសិន ។

ដានី : ដាក់ស្មាយ ដល់ពេល កន្លែងតែសិននឹង?

ឈួង : នឹងហើយនឹងស្ពានសែសិន ។

ដានី : ដាក់ស្មាយ គេចែកបន្តទៀតទៅ?

ឈួង : បាទ! ចែកទៅតាមមន្ទីរពេទ្យ ចែកតាមក្រសួង ចែកតាមមុខសញ្ញា តាមការដ្ឋាន ចែកទៅ ចល័ត ។ បើស្រុកទៅគេអត់ចែកទេ ។

ដានី ៖ ចុះភូមិភាគនឹងនៅកន្លែងណា ដែលយើងទៅសុំត្រីគេនៅភូមិភាគ?

ឈួង ៖ នៅកណ្តាលទន្លេ ។

ដានី ៖ នៅកណ្តាលទន្លេម៉ង?

ឈួង ៖ បាទ! ធ្វើបាននៅកណ្តាលទន្លេ ។

ដានី ៖ ចុះប្រធាននេសាទភូមិភាគម៉ង ពីណាគេ ភូមិភាគពាយ័ព្យ?

ឈួង ៖ ប្រធាននេសាទភូមិភាគ អាលើកមុននឹង ខ្ញុំអត់ស្គាល់ទេ ស្គាល់លើកក្រោយឈ្មោះ ផន ។

ដានី ៖ ផននឹងមកពី?

ឈួង ៖ មិនដឹងជាគេមកពីខាងណាទេ ។

ដានី ៖ ឈ្មោះ ផននឹង?

ឈួង ៖ នោះហើយ ស្គមៗរៀងស្គមតូចដូចខ្ញុំដែរ ។

ដានី ៖ ចុះតាញឹម គេចាប់ពីអន្លង់ តាមមូល សម្បត្តិ?

ឈួង ៖ តាញឹម មូល សម្បត្តិនេះ ចាប់អន្លង់ ចាប់អាជៀល មុនៗចាប់អាជៀល ។

ដានី ៖ មុនចាប់ជៀល?

ឈួង ៖ នោះហើយ ។

ដានី ៖ គេចាប់តាញឹម តាមូល សម្បត្តិមក គេដាក់ពីណាវិញ កាលនោះ?

ឈួង ៖ មិនដឹងជាអ្នកណាទេ ភូមិភាគក្រោយ ខ្ញុំអត់បានដឹងបានស្គាល់ ។

ដានី ៖ អត់បានស្គាល់គេ?

ឈួង ៖ បាទ!

ដានី ៖ អត់ដែលបានឃើញ?

ឈួង ៖ អត់ដែលឃើញ អត់ដែលដឹង ។

ដានី ៖ ចុះតាម៉ុកដែលដើរមកដល់នឹងទេ?

ឈួង ៖ តាម៉ុកមិនដែលមកទេ ។

ដានី ៖ មិនដែលមក?

ឈួង ៖ បាទ! តាម៉ុក ខ្ញុំបានជួបគ្នាជាមួយតាម៉ុក ជួបនៅភ្នំដងរែក ។

ដានី ៖ ជួបពេលភ្នំដងរែក?

ឈួង ៖ បាទ! ដែលយួនចូលហើយ ។

ដានី ៖ ប៉ុល ពត, នួន ជា, អីតាត់អត់ដែលចុះមកមើលអាងត្រពាំងថ្ម?

ឈួង ៖ ទេ! គេមកមិនមក ព្រោះយើងអត់ដែលស្គាល់គេ ។ ប៉ុនមិនដែលមកទេ គ្មានអ្នកមកទេ គ្មានអ្នកណាបានចុះមកទេ ។

ដានី ៖ ចឹងពូដូចថាប្រធាននេសាទតំបន់៥ ហើយចឹងយើងអត់មានទីតាំង អត់មានមន្ទីរអីនៅឈរជើងត្រឹមត្រូវ?

ឈួង ៖ កន្លែងឈរជើងនៅសែសិន ។

ដានី ៖ នៅសែសិន?

ឈួង ៖ តាចេង គាត់នៅ ។

ដានី ៖ អូ! តាចេងគាត់នៅ?

ឈួង ៖ ហើយខ្ញុំចុះក្រោម នៅទន្លេសាប កន្លែងតំបន់ដែលខ្ញុំនៅ គឺកោះក្អែក ។

ដានី ៖ កោះក្អែក?

ឈួង ៖ បាទ! ធ្វើការដ្ឋាននៅកោះក្អែក ។

ដានី ៖ ដូចថាក្នុង៣០០នាក់នឹង យើងចាប់ផង យើងធ្វើត្រីធ្វើអីផង?

ឈួង ៖ បាទ!

ដានី ៖ ចុះកាលនឹងពូហូបត្រី ហូបអីអត់ខ្វះទេ?

ឈួង ៖ ទេ! ខ្ញុំដល់ចុះទៅមិនដែលហូបទេ វាហូបអត់បាន វាឆ្អាប ។

ដានី ៖ វាឆ្អាប?

ឈួង ៖ ហូបបានតែត្រី គេហៅកន្ត្រំប្រេង១ និងត្រីបញ្ជុះហូបបាន ។ ផុតពីនោះខ្ញុំហូបតែសាច់ហូបអី ។

ដានី ៖ ហូបតែសាច់វិញ?

ឈួង ៖ បាទ! សាច់សត្វ មាន់ទឹក មានអី ។

ដានី ៖ ដល់ពេលត្រី ដល់ពេលយើងហូបយូរ១ទៅវាទៅលែងកើត?

ឈួង ៖ បាទ! ហូបលែងកើត ។ ថាទៅមុនដំបូង ខ្ញុំទៅធ្វើប្រធានមុនដំបូង ខ្ញុំថាខ្ញុំងាប់ ។ ចូលទៅដល់កោះក្អែក និយាយពីឆ្អាបប្រហុកស្អុយ ប្រហុកឆាប គ្រាន់តែទឹក ដាំម៉ាឆ្នាំង បានដីកកន្ទះ វាក្អែល១ដូចថាក្អែលដី ។ ដល់នៅយូរ១ទៅវាដេកនៅនឹងពំនូលប្រហុក ក៏មិនធំ មិនស្អុយ ។

ដានី ៖ ចឹងពូអត់សួរចូលចិត្តត្រីដែរ?

ឈួង ៖ បាទ!

ដានី ៖ ដល់ឥឡូវនឹងពូហូបត្រី ហូបអីធម្មតា?

ឈួង ៖ ទេ! សព្វថ្ងៃហូបធម្មតាដូចតែគ្នា ។ នោះនៅក្រចឹង នឹកឃើញឃ្លានដូចគ្នា ។

ដានី ៖ ចុះកាលពេលក្រោយមក តារិនអីមកនឹង ពេលដូចថានេះនឹងប្រជុំរយៈពេលប៉ុន្មានដង ដូចថានេះនឹង ប្រជុំរយៈពេលប៉ុន្មានគេប្រជុំដូចថាគេប្រជុំថ្នាក់តំបន់ ដូចជាប្រធាននេសាទគណៈស្រុក ឬស្អីៗវាប្រជុំគ្នាម្តងៗ?

ឈួង ៖ អត់ដែលបានប្រជុំទេ ។

ដានី ៖ អត់ដែលប្រជុំ?

ឈួង ៖ បាទ!បើថាប្រជុំនេសាទ ហៅនេសាទមកប្រជុំ ។ ប្រជុំស្រុក ប្រជុំខាងភូមិ ខាងសហករណ៍ គឺដោយឡែកផ្សេង យើងមិនបាច់ចូលរួមជាមួយទេ ។

ដានី ៖ ចុះពូធ្លាប់ដែលធ្វើការជាមួយយាយថែម?

ឈួង ៖ យាយថែម ខ្ញុំធ្លាប់បានទៅនៅជាមួយគាត់ដែលយួនចូលហើយនេះទៅនៅភ្នំដងរែកជាមួយ គ្នា ។

ដានី ៖ អូ! ពេលដែលយួនចូលហើយបានទៅ?

ឈួង ៖ បាទ!

ដានី ៖ ចុះកាលពីពូធ្វើនេសាទ គាត់ធ្វើគណៈស្រុកនៅ?

ឈួង ៖ ខ្ញុំមិនដែលបានទាក់ទងអីជាមួយគាត់ ។

ដានី ៖ កាលនឹងស្គាល់គាត់ទេ?

ឈួង ៖ ស្គាល់ ប៉ុនខ្ញុំមិនដែលបានទាក់ទងទេ ព្រោះខ្ញុំវាអន្តភាពចល័ត ខ្ញុំគិតគូខាងចល័តតំបន់ ព្រោះគាត់ខាងស្រុក គាត់គិតគូខាងស្រុកខាងសហករណ៍ ។

ដានី ៖ អត់ដែលបានមកជួបគាត់ ហើយធ្វើការជាមួយគ្នា?

ឈួង ៖ អត់ទេ អត់ដែរទេ ។

ដានី ៖ ដឹងថាគាត់ជាគណៈស្រុក?

ឈួង ៖ បាទ! ប៉ុនដល់អាយួនចូលនេះ គាត់ហៅមកប្រជុំម្តង ។

ដានី ៖ ពីណាហៅ?

ឈួង ៖ គណៈតំបន់តារិន ហើយនឹងយាយថែមនេះ ទៅប្រជុំជុំគ្នាទាំងអស់ម្តងៗគត់ ។

ដានី ៖ មុនយួនចូល?

ឈួង ៖ មុនយួនចូល ។

ដានី ៖ ប្រជុំនៅណា?

ឈួន ៖ ប្រជុំនៅស្វាយ ។

ដានី ៖ ប្រជុំនៅស្វាយ?

ឈួន ៖ បាទ!

ដានី ៖ កាលនឹងតារិន គណៈអធិបតី?

ឈួន ៖ បាទ!

ដានី ៖ យាយថែម?

ឈួន ៖ យាយថែម គាត់គណៈស្រុក ។

ដានី ៖ គណៈស្រុក ប៉ុន្តែពេលប្រជុំនឹង យើងជុំគ្នាគណៈស្រុកគ្រប់ស្រុកទាំងអស់?

ឈួន ៖ បាទ! គ្រប់ស្រុកទាំងអស់ ។ ដល់ប្រជុំនឹង គេមានផែនការ១នេះ គឺនិយាយទៅគេអត់ជឿយើងទេ ។ ព្រោះផែនការ យើងដឹងថា យួនវ៉ៃចូលដល់ខេត្តស្វាយរៀងហើយ ហើយដែល គេបញ្ជាក់ប្រាប់យើង អានេះនិយាយទៅតាមគេ គេបញ្ជាក់ប្រាប់ថា ដែលយួនចូលនេះ ក្នុងប៉ុស្តិ៍វ៉ាដ្យូ ស្រែកខ្មែរទេ អត់មានយួនទេណា ។ ប៉ុនដែលគេនិយាយគេថា យួនចូល ព្រោះយើងនិងយួននោះវាមានប្រវត្តិសាស្ត្រគេដាំតែអុងអីណ៎ ។ ដល់ហើយយួនចូល ហើយ ពួកខ្មែរយើងក្បត់ម៉ាចំនួនរត់ចូលនោះដូចថា សោ ភឹម, មូល សម្បត្តិ, ហេង សំរិន, ហើយនឹងអីនេះ ក្បត់ចូលយួនដែរ ។ ព្រោះសោ ភឹម គេចាប់បាន ដែលរត់ផុត នោះរត់ផុតហេង សំរិន, រត់ផុតជាមួយ នាំទ័ពបាន១៥០០នាក់ទេ ទៅបាន៧ថ្ងៃ វ៉ៃចូលដល់ខេត្តស្វាយរៀងចេះ ។ នោះហើយ ដឹងថាយើងនេះមុខតែបរាជ័យហើយ ។ បើយើងបរាជ័យហើយ យើងត្រៀមលក្ខណៈតាមសហករណ៍នីមួយៗ តាមស្រុកនីមួយៗ កន្លែងការដ្ឋានណាក៏ដោយ យើងត្រូវជីកសម្រាប់កប់អំបិល កប់អង្ករ ឲ្យជីកនៅតាមសហករណ៍គ្រប់សហករណ៍ទាំងអស់ ។

ដានី ៖ ជីកកប់អំបិល កប់អង្ករ?

ឈួន ៖ នោះហើយ ព្រោះកាលណាដែលយើងចាញ់គេ យើងភៀសខ្លួនទៅនៅព្រៃ យប់ឡើងយើងអាចចូលមកយកស្បៀងបាន ។ ផែនការដាក់មកចេះ ស្រាប់តែមកដល់បងប្អូន ជីកគ្រប់សហករណ៍ទាំងអស់ ។ ដល់ជីកគ្រប់សហករណ៍ទាំងអស់ទៅ មិនទាន់បានដាក់អីផងយួនចូលមកដល់ ។ ដល់យួនចូលមកដល់ខាងចលនាខាងនោះ គេនិយាយថា កុំបានគេមករំដោះ

ទាន់ គឺយើងត្រូវរៀបចំទាំងអស់គ្នា ព្រោះតាមឃុំតាមសហករណ៍នីមួយៗសុទ្ធតែដីកអនុវត្ត ស្រេចសម្រាប់កប់យើងទាំងអស់គ្នា ។ ចេះវាទៅជួយចុះទៅវិញ ។

ដានី : កាលនោះគេឲ្យជីកអំបិល ជីកសម្រាប់ជីកដាក់អំបិលនឹង ជីកធំៗ ហើយជីកប៉ុន្មានណា?

ឈួន : ជីកធំណា ដូចថាឃ្លាំងអង្ករ ជីកធំ ល្មមយើងដាក់អង្កររាប់រយតោន ។ ដល់បងប្អូនឃើញ អានោះឯង ដល់គេមកនិយាយចុះទៅវាត្រូវអាចំនុច ។

ដានី : អានេះវាដាក់ឃោសនាផ្សេងៗគ្នា?

ឈួន : បាទ! ដល់គេនិយាយទៅ ដល់ខ្ញុំចាញ់គេទៅនៅព្រៃ ដល់ខ្ញុំមកទៅ ខ្ញុំក៏អត់ដឹងទាំងអស់ លឺលើនិយាយអត់កើត ឯងនិយាយយកការពិត គេថាយើងក្បត់ ។

ដានី : ចុះកាលនឹងម៉េចបានយើងដឹងថាយើងចាញ់គេ ពីព្រោះយើងកាលនឹងគេថាខ្មែរមានតែទ័ព ប៉ុន្មានពាន់នាក់មកវៃ ម៉េចដឹងដែនការយើងចាញ់គេ?

ឈួន : ចុះពួកក្រុមរំដោះទាំងអស់ដែលគេជួយយើង រំដោះទាំងអស់បាញ់យើងដែរ ។ មេ បញ្ជាការរំដោះនៅក្រុងភ្នំពេញ ដូចថាចូលឈួនដែរ ។

ដានី : ពីណាគេ?

ឈួន : មិនដឹងណា ខ្ញុំអត់ស្គាល់ផង គ្រាន់ថាមេបញ្ជាការខាងរំដោះ ។ ដល់ហើយកម្លាំងយើង ត្រូវបរាជ័យ គេដឹងបរាជ័យ បានគេឲ្យយើងរៀបចំ បានពួកវារៀបចំ ។ ខ្ញុំអត់ដឹងទេ ខ្ញុំ នៅតែទន្លេសាបនោះ អត់ដឹងថាគេរៀបចំ ។ ដល់ពេលគេថាឈួនចូលដល់ភ្នំពេញហើយ ខ្ញុំក៏ ឡើង ខៀវ សំផន ក៏ឡើងដែរ ខៀវ សំផន ឡើងពីទន្លេសាប ។ ដល់ពេលឡើងមកនេះ ។

ដានី : ចុះការប្រជុំនេះ តារិន គាត់អ្នកនិយាយ ហើយអ្នកនិយាយប្រាប់?

ឈួន : បាទ! តារិន ។

ដានី : តារិន អ្នកនិយាយ?

ឈួន : បាទ! តារិនៗ គាត់អ្នកនិយាយ ។

ដានី : តារិន កាលនឹងគាត់ចល័តនៅស្វាយផង គាត់នៅត្រពាំងថ្មផង?

ឈួន : បាទ!

ដានី : ចុះកម្លាំងយាយថែម គាត់មានផ្ញើនៅត្រពាំងថ្ម?

ឈួន : ទេ! កម្លាំងយាយថែម គាត់គ្រប់គ្រងកម្លាំងដែលនៅតាមសហករណ៍ទេ ។

ដានី : នៅសហករណ៍ទេ អត់មានទៅត្រពាំងថ្មទេ?

ឈួន ៈ អត់ទេ ។

ដានី ៈ ពួកសហករណ៍អី ក្រែងទៅធ្វើនៅត្រពាំងថ្មដែរ?

ឈួន ៈ ហឺ!

ដានី ៈ និយាយពីពូមានប្រសាសន៍មុន ពួកដូចជាចល័តតំបន់ធ្វើនៅត្រពាំងថ្ម ហើយពួកសហករណ៍ធ្វើនៅព្រះនេត្រព្រះ ភ្នំស្រុក?

ឈួន ៈ បាទៗ អានោះទៅធ្វើ ប៉ុន្តែកាលនោះយាយថែម មិនទាន់បានគ្រប់គ្រងទេ ។

ដានី ៈ តែចឹងដល់ពេលក្រោយមក តាមសហករណ៍គេឈប់ឲ្យនៅធ្វើនៅត្រពាំងថ្ម?

ឈួន ៈ ទេ! អាអ្នកធ្វើនៅនោះធ្វើទៅ អាអ្នកដែលនៅនេះគឺនៅទៅ វាអត់គិតអាអ្នកដែលធ្វើនោះហើយធ្វើនោះហើយទៅៗ ។ គេគិតតែអ្នកដែលនៅនេះ ។

ដានី ៈ ចុះកាលពេលដែលយួនចូលមក យើងរត់ទៅៗយើងរត់ជុំគ្នាទាំងអស់ តារិន យាយថែម ពូ អី គណៈស្រុកផ្សេងៗទៅជុំគ្នាទាំងអស់?

ឈួន ៈ អត់ទេ រត់បែកគ្នាទាំងអស់ ។

ដានី ៈ រត់បែកគ្នា?

ឈួន ៈ បាទ! គណៈតំបន់ដឹងគាត់ទៅខាងណាទេ គណៈតំបន់ រត់មុនគេ ។

ដានី ៈ រត់មុនគេ?

ឈួន ៈ បាទ! តែមិនដឹងថាគាត់ទៅខាងណា ។ ហើយដល់យាយថែមនេះ ក៏រត់ក្រោយគេ មិនដឹងថាទៅខាងណា ។ ហើយដល់ខ្ញុំនេះ ខ្ញុំនៅខាងតាពាល់ៗ គាត់ក្តាប់ចល័តតំបន់ ខ្ញុំខាងចល័តតំបន់ ខ្ញុំនៅទន្លេសាប ។ បានតាពាល់គាត់ហៅឡើងមកថា *"ថាឥឡូវឈួនអើយឡើងមកមិត្តយើងឥឡូវគេរត់ចូលព្រៃអស់ហើយ យើងឡើងមកឲ្យទាន់គេ"* ។ បានខ្ញុំឡើងមកៗ ខ្ញុំមកដល់តាអំយើងនេះ ទុកកាណូត ទុកអីនោះ ខ្ញុំឡើងមកៗយួនចូលដល់តាប៉ុនបាត់ ។ ដល់ស្ពានតាប៉ុន បានខ្ញុំថយមកវិញ ខ្ញុំប្រជុំបងប្អូននៅអន្លង់សា ថា *"ឥឡូវមិត្តយើងពេលនេះគឺ យួនវាបានចូលដល់ប្រទេសកម្ពុជាយើងហើយ ។ ហើយបងប្អូនណាចង់វិលត្រឡប់ទៅស្រុក ភូមិវិញជួបជុំម៉ែឪវិញក៏ជួបចុះ ។ ហើយរបស់របរដែលមានប៉ុន្មាននេះ សូមឲ្យបងប្អូនចែក គ្នាកុំឲ្យទើសគ្នាឲ្យសោះ ។ អ្នកណាត្រូវបានអី យកអីក៏យកទៅ តែបើបងប្អូនណាដាច់ខាត ជាមួយខ្ញុំ គឺទៅតាមខ្ញុំ ព្រោះខ្ញុំអត់ហ៊ាននៅទេ ព្រោះខ្ញុំប្តេជ្ញាដាច់ខាតតាមអង្គការ"* ។ ហើយម៉ាចំនួនក៏តាមមកខ្ញុំបាន៩០នាក់ ដែលតាមទៅជាមួយខ្ញុំ ។ ដល់មកដល់ស្ពានតាប៉ុន

យួនមកដល់ ។ ដល់យួនមកដល់ ខ្ញុំឡើងអត់រួច ខ្ញុំបែកមកដេកនៅភ្នំកំបោរៗរួច បានទាក់ទងផ្លូវខាងនេះឡើងបានទៅ ដល់ឡើងដល់ភ្នំកូនខ្វែង ជួយនឹងយាយថែមៗ បានជួបគាពាល់ ជួបយាយថែមបាន៧-៨ខែដែរ ។ ដល់ចេញពីភ្នំកូនខ្វែង ទៅនៅភ្នំដងរែក ដាច់រយៈការ ទាំងអស់ មិនដឹងអង្គការនៅណាអីណា ពួកខ្ញុំនៅជាមួយគ្នាអត់បាយអត់ទឹក រកបាយស៊ីគ្មាន មិនដឹងទៅរកបាយណាបានស៊ី ដាច់រយៈអស់ នាំគ្នាស៊ីតែឫសឈើ មើមឈើ រហូតដល់យាយថែមទៅទាក់ទងបានដឹងអង្គការ តាមរយៈរបស់គាត់ទៅដឹងអង្គការ គាត់ក៏នាំទៅអន្លង់វែង ។ ដល់នាំទៅនៅអន្លង់វែង ពួកខ្ញុំទាំងអស់គ្នាដាច់ខាតអត់ទៅតាមយាយថែមទេ ។

ដានី : ម៉េចចឹង?

ឈួង : សុខចិត្តមកខាងភ្នំឆ័ត្រវិញ ព្រោះភ្នំឆ័ត្រ មានបារាំងមានអីបើកអង្គរឲ្យ ។ ហើយទៅខាងនោះ គឺគេថាកុម្មុយនីសចំ ឥឡូវយើងឈប់នាំគ្នាលាលែង ឈប់ធ្វើបដិវត្តឈប់ធ្វើកុម្មុនីយជាមួយ ។

ដានី : ទៅភ្នំឆ័ត្រវិញ?

ឈួង : បាទ! មកភ្នំឆ័ត្រនេះ ។

ដានី : ភ្នំឆ័ត្រខាងអី?

ឈួង : ខាងខ្មែរក្រហមដែរ ប៉ុនគេដិវុះចោលរបបខ្មែរក្រហម គេទៅជាលក្ខណៈជាទ័ពជាតិ ។

ដានី : ពីណាគេ អ្នកដឹកនាំនៅភ្នំឆ័ត្រ?

ឈួង : តាយ៉ន ។

ដានី : តាយ៉ន?

ឈួង : បាទ!

ដានី : តាយ៉ន ប្រធានអីគេ ប្រធានកងពល?

ឈួង : ប្រធានកងពល ប្រធានភូមិភាគនេះឯង តាយ៉ន ម៉ាភូមិភាគពាយ័ព្យ ។

ដានី : ពីណាគេអនុបន្ទាប់ៗគាត់ តាយ៉ន?

ឈួង : តាប៉ុម តាវឿន ។

ដានី : មាស វឿន?

ឈួង : ដឹងនាមត្រកូលគាត់ឈ្មោះអី តាវឿននោះគាត់មកដុតអត់ ។

ដានី : តាវឿន ឥឡូវគាត់នៅថ្មដែកកេះ ខាងគាត់ធ្វើប្រធានខាងសាសនាគ្រឹះ?

ឈួន ៖ ដឹង ខ្ញុំមិនដែលបានជួបគេ បែកគ្នា ។

ដានី ៖ បាទ! ហើយម៉េចទៀត?

ឈួន ៖ ហើយដល់តាវឿន គាត់នៅទៅ បានតាស៊ូតាអី តាស៊ូកុំបុតដៃយើង បានខ្ញុំទៅនៅជាមួយធ្វើការជាមួយតាស៊ូនឹង ទទួលអន្តរបារាំងបើកឲ្យប្រជាជន រហូតដល់ក្រោយមកទៅបានតាយ៉ននឹងគាត់ចាត់តាំងខ្ញុំឲ្យចុះមកធ្វើការក្នុង ។

ដានី ៖ ធ្វើការខាងក្នុងយ៉ាងម៉េច?

ឈួន ៖ ឲ្យធ្វើការខាងក្នុងដើម្បីបំផុសចលនាប្រាប់ប្រជាជនថាយើងផ្លាស់ប្ដូរខ្មែរក្រហម យើងមិនមែនពួកអាខ្មៅ មិនមែនពួកខ្មែរក្រហមអីទេ យើងជាកងទ័ពជាតិ ។ ហើយរបៀបរបបកងទ័ពជាតិយ៉ាងម៉េចៗ យើងនិយាយប្រាប់ប្រជាជនឲ្យយល់កុំឲ្យខ្លាច រហូតឲ្យប្រជាជនហ៊ានទៅបើកអន្តរនៅកន្លែងយើង ។

ដានី ៖ កាលនឹងពូគេចាត់តាំងឲ្យពូមកនៅក្នុងភូមិ?

ឈួន ៖ បាទ!

ដានី ៖ ភូមិណា?

ឈួន ៖ នៅព្រះនេត្រព្រះ នៅភូមិកំណើតខ្ញុំវិញ ។

ដានី ៖ នៅប៉ោយសំរោងនឹង?

ឈួន ៖ បាទ!

ដានី ៖ ប៉ុន្តែកាលនោះពូនៅមានតួនាទីអីគេ?

ឈួន ៖ ខ្ញុំកាលដែលនៅ ។

ដានី ៖ ដែលយើងមកបន្តប់នៅក្នុង?

ឈួន ៖ គេហៅថា មុនដំបូងចេះនិយាយទៅវាវែងទៅទៀត ។ មុនដំបូងនៅក្នុងព្រៃនោះ គេរៀបចំឲ្យមានគណៈស្រុក ។ ដល់គេរៀបចំឲ្យមានគណៈស្រុកនេះ គេបោះឆ្នោតទៅវាជាប់ខ្ញុំគណៈស្រុកព្រះនេត្រព្រះ ។ ដល់ជាប់គណៈស្រុកព្រះនេត្រព្រះ បានខៀវ សំផនគាត់មកធ្វើការ នឹងគាប់ផ្សា គាត់ថា គណៈស្រុកនីមួយៗត្រូវរំដោះស្រុកយកខ្លួនឯងឲ្យបាន ព្រោះមាន ទ័ព១៥០នាក់ ដែលទ័ពយើងមាន ។ ប៉ុនក្នុងនោះ គេឲ្យម៉ាមានទ័ពម៉ាវរសេនាធំ ។ ហើយ យើងទើបមានវរៈសេនាតូចឲ្យយើងរើសទ័ពខ្លួនយើងអីខ្លួនយើង វៃរំដោះស្រុកខ្លួនដោយ យើង ។ ចឹងបានខ្ញុំមានប្រធានខ្ញុំមួយជាស្នងការនយោបាយ ខ្ញុំអនុបញ្ញា ។

ដានី ៖ ពីណាគេប្រធាន?

ឈួង ៖ តាណុញ ។ ដល់ស្នងការនយោបាយគេនៅកាន់ទ័ពទៅ ខ្ញុំអនុបញ្ញានេះចុះមកធ្វើការជាមួយប្រជាជន ។

ដានី ៖ មកក្នុងជាមួយប្រជាជន?

ឈួង ៖ បាទ! មកនៅជាមួយប្រជាជន បើកអង្ករ ក៏មកនៅជាមួយ ។

ដានី ៖ ចុះខាងគេខាងក្នុង កាលនឹងរបបសាធារណរដ្ឋកម្ពុជា?

ឈួង ៖ បាទ!

ដានី ៖ កាលនោះ គេមិនគ្រប់គ្រងនឹងដែរ អត់ទេ?

ឈួង ៖ បាទ! គេគ្រប់គ្រងខ្ញុំដែរ ។

ដានី ៖ តែគេអត់ដឹងថា?

ឈួង ៖ គេដឹងដែរ ។

ដានី ៖ គេដឹងដែរ?

ឈួង ៖ ដឹង ។

ដានី ៖ គេដឹងថាពូនៅខាងខ្មែរក្រហមដែរ?

ឈួង ៖ បាទ! ដឹង ប៉ុន្តែសុទ្ធតែគ្នាឯងទាំងអស់ ។

ដានី ៖ ចឹងសុទ្ធតែដូចថាអ្នកស្រុកអ្នកភូមិស្គាល់គ្នាទៅ?

ឈួង ៖ បាទ! អ្នកស្រុកអ្នកភូមិស្គាល់គ្នា គេក៏ចាត់តាំងខ្ញុំឲ្យទៅធ្វើការនោះវិញដែរ ឲ្យទៅយកការណ៍នោះវិញ ។ ឲ្យយកការណ៍នោះ គេមិនមានយកការណ៍រឿងវៃគ្នាអីទេ ដើម្បីទៅផ្សព្វ ផ្សាយពីរឿងយួន មិនមែនធ្វើបាបប្រជាជនស្អីៗ ដើម្បីឲ្យប្រជាជនជំរំនោះចូលមកស្រុក វិញ ។

ដានី ៖ ហើយពូទៅដែរ?

ឈួង ៖ ទៅ ខ្ញុំទៅនោះទៅ ។

ដានី ៖ ប៉ុន្តែពូនៅខាងធ្វើការខាងនោះដដែល?

ឈួង ៖ បាទ! ធ្វើនៅនោះដដែល ។

ដានី ៖ តែរាយការណ៍ប្រាប់ថា ខាងក្នុងឲ្យរាយការណ៍អី ទៅរាយការណ៍?

ឈួង ៖ ប្រាប់ ។

ដានី ៖ គេអត់ថាអីទេ?

ឈួន ៖ បាទ! ដល់ខ្ញុំមកពីនោះទៅ ខ្ញុំប្រាប់អ្នកនេះដែរ ព្រោះរឿងអត់អារឿងវៃអីគ្នា គ្រាន់ថាផ្សាយ ។

ដានី ៖ ម៉េចទៀតទៅចឹង?

ឈួន ៖ ដល់ខ្ញុំនៅរហូត ដល់ពេលយូរទៅ ខ្ញុំបានប្រពន្ធបានអីទៅ ដល់ពេលផ្តាច់ខ្លួនចូលមក គេហៅខ្ញុំទៅកន្លែងវិញ ។

ដានី ៖ ពីណាហៅទៅ?

ឈួន ៖ ខាងខ្មែរក្រហម ខាងកងទ័ពជាតិ នឹងខាងតាស៊ូ ។

ដានី ៖ បាទ! គេហៅទៅវិញ?

ឈួន ៖ នឹងហើយហៅទៅវិញទៅ ក៏ខ្ញុំចូលទៅធ្វើការវិញទៅ រហូតបានប៉ុន្មានឆ្នាំក៏ខ្ញុំឈឺ ខ្ញុំឈប់ទៅ ។

ដានី ៖ កាលនឹងគេហៅទៅវិញ ពូមានតួនាទីអីដែរ?

ឈួន ៖ ខ្ញុំ នៅការិយាល័យទី៥ ។

ដានី ៖ ទី៥ នៅ?

ឈួន ៖ នៅការិយាល័យខាងកងពល ។

ដានី ៖ កងពលខាង?

ឈួន ៖ កងពល៨២ ។

ដានី ៖ កងពល៨២មកខាងចូលមកខាងរដ្ឋាភិបាលហើយ?

ឈួន ៖ បាទ! ចូលហើយ ៨១សព្វថ្ងៃ ។

ដានី ៖ ៨១សព្វថ្ងៃ?

ឈួន ៖ បាទ!

ដានី ៖ កងពលទី?

ឈួន ៖ កងពល៨២ នៅការិយាល័យទី៥ ។

ដានី ៖ ពូឈប់ពីអង្កាល់?

ឈួន ៖ ខ្ញុំឈប់បាន១០ឆ្នាំហើយ ។

ដានី ៖ ១០ឆ្នាំ កាលនឹងពូមានបានឋានន្តរសក្តិអីដែរ?

ឈួន ៖ កាលមិនទាន់ចូលការិយាល័យ ខ្ញុំសក្តិ៤កន្ទះ ។

ដានី ៖ ដល់ចូលការិយាល័យ?

ឈួង ៖ ដល់ចូលការិយាល័យសក្តិ២ ។

ដានី ៖ ពូឈប់១០ឆ្នាំ?

ឈួង ៖ បាទ!

ដានី ៖ យើងនៅមានប្រាក់សោធននិវត្តន៍ដែរ អត់ទេ?

ឈួង ៖ ទេ! ខ្ញុំមិនដែលបានយកទេ កាលដែលគេរៀបចំ កាលនោះខ្ញុំឈឺនៅកន្លែងពេទ្យ ខ្ញុំទៅអត់រួច ។ ទៅអត់រួច ខ្ញុំប្រគល់ឲ្យមេ ថាធ្វើម៉េចធ្វើទៅអារឿងឈ្មោះខ្ញុំ ផ្លាស់ប្តូរទៅកន្លែងណាទៅណា ប្រាក់ខែអ្នកណា បើកយកក៏បើកទៅ ។

ដានី ៖ ចឹង?

ឈួង ៖ បាទ!

ដានី ៖ ពូអត់ចង់បាន?

ឈួង ៖ អត់ចង់បានអីទេ ។ ដល់ក្រោយមក ខ្ញុំនៅសព្វថ្ងៃនេះ ប៉ុន្មានថ្ងៃមុន ហៅខ្ញុំទៅកន្លែងវិញ ។

ដានី ៖ បានចឹង?

ឈួង ៖ នោះហើយ ។

ដានី ៖ ពូទៅ មានឈ្មោះពូដដែល?

ឈួង ៖ ទេ! ឈ្មោះដូចថា បើសិនជាទៅឈ្មោះថ្មី តែឈ្មោះចាស់ខ្ញុំ គេជំនួស អាអ៊ុនគេជំនួស ។

ដានី ៖ លោកពូទៅអត់?

ឈួង ៖ ខ្ញុំទៅបានម៉ាថ្ងៃ ២ថ្ងៃ ខ្ញុំមកវិញ ដែលខ្ញុំមិនស្រួលរូបខ្ញុំ ខ្ញុំទៅថ្ងៃនេះចេះប្រមូលទ័ពចាស់ដើម្បីឲ្យគេជួយ ។ ព្រោះនឹកឃើញថា អ្នកតស៊ូទាំងអស់គ្នា ដល់ស្រុកយើងវាមានវល់ចេះ យើងត្រូវតែជួយគ្នាវិញ ។

ដានី ៖ ពូដូចថាពួកខ្ញុំសួរនាំពូវា២ម៉ោងកន្លះហើយ ហើយយូរដែលហើយពូ ។

ឈួង ៖ បាទ! មិនអីទេ ។

ដានី ៖ បាទ! ចឹងខ្ញុំដូចជាអស់សំនួរត្រូវសួរនាំពូទៀតហើយ ពូមានចង់បន្ថែមនូវអ្វីដែលខ្ញុំអត់បានសួរនាំពូទេ?

ឈួង ៖ បាទ!

ដានី ៖ ចង់បន្ថែមទៀតទេ?

ឈួង ៖ មិនមានបន្ថែមទៀតផង វាអស់ហើយ ចប់ដែរ ។

ដានី ៖ បាទ! ខ្ញុំអរគុណពូច្រើនដែលចំណាយពេលផ្ដល់បទសម្ភាសន៍ ទាក់ទងពីរឿងរ៉ាវ ពីបទពិសោធន៍របស់ពូ តាំងពីក្មេងមកដល់សម័យ៣ឆ្នាំ ហើយមកដល់ឥឡូវនេះ ខ្ញុំអរគុណពូច្រើនៗ

ឈួង ៖ បាទ!

«ចប់»